# គ្មានអ្វីធំជាងប្រយោជន៍ជាតិ



និពន្ធដោយ

ព្រះភិក្ខុ បញ្ញាបទីបោ គឿន វិបុល

ព្រះភិក្ខុ បញ្ញាបទីបោ គឿន វិបុល

គ្មានអ្វីធំជាងប្រយោជន៍ជាតិ

# ជីវប្រវត្តិសង្ខេប

ភិក្ខុបញ្ញាបទីបោ **ភឿន វិបុល**ប្រសូត្រនៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៨៦ ជាកូនកសិកររស់នៅភូមិត្រពាំងស្វាយ ឃុំគោគគង់ខាងកើត ស្រុកកញ្ជៀច ខេត្តព្រៃវែង ។

- ឪពុកឈ្មោះ **ផង ភឿន** មុខរបរកសិករ
- ម្តាយឈ្មោះ **ស៊ិន ហៃ** មុខរបរកសិករ

ភិក្ខុ **ភឿន វិបុល** មានបងប្អូនរួមផ្ទៃចំនួន៥នាក់គឺ÷

- បងស្រី **ភឿន ចិន្តា**
- បងស្រី **ភឿន ដារតី**(ស្លាប់)
- ភិក្ខុ **ភឿន វិបុល**
- ប្អូនស្រី **ភឿន ចន្ធី**
- ប្អូនប្រុស **ភឿន ដុល្លា**។

ភិក្ខុបញ្ញាបទីបោ ភឿន វិបុល បានសាងព្រះផ្នួសនៅក្នុងឆ្នាំ២០០០រហូតមកដល់សព្វថ្ងៃ...។ការសិក្សាភិក្ខុបញ្ញាបទីបោភឿន វិបុល ជាសមណនិស្សិតនៃសកលវិទ្យាល័យព្រះសីហនុរាជ នៅទីក្រុងភ្នំពេញ ឯកទេសទស្សនវិជ្ជាពុទ្ធសាសនា។

# នាមអ្នកចូលរួមជួយត្រួតពិនិត្យសៀវភៅនេះ

១.ភិក្ខុ **ជៅ សម្បត្តិ**

២.ភិក្ខុ វណ្ណសោភណោ **តាត ជី** (សហការីកុំព្យូទ័រ)

៣.ភិក្ខុ ពុទ្ធរក្ខិតោ **ចាន់ ពិន**

៤.ភិក្ខុ បញ្ញាបដីបោ **ភឿន វិបុល**(អ្នកនិពន្ធ និងវាយកុំព្យូទ័រ)

៥.ភិក្ខុ ជិរញ្ញាណោ **វុន ៉ាណា**

៦.លោកគ្រូ **អេង មេត្តា**

៧.ឧបាសក **ភឿ សុភ័ក្ត្រ**

ថ្ងៃចន្ទ័ ៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ផ្ញើនៅវត្តអរុណវតី,ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩

**ភិក្ខុបញ្ញាបដីបោ ភឿន វិបុល**

# មាតិកា

ចំណងជើង ទំព័រ

ឧទ្ទិសកថា.....................................................................i

អារម្ភកថា.....................................................................ii

អារម្មណ៍អ្នកជួយ.............................................................១

អ្វីហៅថាពលរដ្ឋ...............................................................៨

ខ្ញុំយកតែរបស់ខ្ញុំមកវិញតែប៉ុណ្ណោះ.................................១២

ជីវិតមោងលេងមាឌ..........................................................២៤

ភាពអសោចក្នុងគ្រួសារ......................................................៤០

រូបមនុស្សខ្លួរសត្វ.............................................................៤៥

អាស្រូវជីវិតអ្នកច្រាជ្វ.........................................................៥៤

ម៉ែឪមិនយល់ការកូនដិងវេទនា.............................................៦៨

ជម្ងឺចំឡែកក្នុងខ្លួនខ្ញុំ........................................................៧៧

មិនស្គាល់ខ្លួនឯងមិនស្គាល់តួនាទី.........................................៨២

កំនិតកន្ទុយអណ្ដើក..........................................................៨៨

ចង់តែបានចង់តែរស់ជាចរិតពូជសាសន៍ខ្ញុំ.........................៩២

ពិភពលោកនេះ......................................................................៩៦

ពលរដ្ឋខ្មែរស៊ាំក្នុងទុក្ខលំបាក....................................១០១

ស្រុកខ្ញុំស្រុកចំឡែក...................................................១១១

ក្មេងអត្តសញ្ញាណខ្លួនឯង............................................១១៧

សីល៥ប្រៀបដូចអាវក្រោះ............................................១២១

ដើម្បីកម្ពុជាមានសន្តិភាព.............................................១២៧

ទស្សនពិចារណា.........................................................................១៣៣

សេចក្តីបញ្ជាក់...........................................................១៣៦

ឯកសារពិគ្រោះ...........................................................១៣៧

នាមអ្នកចូលបោះពុម្ពសៀវភៅ.............................១៣៨

# ឧទ្ទិសកថា

ជាដំបូងក្នុងនាមខ្ញុំជាអ្នកនិពន្ធសៀវភៅនេះឡើង ខ្ញុំពិតជានឹករឭកដល់គុណ និងសូមដឹងគុណជាអនេកប្បការ ចំពោះប្រទេសកំណើតរបស់ខ្ញុំ(**កម្ពុជា**) ព្រមទាំងពួកលោកអ្នកជាបុព្វវីរបុរសជាតិដូនតាខ្មែររូប គ្រប់ៗជំនាន់ ដែលពួកលោកបានស៊ូលះបង់ជីវិត ប្តូរផ្តាច់យកមកវិញនូវទឹកដីកម្ពុជាសម្រាប់ទុកឲ្យពូជសាសន៍ខ្មែរ បានរស់នៅគ្រប់គ្នាតជំនាន់កូនចៅរហូតមកដល់សព្វថ្ងៃនេះ សូមដឹងគុណដល់ជនបដិវត្តន៍គ្រប់ជាតិសាសន៍ គ្រប់ៗជំនាន់ និងគ្រប់រូប ក្នុងនោះមាន(**ព្រះសម្មាសម្ពុទ្ធ**) ដែលជាបុគ្គលដ៏ឆ្នើមជាបុគ្គលឯក បានធ្វើបដិវត្តន៍ផ្នត់គំនិត ជាសកលដំបូងគេបង្អស់ក្នុងលោក។

សូមដឹងគុណដល់លោកទាំងពីរ ដែលបានផ្តល់កំណើតដល់ខ្ញុំ មានលោកឪពុក**ឆន ភឿន** និងអ្នកម្តាយ**ស៊ុន ហៃ** ។ ពួកលោកទាំងពីរ ដែលកំពុងមានវត្តមានជីវិតរស់នៅសព្វថ្ងៃ នៅភូមិត្រពាំងស្វាយ ឃុំគោកគង់ខាងកើត ស្រុកកញ្ច្រៀច **ខេត្តព្រៃវែង**។

សូមឲ្យពលិកម្មនេះ បានប្រែក្លាយទៅជាឧត្តមគតិ មនសិការជាតិ សាមគ្គីភាពនិងឯកភាពជាតិ សម្រាប់សង្គមពលរដ្ឋខ្មែរ ក៏ដូចសង្គមពិភពលោកទាំងមូលផងចុះ។

# អារម្ភកថា

សៀវភៅដែលមានឈ្មោះថា«**គ្មានអ្វីធំជាងប្រយោជន៍ជាតិនោះទេ**»នេះគឺជាសៀវភៅស្នាដៃដំបូងរបស់ខ្ញុំ ដែលខ្ញុំទើបតែបាននិពន្ធឡើង និងបានប្រមូលគំនិតទស្សនៈអ្នកប្រាជ្ញខ្មែរនិងបរទេសមួយចំនួនដែលខ្ញុំធ្លាប់បានរៀនចេះចាំយល់កន្លងមកបានខ្លះៗ យកមកបូករួមនិងគំនិតទស្សនៈផ្ទាល់ខ្លួន ទើបខ្ញុំសម្រេចចិត្តចាប់ផ្ដើមនិពន្ធសៀវភៅមួយនេះឡើងតែម្ដង។ ដោយខ្ញុំមានបំណងចង់បញ្ជាក់អំពីតថភាពជាក់ស្ដែង ដែលកំពុងតែកើតមាននៅក្នុងសង្គមខ្មែរសព្វថ្ងៃ និងសង្គមពិភពលោកទាំងមូល ហើយលើសពីនេះទៅទៀតនោះ ក៏ជាការបញ្ជាក់បង្ហាញពីអារម្មណ៍ពិតរបស់ខ្ញុំក្នុងនាមជាអ្នកនិពន្ធផ្ទាល់ផង ទាំងខណៈពេលដែលកំពុងតែមានវត្តមានជនបដិវត្តន៍ផ្នត់គំនិតដំបូងគេនៅកម្ពុជាផងនោះ(លោកពូខឹមវាសនា) ដែលលោកនិងកំពុងតែបានធ្វើដំណើរគ្រប់ទីកន្លែង ដើម្បីបង្ហាត់បង្ហាញនិងបង្រៀននូវសច្ចធម៌(**មេរៀនព្រះធម៌**) ដែលជាមេរៀនការពិតនៃជីវិត និងដំណោះស្រាយគ្រប់សព្វបែបយ៉ាង ឲ្យបានដល់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ក្នុងពិភពលោកទាំងមូលផងនោះ។

ម្យ៉ាងវិញទៀតដោយលោកមើលឃើញថា ពលរដ្ឋមួយចំនួនធំមានការពិបាក និងមិនទាន់មានមូលដ្ឋានគ្រឹះមានសមត្ថភាពគ្រប់គ្រាន់ អាចក្នុងការបេះគិតត្រិះរិះពិចារណារែកញែក និងមិនអាចបែងចែកឲ្យបានដាច់ស្រឡះនូវភាពល្អអាក្រក់បាននោះ ហើយទាំងមិនអាចដឹងបានទៅទៀតនៅក្នុងរឿងរ៉ាវដ៏ស្មុកស្មាញរឿងចង្អៀតជ្រៅៗមួយចំនួនធំ និងរឿងបំភាន់ភ្នែកជាច្រើនក្នុងលោកបានផងទៀតនោះ ទើបលោកសម្រេចចិត្តមកដើម្បី និងដើរជួយពន្យល់បំភ្លឺឲ្យបានដល់ពលរដ្ឋខ្មែរ ក៏ដូចជាពលរដ្ឋទូទៅក្នុងពិភពលោកឲ្យបានយល់ច្បាស់ ក្នុងនាមជាមនុស្សជាតិរួមលោកជាមួយគ្នានោះ។ ដែលខ្ញុំសម្រេចចិត្តដាក់ចំណងជើងសៀវភៅនេះថា«**គ្មានអ្វីធំជាងប្រយោជន៍ជាតិនោះទេ**»ដូច្នេះនោះក៏ជាពាក្យដែលបានមកពីទស្សនៈគំនិត របស់ជនបដិវត្តន៍ផ្ទត់គំនិតដំបូងគេនៅកម្ពុជានោះផងដែរ។

ដោយខ្ញុំយល់យ៉ាងដាក់ច្បាស់ថា នេះគឺជាពាក្យដែលចេញតែពីជនដែលមានមនសិការឧត្តមគតិសម្រាប់ជាតិយ៉ាងពិតប្រាកដតែមួយគត់ ហើយក៏ជាពាក្យដែលអាចនិងផ្ដល់ជាប្រយោជន៍ ឲ្យជាឧត្ដមគតិមនសិការជាតិបានដល់ ប្រជាជាតិសាសន៍ខ្មែរគ្រប់ៗជំនាន់បានផងទៀតនោះ ទើបខ្ញុំសម្រេចចិត្តយកពាក្យមួយនេះ ដាក់ធ្វើជាចំណងជើងសៀវភៅនេះតែម្ដងទៅ។

# អារម្មណ៍អ្នកជួយ

អារម្មណ៍អ្នកជួយគឺជាអារម្មណ៍ឈឺឆ្អាល ចិត្តអ្នកជួយជាចិត្តសង្គ្រោះ។ វាជាអារម្មណ៍ពិតរបស់ពួកលោកអ្នកត្រាស់ដឹង អ្នកជស្បូវវិទ្ធ និងពួកលោកអ្នកប្រាជ្ញសប្បុរសទាំងឡាយក្នុងលោក។ ប៉ុន្តែមិនមែនរាល់តែសកម្មភាពកន្លងមកនៃការជួយជាទូទៅរបស់មនុស្ស ដែលពួកយើងធ្លាប់តែបានឃើញមនុស្សចិត្តសាមញ្ញៗមួយចំនួនធំ ដែលពួកគេបានធ្វើកន្លងមក នោះក៏មិនមែនប្រាកដថាជាអារម្មណ៍ឬទង្វើរ ដែលចេញពីបេះដូងសង្គ្រោះពិត ឬជាចិត្តចង់ជួយដោយពិតប្រាកដនោះក៏មិនមែនដែរ បើយើងចេះនាំគ្នារៀនសង្កេតពិនិត្យបន្តិចឲ្យឃើញ ពីអារម្មណ៍នៃការជួយដែលចេញតែពីបេះដូងជួយពិត របស់ពួកលោកសប្បុរសទាំងឡាយបាននោះ ពិតណាស់ខួរក្បាលរបស់អ្នកគឺកាន់តែមានសមត្ថភាពកាន់តែខ្ពស់ហ៊ានអារកាត់ និងអាចដាក់ពិន្ទុកឲ្យមនុស្សទូទៅក្នុងពិភពលោកទាំងមូលនេះ ឲ្យសមល្មមទៅតាមកម្រិតទឹកចិត្តនោះបានទៀតផង។ អារម្មណ៍អ្នកជួយពិតប្រាកដ វាគឺជាអារម្មណ៍មួយដ៏បរិសុទ្ធដែលជាទឹកចិត្ត ចេញតែពីចិត្តរួចផុតពីភាពអាត្មានិយមរបស់ខ្លួន ជាចិត្តអាណិតជាចិត្តចង់ជួយនិងជាចិត្តសង្គ្រោះយ៉ាងពិតប្រាកដជាចិត្តប្រកបទៅដោយមនោសញ្ចេតនាគឺៈមេត្តា ករុណា និងមុទិតា ដែលជាចិត្តអាណិតស្រឡាញ់ជាចិត្តផ្តល់ឲ្យជាចិត្តសង្គ្រោះ គ្មានព្រំដែននោះទេ

សម្រាប់ពិភពលោកមួយនេះ គឺគ្មានលក្ខខណ្ឌសោះតែម្តង ហើយចិត្តរបស់ពួកលោកទាំងនោះសោធ ក៏ជាចិត្តខ្ពស់ លើសពីទឹកចិត្តមនុស្សធម្មតាផងដែរ **ជាចិត្តស្មោះត្រង់ ជាចិត្តទាន ជាចិត្តបូជា ជាចិត្តសង្គ្រោះ** ជាចិត្តមួយដែលចេញផុតពីភាពអាត្មានិយម គឺជាទឹកចិត្តនៅក្នុងលំដាប់ទានថ្នាក់ទីពីរទើបគឺជាទាន**ឧបចារមី** និងជាទានលំដាប់ថ្នាក់ទីបី ជាទានខ្ពស់បំផុតគឺ **បរមត្ថចារមីទាន** ជាចិត្តផ្តល់ឲ្យដ៏ខ្ពស់ក្នុងលំដាប់លំហូរនៃទឹកចិត្តរបស់ព្រះអរហន្តទាំងឡាយផងដែរ។ ទឹកចិត្តសង្គ្រោះរបស់ពួកលោកសប្បុរសទាំងឡាយនោះ ប្រៀបបានទៅនិងដុំថ្មយ៉ាងធំមហិមា ដែលបានកំពុងនិងរមៀលធ្លាក់ចុះមកពីលើកំពូលភ្នំ ឬដូចជាទឹក ដែលកំពុងហូរធ្លាក់ពីទីទួលខ្ពស់ ហូរចុះមកកាន់ទីទំនាបនោះអញ្ចឹងណា គឺថាគ្មានអ្វីណាមួយអាចមកអាចរាំងធ្វើឲ្យស្ទះទប់ទាក់មិនឲ្យថ្មដ៏ធំ ឬទឹកនោះមិនឲ្យធ្លាក់ចុះមកក្រោមនោះ គឺថាពុំអាចទប់បាននោះឡើយ។ យ៉ាងណាមិញ ទឹកចិត្តរបស់ពួកលោកអ្នកត្រាស់ដឹង និងពួកលោកសប្បុរសវីរបុរសទាំងឡាយនោះ ក៏យ៉ាងដូច្នោះផងដែរ គឺថាគ្មានអ្នកណាម្នាក់ក្នុងពិភពលោកមួយនេះ អាចមកហាមឃាត់ឬមកទប់ស្កាត់នូវលំហូរទឹកចិត្តនិងសកម្មភាពដ៏បរិសុទ្ធរបស់ពួកលោកទាំងនោះ ដើម្បីមិនឲ្យពួកលោកមកជួយសង្គ្រោះមនុស្សក្នុងលោកទាំងមូលនេះ ក៏ពុំអាចបានដូចគ្នានោះផងដែរ។ ចិត្តឈឺឆ្អាលរបស់ពួកលោកសប្បុរសទាំងនោះ គឺពិតជាទឹកចិត្តឪពុក

ម្តាយដែលមានទំនួលខុសត្រូវចំពោះកូនៗមែន ដែលតែងតែព្រួយបារម្ភជាប់មិនដាច់ ពួកលោកចេះតែមានអារម្មណ៍ឈឺឆ្អាលជានិច្ច ហើយក៏តែងតែបារម្មណ៍ខ្លាចក្រែងលោមនុស្សក្នុងពិភពលោកទាំងមូលនេះ និងធ្លាក់ចូលទៅក្នុងដំណើរផ្លូវខុសធ្លាក់ចូលក្នុងគំនិតខុសគឺគំនិត **មិច្ឆាទិដ្ឋិ** (គំនិតយល់ខុស)នោះឯង អាចជាហេតុបណ្តាលធ្វើឲ្យ ពិភពលោកទាំងមូលនេះ និងប្រែក្លាយទៅជាភ្នក់ភ្លើងដ៏ធំ ដែលវាអាចនិងនាំបណ្តាលឲ្យឆេះកម្ទេចពិភពលោករបស់មនុស្សទាំងមូលនេះទៀតផង។ ដូច្នេះហើយ បានជាពួកលោកសប្បុរសទាំងនោះ ពួកលោកខិតខំព្យាយាមត្រិះរិះពិចារណាជាខ្លាំង ក្នុងការស្វែងរកគ្រប់មធ្យោបាយ ដើម្បីនិងទប់ស្កាត់កុំឲ្យរឿងដែលគួរឲ្យភ័យខ្លាច សម្រាប់ពិភពលោកមួយនេះ វាមានឱកាសកើតឡើងបាន មកលើមនុស្សក្នុងលោកយើងនេះ។ ដោយពួកលោកបានយល់ឃើញ ពីដំណើរនៃក្តីវិនាសសកម្មយ៉ាងធំធេងដូច្នេះហើយ ទើបពួកលោកបានប្តេជ្ញាយ៉ាងមុតមាំបំផុត ទៅក្នុងការទប់ស្កាត់ចំពោះរឿងគ្រោះថ្នាក់ដ៏ធំមួយនេះ រហូតដល់ថ្នាក់ពួកលោកហ៊ានលះបង់ក្តីសុខផ្ទាល់ខ្លួន ស៊ូយកជីវិតរបស់ពួកលោកទៅជួយការពារជីវិតមនុស្សមួយផែនដី និងពិភពលោកទាំងមូលផងនោះ ទាំងដែលមនុស្សមួយពិភពលោក គេកំពុងតែដេកលង់លក់យ៉ាងស្កប់ស្កល់ មិនទាំងនិងបានយកបេះដូងសន្តានភ្នែកត្រជៀក របស់ពួកគេមកគិតមកមើលមកស្តាប់មកចាប់អារម្មណ៍

ដឹងសុខទុក្ខរបស់ពួកលោកផងនោះ។ អារម្មណ៍បេះដូងឈឺឆ្អាលរបស់ពួកលោកមានសេចក្តីសង្រ្គោះទាំងស្រុង ស្រោចទៅលើមនុស្សមួយពិភពលោក ប្រាជ្ញាខួរក្បាលរវៃប្រឹងគិតស្វែងរកមធ្យោបាយសព្វគ្រប់បែបយ៉ាង ដើម្បីដោះស្រាយនូវរាល់បញ្ហាផ្សេងៗដែលបានកំពុងតែកើតមានឡើង និងស្វែងរកផ្លូវដើម្បីធ្វើឲ្យពិភពលោកទាំងមូលនេះ ឲ្យបានរីកចម្រើនសម្រាប់ទុកឲ្យមនុស្សរស់នៅបានសុខសន្តិភាព ឯដៃម្ខាងក្រសោបឱបមនុស្សល្អទន់ខ្សោយ ដែលត្រូវបានមនុស្សអាក្រក់កំពុងធ្វើបាបជិះជាន់ជារៀងរាល់ថ្ងៃ ចំណែកឯដៃម្ខាងទៀតកាន់ដាវដេញកម្ចាត់ពពួកមនុស្សខូចអាក្រក់ចិត្តអាត្មានិយមទាំងឡាយ ដែលពួកគេតែងតែនាំគ្នាបង្ករបង្កើតនូវបញ្ហាក្តៅក្រហាយផ្សេងៗជាច្រើនមិនចេះចប់មិនចេះហើយនោះ ទុកឲ្យមកដល់សង្គមនិងពិភពលោកទាំងមូល ទាំងដែលពួកខ្លួនដែលជាអ្នកបំផ្លាញកំពុងតែត្រដររស់នៅផងនោះ។ សួរថាៈទឹកចិត្តលះបង់គ្រប់ៗជំនាន់របស់ពួកលោកសប្បុរសទាំងនោះ មានជាប់រហូតមកទាល់ដល់សព្វថ្ងៃនេះប៉ុណ្ណឹងហើយ តើសមគួរឲ្យពួកយើងល្មមចេះភ្ញាក់គំនិតកំណើត អាចចេះគោរពដឹងគុណ និងអាចចេះមើលដឹងថាមនុស្សណាល្អមនុស្សណាអាក្រក់ហើយឬនូវ? ជាការពិតបើមនុស្សមួយពិភពលោកនេះ ជាមនុស្សសម្បូរជាអ្នកមានសន្តានបេះដូងជាមនុស្សពិតប្រាកដ មានចិត្តកតញ្ញូ (**ចេះដឹងគុណចេះតបគុណ**) គឺថាពួកគេអាចនិងមើលឃើញ និង

យល់បាននូវទឹកចិត្តលះបង់ដ៏ធំធេងសម្រាប់ប្រយោជន៍រួមលោកមួយនេះ របស់ពួកលោកសប្បុរសទាំងនោះយ៉ាងពិតប្រាកដ តែផ្ទុយមកវិញ បើបេះដូងរបស់ពួកគេគ្មានសន្តានជាបេះដូងមានសារជាតិជាមនុស្សគ្មានកតញ្ញូទេនោះ គឺពិតណាស់ពួកគេក៏និងមិនអាចមើលឃើញយល់បាននូវទឹកចិត្តសង្គ្រោះ ទឹកចិត្តលះបង់ដ៏ធំធេងមួយនេះ បាននោះឡើយ គឺថាពួកគេមើលមិនឃើញជារៀងរហូត អស់មួយជីវិតរបស់ពួកគេនោះតែម្តង។

# អ្វីដែលហៅថាពលរដ្ឋ?

**ពល+រដ្ឋ>ពលរដ្ឋ**(រដ្ឋពល)=ពលរបស់រដ្ឋ ពលអាស្រ័យនៅក្នុងរដ្ឋ ប្រជាជនទាំងប្រុសទាំងស្រី ដែលទុកជាកម្លាំងរបស់ប្រទេស ពលរដ្ឋម្នាក់ៗគប្បីបំពេញពលិកម្មផ្សេងៗ ចំពោះប្រទេសជាតិមាតុភូមិរបស់ពួកខ្លួនដោយប្តូរផ្តាច់ ទៅតាមលទ្ធភាពនិងតួនាទីរបស់ខ្លួន។ ពលរដ្ឋម្នាក់ៗ គឺជាកោសិការរបស់សង្គមជាតិខ្លួន ហើយមនុស្សដែលជាពលរដ្ឋទូទៅ ក៏ជាកោសិការរបស់ពិភពលោកទាំងមូលផងដែរ។ ពលរដ្ឋគឺជាអ្នករស់នៅក្នុងសង្គម ទោះបីជាទៅរស់នៅក្នុងសង្គមណាមួយដទៃផ្សេងក៏ដោយ នៅក្នុងសង្គមកំណើតរបស់ខ្លួនក្តី ទៅរស់នៅឯសង្គមប្រទេសជាតិដទៃៗក្តី ពលរដ្ឋជាទូទៅត្រូវតែមានកតព្វកិច្ច និងករណីកិច្ចនៅក្នុងសង្គម ដែលខ្លួនកំពុងតែរស់នៅនោះជាចាំបាច់ ហើយលើសពី

នេះទៅទៀតនោះ ត្រូវតែមានកតញ្ញូកិច្ចយ៉ាងធំធេង និងយ៉ាងប្តូរផ្តាច់បំផុត នៅក្នុងសង្គមកំណើតរបស់ពួកខ្លួនជាចាំបាច់ខានមិនបាននោះឡើយ។

សភាពចិត្តដាច់ ចិត្តអកតញ្ញូ និងភាពអាត្មានិយម(**គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន**)បើវាបានកើតមានទៅលើពលរដ្ឋនៅក្នុងសង្គមណាមួយហើយនោះ សង្គមមួយនោះពិតណាស់ វាសមល្មមនិងរលាយបានហើយ បើវាមិនរលាយទេនោះទើបវាចំឡែក។ ពលរដ្ឋដែលចេះតែរស់នៅក្នុងសង្គម ហើយដែលចេះតែនាំគ្នាទទួលយកបាន នូវគ្រប់ៗតែស្ថានភាពរាល់តែបញ្ហាទាំងអស់របស់សង្គមបាននោះ គឺវាពិតជារឿងគ្រោះថ្នាក់ខ្លាំងណាស់ទៅអនាគតសម្រាប់សង្គមមួយនេះ។ ដោយពលរដ្ឋមានតែចរិត មិនចង់ខ្វាយខ្វល់ពីសង្គម នឹងគ្មានអារម្មណ៍ចេះទើសទាស់នូវរឿងដែលពួកខ្លួនបានយល់ទាំងអស់គ្នាយ៉ាងច្បាស់ហើយថា វាពិតជារឿងដែលមិនស័ក្តិសម ហើយវាតែងតែកើតមានជារឿយៗដែលវាតែងតែនាំមកនូវការប៉ះពាល់ដល់សង្គម របស់ពួកខ្លួនយ៉ាងពិតប្រាកដថែមទៀតផងនោះ នូវតែមិនចេះព្រមភ្ញាក់កំណើត នូវមិននាំគ្នាព្រមប្រតិកម្មតបនោះ គឺវាស័ក្តិសមនឹងទទួលបាននូវសង្គមមួយ ដោយគ្មានការរីកចម្រើនយ៉ាងនេះ និងមានតែភាពភ័យខ្លាច អសន្តិសុខពាសពេញតែក្នុងសង្គមជាតិ ជារៀងរាល់តែថ្ងៃមិនចេះចប់មិនចេះហើយយ៉ាងនេះនោះ គឺវាសមហេតុសមផលស្មើចុងស្មើដើមហ្នឹងហើយ។ គឺវាស័ក្តិសមសម្រាប់ពលរដ្ឋ

ដែលរស់នៅក្នុងសង្គមមួយនិងគេដែរ ដែលមានតែចរិតគំនិតចោលម្សៀតចេះតែនាំគ្នាខ្ជិលមិនចង់ដឹងចង់ឮពីបញ្ហាសង្គមនោះ នេះហើយដែលជាលទ្ធផលមិនចង់ខ្វាយខ្វល់មិនចង់គិតគូរពីសង្គម របស់ពួកខ្លួនរស់នៅសព្វថ្ងៃនោះឯង។ ហើយនៅតែនាំគ្នាអាចទទួលទ្រាំយកបានតែគ្រប់ស្ថានភាព គ្រប់ៗតែហេតុការណ៍បញ្ហានោះបានទៀត ទោះបីតែមានភាពអសកម្មអសមត្ថភាពក្នុងការដឹកនាំពីមេដឹកនាំក្នុងការដឹកនាំប្រទេសពីមួយឆ្នាំទៅមួយឆ្នាំ ដែលនាំតែប្រទេសទៅរកតែភាពវិនាសសកម្ម និងនាំតែភាពក្ដៅក្រហាយមកផ្ដល់ឲ្យដល់ពួកខ្លួន(**ពលរដ្ឋ**) និងប្រទេសប៉ុណ្ណឹងហើយក៏ដោយក្ដី ក៏ពួកគេនៅតែបន្តគាំទ្របានទៀត។ នេះសរបញ្ជាក់ឲ្យឃើញបានថា ពួកអ្នកជាប្រជាពលរដ្ឋពិតជាល្ងង់ខ្លៅបំផុត ដែលនៅក្នុងសង្គមមួយក្នុងពិភពលោកជាមួយនឹងគេដែរនោះ ដែលគេឲ្យមានក្បាលមានភ្នែកមានត្រចៀក ដើម្បីឲ្យចេះមើលឲ្យចេះគិតឲ្យចេះស្ដាប់ តែបែរជាមិនចេះនាំគ្នាមើល មិនចេះនាំគ្នាគិតពិចារណាមិនចេះនាំគ្នាស្ដាប់នោះទៅវិញ។ បើមានតែភ្នែកមានតែក្បាលមានតែត្រចៀក ហើយមិនចេះមើលមិនគិតមិនចេះស្ដាប់មិនចេះស្វែងយល់ឲ្យបានច្បាស់ ទៅនឹងពិភពលោកខាងក្រៅឲ្យបានដឹងថាគេនឹងបានកំពុងតែដើរទៅដល់ណាហើយ គេបានកំពុងរីកចម្រើនទៅដល់ណាហើយទេនោះ គឺវាពិតជារឿងអភ័ព្វ និងគួរឲ្យ

ខ្មាសគេខ្លាំងណាស់ សម្រាប់ពួកអ្នកក្នុងនាមជាប្រជាពលរដ្ឋ ដែលកំពុងតែរស់នៅក្នុងសង្គមមួយនៅរួមពិភពលោកនិងគេដែរនោះ។

បែរមកមើលសង្គមរបស់ខ្លួននៅពេលសព្វថ្ងៃមានតែសភាពសោះកក្រោះ ដែលស្ថិតតែនៅក្នុងស្ថានភាពដ៏តូចចង្អៀត( **គ្មានសេរីភាព** ) ហើយមានតែភាពងងឹតសូន្យឈឹង( **សម្បូរតែមនុស្សអវិជ្ជាអាត្មានិយម** )តែប៉ុណ្ណោះទៅវិញ។ នេះឯងហើយគឺជាលទ្ធផល ដែលពួកអ្នកជា( **ពលរដ្ឋ** )មិនព្រមនាំគ្នាចង់គិតខ្វល់ មិនព្រមនាំគ្នាយកភ្នែកបេះទៅមើលគេនោះឯង។ សង្គមមួយអាចធ្លាក់ចុះ ឬរីកចម្រើនទៅមុខបាននោះ ពិតណាស់វាអាស្រ័យទៅលើពលរដ្ឋនៅក្នុងសង្គមមួយនោះ សម្បូរទៅដោយពលរដ្ឋដែលមានចំណេះដឹងក្នុងដំណើរឧត្តមគតិ និងមនសិការជាតិ ដែលយើងធ្លាប់តែនិយាយថាសម្បូរធនជានមនុស្សពិតប្រាកដនោះឯង តែវាមិនមែនត្រឹមតែមានចំណេះដឹងច្រើនលើសគេ តែបែរជាមានតែភាពអាត្មានិយមនោះទេ ហើយបើពួកអ្នកជាប្រជាពលរដ្ឋ ពិតជាចង់ឲ្យសង្គមគ្រួសាររបស់ខ្លួនម្នាក់ៗ មានសុខសុវត្ថិភាពសុភមង្គលជានិរន្តរ៍ទៅបានពិតមែននោះ គឺពួកអ្នកត្រូវដឹងឲ្យបានច្បាស់ជាមុនថាពួកអ្នកចាំបាច់ត្រូវតែធ្វើឲ្យសង្គមជាតិរបស់ពួកអ្នកមួយនេះ អោយវាបានសន្តិ

ភាពនិងសុខសុវត្ថិភាពរីកចម្រើនពិតប្រាកដជាមុនសិន បើមិនដូច្នោះទេកុំសង្ឃឹមថាគ្រួសារដ៏តូចរបស់ពួកអ្នកនេះបានសុខឲ្យសោះ។

ដែលអាចឲ្យសង្គមមួយមានសន្តិភាព និងសុខសុវត្ថិភាពរីកចម្រើនពិតប្រាកដទៅបាននោះ គឺវាពិតជាត្រូវអាស្រ័យទៅលើសមត្ថភាពចំណេះដឹងខ្ពស់ផ្នែកខាងខួរក្បាលរបស់ពលរដ្ឋ ដែលនៅក្នុងសង្គមមួយនោះយ៉ាងពិតប្រាកដបូករួមជាមួយនិងទឹកចិត្តមនោសញ្ចេតនា និងកោសិការនៃមនសិការជាតិ ឧត្តមគតិជាតិបានល្អជាមុនសិននោះឯងយ៉ាងពិតប្រាកដ នោះទើបបានអាចធ្វើឲ្យសង្គមគ្រួសាររបស់ពួកអ្នកម្នាក់ៗ និងមានសុខសុវត្ថិភាពសុភមង្គលជានិរន្តរ៍ទៅបានយ៉ាងពិតប្រាកដ នេះគឺជារូបមន្តមួយដ៏ត្រឹមត្រូវក្នុងចំណោមរូបមន្តដ៏ត្រឹមត្រូវជាច្រើនផ្សេងទៀត ក្នុងការយកទៅកសាងសង្គមជាតិ និងសង្គមគ្រួសាររបស់ពួកអ្នកដើម្បីឲ្យមានការរីកចម្រើនពិតប្រាកដទៅមុខបាននោះណា។

ម្យ៉ាងវិញទៀតពលរដ្ឋជាមនុស្សដែលមានសន្តានចិត្ត ជាអ្នកចេះដឹងគុណមានចិត្ត មានមនោសញ្ចេតនា មានមនសិការ មានឧត្តមគតិចំពោះសង្គមជាតិ ដែលពួកខ្លួនបានកំពុងតែរស់នៅសព្វថ្ងៃនេះ គឺជាមូលហេតុដែលធ្វើឲ្យសង្គមជាតិរបស់ពួកគេមួយនេះ នឹងបានរួចផុតពីភាពងងឹតអន្ធការ ហើយធ្វើឲ្យសង្គមពួកគេមួយនេះវាកាន់តែមានពន្លឺភ្លឺស្វាង និងកាន់តែមានការរីកចម្រើន

ទៅខាងមុខៗបានថែមទៀតផង។ តែផ្ទុយមកវិញ បើពួកអ្នកជាប្រជាពលរដ្ឋជាម្ចាស់ប្រទេសជាម្ចាស់អំណាច បែរជានាំគ្នាមិនខ្វីចង់គិតមិនខ្វីចង់ខ្វល់ពីសង្គមសព្វថ្ងៃរបស់ពួកខ្លួនទេនោះ ហើយចាំតែមើលបំណាំចាំតែចាប់កំហុសទាំងងងឹតងងុល គ្មានការពិចារណាឲ្យបានច្បាស់លាស់ជាមុនសិនទេនោះ និងថែមទាំងបានទុកកិច្ចការងារសង្គមជាតិទាំងមូល ទុកឲ្យតែមេដឹកនាំ (**រដ្ឋាភិបាល**)ម្នាក់ឯង ជាអ្នកដោះស្រាយ និងជាអ្នកទទួលខុសត្រូវតែម្នាក់ឯងថែមទៀតផងនោះ ពិតណាស់សង្គមរបស់បងប្អូនមួយនេះ ដាច់ខាត់គឺវាមិនអាចរីកចម្រើន និងអាចដោះស្រាយបញ្ហាទៅរួចបាននោះឡើយ គឺវាមានតែការធ្លាក់ចុះដុនដាបជាបន្តបន្ទាប់ថែមទៀតតែប៉ុណ្ណោះ។ សាករៀនគិតរៀនស្រម៉ៃបន្តិចមើល៍ បងប្អូនវាជាការងារប្រទេសជាតិទាំងមូលណា! វាមិនមែនជាការងារផ្ទះក្រុមគ្រួសារតូចមួយនោះទេណា!។

ជាការពិតណាស់សង្គមជាតិមួយនេះ គឺជារបស់ពួកយើងដែលជាប្រជាពលរដ្ឋជាម្ចាស់ សង្គមធ្លាក់ចុះក្តី ឬរីកចម្រើនទៅបានក្តី គឺវាអាស្រ័យទៅលើពួកយើងហើយ ដែលជាប្រជាពលរដ្ឋដែលនៅក្នុងសង្គមនោះជាអ្នកនាំគ្នាធ្វើនោះ។ យើងដាក់**សំនួរ**សួរថាៈព្រោះហេតុអ្វី? **ចម្លើយ**ៈគឺវាគ្មានហេតុអ្វីក្រៅតែពីវា

ជាសង្គម វាជាផ្ទះរបស់ពួកយើងទាំងអស់គ្នា ដែលពួកយើងកំពុងតែរស់នៅសព្វថ្ងៃនោះទេ។

ម្យ៉ាងវិញទៀតអ្នកត្រូវដឹងឲ្យបានច្បាស់ថាសង្គមមួយនេះ គឺវាមិនមែនជាសង្គមសម្រាប់តែមេដឹកនាំតែម្នាក់ឯងនោះទេ ហើយក៏មិនមែនសម្រាប់តែបុគ្គលដែលជាពលរដ្ឋ**ភាវគយជ**ណាម្នាក់នោះក៏អត់ទេដែរ!

តែជាការពិត **វាគឺជាសង្គម វាជាប្រទេស វាជារដ្ឋ វាជាផ្ទះរួម** របស់ពួកយើងទាំងអស់គ្នា ដែលជាប្រជាពលរដ្ឋ ដែលជាម្ចាស់ប្រទេសនោះឯងយ៉ាងពិតប្រាកដតែម្តង។ បើពួកយើងបានដឹងច្បាស់ហើយថា ពួកយើងជាម្ចាស់ប្រទេសយ៉ាងពិតប្រាកដដូច្នេះហើយនោះ តើពួកយើងគួរនូវមានចិត្តរារែកដល់ណាទៀតទៅ? ហេតុអ្វីក៏ពួកយើងមិនព្រមនាំគ្នាបើកចិត្ត បើកបេះដូងប្រមូលកម្លាំងពង្រឹងអំណាចខំបង្កើនចំណេះដឹងជាចំណីខួរក្បាល ក្នុងនាមជាពលរដ្ឋម្ចាស់ប្រទេសម្ចាស់អំណាចទាំងអស់គ្នា ដើម្បីសម្រេចកិច្ចការងារស្រុកទេសរបស់ពួកយើង ដោយពង្រឹងអំណាចក្នុងនាមជាប្រជាពលរដ្ឋជាម្ចាស់ប្រទេសរបស់ពួកយើងទាំងអស់គ្នានោះទៅ៕

# ខ្ញុំយកតែរបស់ខ្ញុំមកវិញតែប៉ុណ្ណោះ

ការបាត់បង់នូវរបស់ដ៏មានតម្លៃ ដែលវាមានតម្លៃលើសមនុស្សមួយនគរទៅទៀតនោះ គឺវាពិតជាពិបាកនិងធ្វើចិត្តឲ្យព្រមទទួលយកខ្លាំងណាស់ សម្រាប់ម្ចាស់របស់ជាទូទៅ ដែលតែងតែធ្លាប់បានបាត់បង់របស់ជាទីស្រឡាញ់លើសជីវិតនោះ។ យ៉ាងណាមិញចិត្តរបស់វិជ្ជា ក៏មិនខុសអីពីម្ចាស់របស់ទាំងឡាយ ដែលធ្លាប់តែបានបាត់របស់ទាំងឡាយនោះផងដែរ។ ភាពស្មោះត្រង់ពោរពេញទៅដោយមនសិការ និងឧត្តមគតិជាតិ ពោរពេញទៅដោយភាពនឹងធឹង និងសម្បូរទៅដោយចំណេះដឹងខ្ពស់ផងនោះ វិជ្ជាគឺជាមនុស្សម្នាក់ដែលមានចក្ខុវិស័យ និងទស្សនវិស័យ ដ៏ភ្លឺស្វាងម្នាក់ក្នុងចំណោមពលរដ្ឋទូទៅក្នុងសង្គមជាតិរបស់ខ្លួន។

ដូច្នេះហើយពេលវេលាក្នុងការរស់នៅ របស់វិជ្ជាគឺវាពិតជាមានតម្លៃខ្លាំងណាស់ សម្រាប់វិជ្ជាក្នុងការធ្វើសកម្មភាពការងារផ្សេងៗ ដើម្បីឲ្យបានដល់សង្គម និងសម្រាប់មនុស្សជាតិទូទៅ។ ជាពិសេសគឺក្នុងកិច្ចការងារជួយដល់ប្រទេសកំណើតរបស់ខ្លួន ដោយមនសិការជាតិដ៏ត្រឹមត្រូវ ដើម្បីចូលរួមចំណែកមួយក្នុងការដឹងគុណ ដល់ទឹកដីប្រទេសកំណើត និងដើម្បីចូលរួមជួយដល់ពូជសាសន៍រួមឈាមរបស់ខ្លួនផង។ វិជ្ជាបានសិក្សាស្វែងយល់ យ៉ាងជាក់ច្បាស់ទៅលើតម្លៃនៃចំណេះដឹង សមត្ថភាព និងបទពិសោធន៍ ដែលខ្លួនកំពុងមានទាំង

អម្បាលមាណនេះ និងត្រូវតែយកមកបម្រើ យកមកប្រើប្រាស់ ឲ្យអស់ពីសក្តានុពលភាព ទៅលើផ្លូវដ៏ត្រឹមត្រូវមួយ ក្នុងដំណើរនៃជីវិតមួយនេះ ដើម្បីយកមកបម្រើឲ្យដល់ជាតិសាសន៍របស់ខ្លួនមួយនេះ គឺថាវិជ្ជាមានសុបិន្តមួយចង់ធ្វើឲ្យបានទៅដល់បងប្អូនពូជសាសន៍របស់ខ្លួន ឲ្យពួកគេបានស្គាល់ច្បាស់ម្តងថាអ្វីទៅ ដែលជាសេចក្តីសុខពិត នឹងភាពរីកចម្រើនរបស់ប្រទេសជាតិមួយដ៏ពិតប្រាកដនោះ។

ដូច្នេះហើយ ចំណេះដឹងទាំងអម្បាលមាណដែលខ្លួនមាន វិជ្ជាបានយកមកប្រើទាំងអស់ ដោយអស់ពីសមត្ថភាព នូវអ្វីដែលខ្លួនអាចធ្វើបាន ដើម្បីធ្វើឲ្យបានជាផលប្រយោជន៍ដល់សង្គមជាតិមួយនេះ និងឲ្យបានដល់បងប្អូនប្រជាពលរដ្ឋពូជសាសន៍រួមឈាមរបស់ខ្លួនផង។ ចំណេះដឹងដែលវិជ្ជាមានភាគជាទូទៅ គឺបានមកពីការខិតខំប្រឹងប្រែងអត់ធ្មត់រៀនសូត្រ ព្យាយាមថ្លឹងថ្លែងរិះរកគិតត្រិះរិះពិចារណាស្វែងរកហេតុ និងផលដ៏ត្រឹមត្រូវ ទូទៅក្នុងមជ្ឈដ្ឋានផ្សេងៗ នឹងចេះរៀនស្តាប់ចាប់យកចំណុចសំខាន់ៗ ពីបរិស្ថានជុំវិញ ដែលខ្លួនបានកំពុងតែរស់នៅសព្វថ្ងៃនោះឯងភាគច្រើន។

នៅពេលវិជ្ជាខំព្យាយាមត្រិះរិះគិតពិចារណាដោយចិត្តស្មោះ ក៏បានស្វែងយល់ពីហេតុផលត្រឹមត្រូវនោះបានកាន់តែច្រើនឡើង វិជ្ជាក៏មានចំណេះដឹងពិសេសម៉្យាងផ្សេងទៀតយ៉ាងប្រត្យ័ក្ស ហើយអាចប្រមើលមើលឃើញ និង

អាចយល់បានយ៉ាងជាក់ច្បាស់ពីស្ថានភាព និងដំណើររបស់ពិភពលោកទាំងមូលនេះ បានយ៉ាងពិតប្រាកដថែមទៀតផងដែរ។ ដោយស្ថានភាពជាក់ស្តែង ពិភពលោកមួយនេះ គឺវាត្រូវបានរងនៅភាពអយុត្តិធម៌ យ៉ាងព្រៃផ្សៃជាច្រើនដែលបានកំពុងកើតឡើងជាបន្តបន្ទាប់។ ដោយការយល់អំពីដំណើរ និងមើល៍ឃើញយ៉ាងជាក់ច្បាស់ពីស្ថានភាពពិភពលោកយ៉ាងដូច្នេះហើយ បានជាវិជ្ជាឲ្យតម្លៃជាខ្លាំងទៅលើការចេះ **ជួយឈឺឆ្អាលគ្នា និងចេះចូលរួមសាមគ្គីភាពគ្នា** ចូលរួមដើម្បីនាំគ្នាជួយរកយុត្តិធម៌ ឲ្យបានដល់មនុស្សក្នុងពិភពលោកទាំងមូលនេះ ដែលនិងកំពុងតែស្ថិតរងនូវការធ្វើទុក្ខធ្វើទោសធ្វើទុក្ខបុកម្នេញ មកពីសំណាក់ពពួកអាមនុស្សបាតសង្គម(**មនុស្សអាក្រក់**) ពួកចិត្តអាត្មានិយមទាំងឡាយនោះ ដែលពួកវាកំពុងប្រព្រឹត្តយ៉ាងគគ្លើនសព្វថ្ងៃនេះ និងដើម្បីស្រោចស្រង់ឲ្យពិភពលោកមួយនេះ ឆាប់បានរួចផុតពីទុក្ខទោសទៅ។ វិជ្ជាក៏ខំព្យាយាមដើរពន្យល់ ដល់បងប្អូនពូជសាសន៍រួមឈាម របស់ខ្លួន និងពលរដ្ឋទូទៅក្នុងលោក ឲ្យបែរមកនាំគ្នាខំប្រឹងជួយគ្នា នាំគ្នាព្យាយាមដាំបណ្តុះអំពើល្អ ជួយពង្រឹងនិងពង្រីកអំពើល្អភាពយុត្តិធម៌ ឲ្យបានកាន់តែរីកចម្រើនឡើងវិញ និងនាំគ្នាព្យាយាមវាតទីឲ្យបានធំដើម្បីពង្រីកអំពើល្អសម្រាប់ពិភពលោកទាំងមូលរបស់ពួកយើងមួយនេះបានសន្តិភាពបរិបូរ។

នេះគឺជាអារម្មណ៍ជាគោលបំណង និងជាសកម្មភាពពិតដែលចេញតែពីបេះដូងពិតសន្តានពិតចក្ខុវិស័យ និងទស្សនវិស័យភ្លឺថ្លាយ៉ាងពិតប្រាកដរបស់វិជ្ជានោះឯង។ បើនិយាយអំពីជីវភាព និងត្រកូលរបស់វិជ្ជានោះវិញ គឺថាវិជ្ជារស់នៅក្នុងត្រកូលដ៏សាមញ្ញមធ្យមមួយ ដែលវាសមរម្យល្មមសម្រាប់មនុស្សស្គាល់ប្រមាណជាមនុស្សចេះគ្រប់ វិជ្ជាបានកើតក្នុងត្រកូលថ្លៃថ្នូរមួយនេះ ហើយក៏ឋិតនៅក្នុងប្រទេសមួយនេះផងដែរ ដែលជាប្រទេសធ្លាប់តែជាប្រទេសមហានគរដែលធ្លាប់តែមានផ្ទៃដីដ៏ធំល្វឹងល្វើយលាតសន្ធឹងសន្ធៃពីមុនកន្លងមក និងធ្លាប់តែសម្បូរសប្បាយពីមុនមកផងនោះ តែសព្វថ្ងៃប្រទេសមួយនេះគឺមិនដូចអ្វីដែលមានពីមុនទៀតនោះឡើយ។ គឺត្រូវជួបរឿងអកុសល ប្រែក្លាយទៅជាលែងធំលែងសម្បូរសប្បាយ តែប្រទេសមួយនេះបែរជាកាន់តែរួមតូចទៅៗ ជិតនិងបាត់ស្រមោលបាត់អត្តសញ្ញាណ ពីផ្ទាំងផែនទីពិភពលោកនេះ ទៅវិញថែមទៀតផង។ សួរថាៈតើវាមកពីមូលហេតុអ្វី?**ចម្លើយៈ**...........; គឺទុកឲ្យអ្នកដែលកំពុងអានជាអ្នកឆ្លើយទៅចុះ។ តែវាមិនចំឡែកនោះទេ! ហើយក៏វាមិនគួរឲ្យឆ្ងល់ផងដែរ (**ព្រះពុទ្ធ**)ទ្រង់សម្តែងថា÷``**ហេតុវាយ៉ាងណា ផលគឺវាយ៉ាងនោះ**``បើក្នុងសង្គមនោះ ប្រទេសនោះ សហគមន៍គ្រួសារនោះ ដែលមានសមាជិក ឬពលរដ្ឋដែលមានចរិតគំនិតសន្តានបែបណា មេដឹកនាំប្រទេស(**រដ្ឋាភិបាល**)លទ្ធផលសម្រាប់ប្រទេសក្នុងសង្គម សហគមន៍ និង

គ្រួសារ ក៏វាយ៉ាងនោះឯងផងដែរគឺវាគ្មានអីចំឡែកនោះទេ វាសមនឹងពាក្យខ្មែរថា«**ឆ្នាំជ័ណកាគម្រប់ជីជ័**»គឺវាមិនខុសនោះទេ គឺសមហេតុសមផលហើយ។

ដូច្នេះហើយ ដើម្បីឲ្យអ្វីមួយមានការរីកចម្រើន និងបានទទួលលទ្ធផលល្អទៅបាននោះ ពិតណាស់គឺវាត្រូវអាស្រ័យទៅលើគំនិតរបស់យើងម្នាក់ៗ ត្រូវតែនាំគ្នាមក**យល់ត្រូវគិតត្រូវ**ឲ្យបានជាមុនសិន ដូចដែលយើងជាជនជាតិខ្មែរ ធ្លាប់តែបានឮចាស់ៗខ្មែរយើង សូត្រស្វាធ្យាយកន្លងមកហើយថា«**គំនិតខ្ញុំកើតកំណើតខ្ញុំមាន**» ឲ្យតែគំនិតកើតពិតណាស់ កំណើតវាត្រូវតែមាន ហើយរួមផ្សំនិងការចុះអនុវត្តផងនោះ ភាពល្អភាពរីកចម្រើនគឺវាត្រូវតែកើតយ៉ាងពិតប្រាកដ ឲ្យតែប្រជាពលរដ្ឋមានគំនិតកើត ពិតណាស់ប្រទេសជាតិនោះ មេដឹកនាំនោះ ក៏ប៉ះចំមេដឹកនាំ(**រាជរដ្ឋាភិបាល**)ជាមនុស្សមានកំណើតផងដែរ។

ទាំងនេះវាគឺជាសច្ចៈធម៌ ជាហេតុផល ជាសភាពត្រឹមត្រូវយ៉ាងពិតប្រាកដ តែទោះបីជាយើងដឹងថានោះវាជាសច្ចធម៌ ជាដំណើរត្រឹមត្រូវក៏ដោយតែវានៅតែជាអកុសលគ្រោះកាចដ៏ធំសម្រាប់សង្គមរបស់រិជ្ជាមួយនេះដដែល។ នៅក្នុងពេលបច្ចុប្បន្នសព្វថ្ងៃនេះ នៅក្នុងសតវត្សរ៍ទី**២១**នេះឯង គឺវាកំពុងតែ

ប្រែក្លាយទៅជា «**នគរឆ្កើងប្លែកសប្បាយតែក្មេងក្នុងចិត្តរង់ចាំ**» នោះទៅវិញ។ **សួរថា**:តើវាមកពីមូលហេតុអ្វី បានទៅជាបែបនេះទៅវិញនោះ? **ចម្លើយ**:គឺវាគ្មានមកពីមូលហេតុអ្វីនោះទេ ក្រៅមកតែពីបងប្អូនពូជសាសន៍រួមឈាម របស់វិជ្ជាខ្លួនឯងផ្ទាល់ហ្នឹងឯងតែម្តង ដែលសម្បូរតែមនុស្សមានចិត្តអាត្មានិយម លង់ជ្រុលហួសហេតុពេកនោះឯង ទាំងនោះហើយគឺជាមូលហេតុ នេះហើយគឺជាហេតុផល។

មូលហេតុដូចដែលបានបញ្ជាក់មកពីខាងលើនេះហើយ ដែលវាបានកំពុងតែបណ្តាលធ្វើឲ្យទ្រព្យសម្បត្តិដូនតា ដែលជាកេរ្តិ៍មរតករបស់ជាតិទាំងមូល ដែលលោកខំកសាងបន្សល់ទុក សម្រាប់ទុកឲ្យកូនចៅជំនាន់ក្រោយៗរបស់ពួកគាត់ទាំងប៉ុន្មាននោះ ក៏ត្រូវបានបាត់បង់ទៅជាបណ្តើរៗពីរមួយថ្ងៃទៅមួយថ្ងៃ បានធ្លាក់ទៅលើប្រទេសជនទៃជិតខាង ដែលនៅជុំវិញខ្លួនសព្វថ្ងៃ ជាប្រទេសសត្រូវស្ងួពូជថែមទៀតផងនោះទៅវិញ។ ដែលពួកគេតែងតែមានបំណងអាក្រក់មានមហិច្ឆតាសន្សំចិត្តចង់យកប្រទេសមួយនេះ ជាច្រើនសតវត្សរ៍កន្លងមកហើយនោះ។ ទោះបីស្ថានភាពស្រុកទេសធ្លាក់ដុនដាប់ដល់កម្រិតណាក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅសព្វថ្ងៃក្នុងប្រទេសមួយនេះ ក៏នៅតែមិនព្រមនាំគ្នាភ្ញាក់ខ្លួនទៀត ស្ទើតែបាត់បង់ប្រទេសទាំងមូល ចេញពីផែនទី

ពិភពលោកទៅហើយផងនោះ ក៏ពូជខ្មែរមួយនេះនៅតែមិនព្រមក្រោកដដែល។ ការងើបមិនរួចឬមិនព្រមនាំគ្នាងើបនោះ គឺដោយសារតែមានភាពអាត្មានិយម មានច្រើនលើសលប់ហួសហេតុហួសប្រមាណពេក ដែលចិត្តអាត្មានិយមកំពុងមាននៅក្នុងសន្ដានបេះដូង បងប្អូនពូជសាសន៍របស់វិជ្ជានោះឯង។ តែទោះបីជាស្ថានភាពធ្លាក់ដល់កម្រិតណាក៏ដោយ ទោះបីបងប្អូនពូជសាសន៍រួមឈាមមានភាពអាត្មានិយម មានច្រើនលើសលប់ហួសហេតុ មិនព្រមស្ដាប់ហេតុផល មិនព្រមនាំគ្នាខំប្រឹងភ្ញាក់រឭកយ៉ាងណាក៏ដោយ ក៏វិជ្ជានៅតែមិនបានបាក់ទឹកចិត្ត នៅតែមិនអស់ទឹកចិត្តមិនអស់សង្ឃឹម ក្នុងដំណើរការជួយសង្គ្រោះបងប្អូនរួមជាតិ និងប្រទេសជាតិ ដ៏កម្សត់របស់ខ្លួនមួយនេះដដែល។

វិជ្ជាតែងតែព្យាយាមដាក់សំនួរសួរខ្លួនឯង និងលើកទឹកចិត្តខ្លួនឯង ជារឿយៗហើយតែងតែប្រាប់ខ្លួនឯងជារៀងរហូតថា÷ «**វិជ្ជា! វិជ្ជាឯងរស់នៅបានមួយថ្ងៃ សូមរស់នៅក្នុងតម្លៃ សូមរស់នៅក្នុងការបម្រើមនសិការ ជាមនុស្សជាតិណា!**» ភាពមិនចេះអស់សង្ឃឹម និងទម្លាប់ចេះញញឹម នៅពេលជួបបញ្ហាទាំងឡាយ ដែលតែងតែជួបផ្ទាល់នៅនិងមុខជារឿយៗនោះ នោះគឺជាចំណុចដ៏ខ្លាំងរបស់វិជ្ជាដែលត្រូវប្រឈមតតាំងប្រឆាំងបំបែកនូវឧបសគ្គទាំងនោះ។ ព្រោះពេលវេលា ក្នុងជីវិតរស់នៅរបស់វិជ្ជា គឺគេ

បានធ្វើឲ្យជីវិតរបស់គេមានតម្លៃខ្លាំង់ណាស់ ក្នុងការរស់ក្នុងសង្គមរបស់គេ គេបានឲ្យតម្លៃយ៉ាងខ្ពស់ទៅលើពេលវេលា មានជីវិតរស់នៅរបស់ខ្លួនគេ គឺគេមិនបានធ្វើឲ្យជីវិតរបស់គេរស់ដោយឥតប្រយោជន៍រស់ដោយជីវិតចោលម្សៀតនោះទេ គេមិនឲ្យជីវិតគេរសើឥតប្រយោជន៍ចោលទៅជាមួយពេលវេលានោះទេ។

ដូច្នេះហើយចក្ខុវិស័យនិងទស្សនវិស័យ ពិសេសគឺបំណងពិតរបស់វិជ្ជាតែងតែសម្លឹងយ៉ាងមុតមាំយ៉ាងមុតស្រួចជារឿយៗ ទៅលើសម្បត្តិដូនតារបស់ខ្លួន ដែលត្រូវបានបាត់បង់កន្លងទៅហើយ ទៅលើកណ្ដាប់ដៃនៃប្រទេសជិតខាង ដែលនៅជុំវិញប្រទេសរបស់ខ្លួនសព្វថ្ងៃនេះ។ តែវិជ្ជាក៏នៅតែមិនអស់សង្ឃឹម ហើយក៏មិនភ្លេចខ្លួនក្នុងការជួយពង្រឹង នឹងពង្រីកគំនិតឲ្យដល់បងប្អូនពូជសាសន៍រួមឈាមរបស់ខ្លួននោះផងទេ។ វិជ្ជាតែងតែព្យាយាមត្រិះរិះ រិះគិតស្រាវជ្រាវរាវរក ពិចារណាស្វែងរកគំនិតថ្មីៗ និងទស្សនៈថ្មីៗ ក្នុងការដោះស្រាយបញ្ហាទាំងឡាយក្នុងបច្ចុប្បន្នផង និងខំស្វែងរកមធ្យោបាយផ្សេងៗបន្ថែមទៀត ដែលនិងនាំឲ្យមានការរីកចម្រើនជាច្រើនទៅមុខផង ដើម្បីដាំបណ្ដុះពង្រាយ និងពង្រីក ឲ្យបានដល់បងប្អូនពូជសាសន៍របស់ខ្លួន ឲ្យមានការចេះដឹងថាអ្វីទៅដែលមានប្រយោជន៍ និងអ្វីដែលអត់ប្រយោជន៍នោះ និងផ្ដល់ឲ្យបានដល់បងប្អូន រួមជាតិរបស់ខ្លួន ដែលកំពុងតែមានភាពអាត្មានិយមច្រើន

ផងនោះឲ្យបានដឹង និងនាំគ្នាប្រញាប់ភ្ញាក់ខ្លួនឡើងវិញ។ ដោយស្ថានភាពប្រទេសជាតិ និងចំណេះដឹងនៅមានកម្រិត ហើយទាំងជីវភាព របស់ប្រជាពលរដ្ឋក៏កាន់តែធ្លាក់ដុនដាបថែមទៀតផង និងមានតែការរីកចម្រើនផ្នែកតែជម្ងឺអាត្មានិយម នៅពាសពេញតែប្រទេសយ៉ាងទម្ងន់ថែមទៀតផងនោះ វិជ្ជាក៏កាន់តែមានការពិបាកយ៉ាងខ្លាំង ក្នុងការរកគន្លឹះគំនិតនិងទស្សនៈថ្មីៗ ដើម្បីយកមកពន្យល់ ឲ្យបានដល់បងប្អូនពូជសាសន៍របស់ខ្លួនមួយនេះផងដែរ ប៉ុន្តែក៏វាមិនពិបាកណាស់ណា ដល់បងប្អូនពូជសាសន៍របស់វិជ្ជាខ្លួនឯងផ្ទាល់នោះទេ ដែលពួកគេមិននិងខ្វីចង់ស្តាប់មិនខ្វីចង់ខ្វាយខ្វល់ ហើយព្រមទាំងដែលនាំគ្នាមកមើលងាយគំនិតផងថែមទៀតនោះ។

ដូច្នេះហើយបានធ្វើឲ្យវិជ្ជាសម្រេចចិត្ត ចំណាយយុវភាពយុវវ័យ របស់ខ្លួនគេផ្ទាល់អស់មួយជីវិតរបស់គេ ដើម្បីដើរទៅគ្រប់ទីកន្លែង គ្រប់ច្រកល្ហកដើម្បីយកគំនិតទស្សនៈ ដែលខ្លួនបានយល់ជាក់ច្បាស់ថា វាពិតជាគំនិតដ៏ត្រឹមត្រូវហើយ ដើម្បីយកទៅពន្យល់ឲ្យដល់បងប្អូនពូជសាសន៍ រួមឈាមរបស់ខ្លួនឲ្យពួកគេបានដឹង និងនាំគ្នាឆាប់ប្រញាប់លះបង់នូវភាពអាត្មានិយម( **ការគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន** )បានឆាប់ចេញពីសន្តានឲ្យអស់ហើយត្រូវតែបែរត្រឡប់មកនាំគ្នា មកយល់ពីប្រយោជន៍រួមជាសំខាន់ជាមុនសិន គឺត្រូវនាំគ្នាចេះស្រលាញ់យ៉ាងស្មុគ្រស្មោះប្តូរផ្តាច់ចេញពីបេះដូងពិតៗជា

មុន ចំពោះជាតិទឹកដីមួយនេះ។ ហើយត្រូវនាំគ្នាចេះស្តាយនឹងឲ្យចេះទាមទារ យកមកវិញ នូវមរតកសម្បត្តិដូនតា ដែលបានបាត់បង់ទៅនៅប្រទេសជិតខាង នោះយកមកវិញ ពិសេសគឺសម្បត្តិដូនតារបស់ខ្លួន ដែលបានបាត់បង់ទៅជាច្រើនសតវត្សរ៍កន្លងទៅហើយនោះ អោយចេះនាំគ្នាចង់បានទាមទាយកមកវិញ។ តែវិជ្ជាមិនដែលមានទម្លាប់បង្រៀនបណ្តុះគំនិតមិនល្អណាមួយ ឲ្យដល់ពូជសាសន៍បងប្អូនរបស់ខ្លួនសន្សំចិត្តមានភាពលោភលន់ ទៅលួចឆក់ប្លន់ទ្រព្យសម្បត្តិប្រទេសជិតខាងជុំវិញនោះទេ គឺឲ្យទាមទាយកត្រឹមតែទ្រព្យសម្បត្តិ កេរ្តិ៍មរតកដូនតារបស់ខ្លួនដែលបានបាត់ទៅ យកមកវិញតែប៉ុណ្ណោះ។

តែពិសេសជាងនេះទៅទៀតនោះ វិជ្ជាតែងតែផ្តល់គំនិតឲ្យដល់ពូជសាសន៍របស់ខ្លួនបន្ថែមទៀតថា: «**គេអាចយកទឹកដីនិងទ្រព្យសម្បត្តិរបស់ដូនតាយើងមួយចំនួនចានទៅក៏ពិតមែន តែគេមិនអាចយកប្រមាត់បេះដូងថ្លើម ដែលជាមនោសញ្ចេតនាពិត របស់ពូជសាសន៍ឈាមតែមួយដូនតាអង្គរបស់ពួកយើងបាននោះទេ**»។ប្រសិនបើបងប្អូនពូជសាសន៍របស់យើងនៅក្នុងស្រុកសព្វថ្ងៃនេះ គ្មានភាពអាត្មានិយម មិនគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍តែក្រុមគ្រួសារតែមួយមុខទេនោះ តែបែរជាមកនាំគ្នាមាន

គំនិតខ្ពស់ហួសសម្លឹងមើល ឲ្យឃើញទៅដល់ប្រយោជន៍រួមជាសំខាន់ជាមុន គឺការរៀបចំប្រទេសជាតិ និងនាំគ្នាចេះជ្រើសរើសឲ្យបាននូវមេដឹកនាំ ដែលមានចិត្តស្មោះត្រង់ឲ្យបានជាមុនសិននោះ ហើយបែរជានាំគ្នាមកឃើញប្រយោជន៍រួមយូរអង្វែងជាធំ សម្រាប់ទុកឲ្យកូនចៅជំនាន់ក្រោយៗរបស់ខ្លួនជាមុននោះ ពិតណាស់កេរ្តិ៍មរតកសម្បត្តិដូនតារបស់ពួកយើង ដែលបានបាត់បង់ទៅនៅនិងប្រទេសជទៃជិតខាងយើងជាច្រើនសតវត្សរ៍កន្លងមកហើយទាំងអម្បាលម៉ាននោះ គឺវាគង់តែនិងបានមកយើងវិញជាពុំខានឡើយ។ ហើយអ្វីៗដែលយើងកំពុងតែមានសព្វថ្ងៃនេះ គឺវានិងបានកាន់តែមានការរីកចម្រើនឡើងៗហើយក៏មិនអាចនិងបាត់បង់បន្តទៅទៀតបាននោះឡើយ។ ដូច្នេះហើយបើពួកគេចេះរក ចេះជ្រើសរើសបាននូវមេដឹកនាំប្រទេស ដែលមានទស្សនៈមានចក្ខុវិស័យសម្បូរទៅដោយចំណេះដឹងនិងគំនិតច្នៃប្រឌិតបានជាមុននោះ ដើម្បីកសាងប្រទេសសព្វថ្ងៃដែលនៅសេសសល់ទាំងប៉ុន្មាននេះ ឲ្យបានរីកចម្រើនបែបស៊ីវិល័យជាមុនបានសិននោះ ពេលនោះឯងហើយលទ្ធផលចុងក្រោយសម្បត្តិដូនតារបស់ពួកយើង ដែលបានបាត់បង់ទៅទាំងអម្បាលមាណនោះ ពិសេសគឺទឹកដីប្រាសាទ និងប្រជាពលរដ្ឋដែលជាឈាមជ័រដូនតាខ្មែរអង្គររបស់ពួកយើងទាំងប៉ុន្មាន និងបានត្រឡប់មកយើងវិញយ៉ាងងាយបំផុត។

ដូច្នេះហើយ ដើម្បីឲ្យសម្បត្តិដូនតារបស់ពួកយើង ដែលបានបាត់បង់ទៅទាំងអម្បាលមាណ នៅក្នុងកណ្ដាប់ដៃប្រទេសជិតខាង ដែលនៅជុំវិញប្រទេសយើងសព្វថ្ងៃនេះ ឲ្យបានមកយើងវិញនោះ ដូចដែលខ្ញុំបានសរសេររៀបរាប់ពីខាងលើជាហូរហែរមកហើយ យើងក៏មិនត្រូវដេកចាំបួងសួងសំពះឲ្យព្រះទេវតាព្រះឥន្ទព្រះព្រហ្ម និងអារុក្ខអារក្សអ្នកតាឬអ្នកមានបុណ្យណាឲ្យគេមកជួយយកឲ្យយើងវិញនោះក៏ទេដែរ!។ តាមពិតទៅគឺពួកលោកអ្នកទាំងនោះមិនអាចជួយយើងបានជាដាច់ខាត បើពួកយើងមិននាំគ្នាធ្វើដោយកណ្ដាប់ដៃខ្លួនឯងទេនោះ។ បើយើងជាពលរដ្ឋកំពុងរស់នៅក្នុងប្រទេស ដែលនៅសេសសល់ទាំងប៉ុន្មាននេះ ចេះនាំគ្នាជួយបណ្ដុះមនសិការបណ្ដុះអំពើល្អមនុស្សល្អនិងខំប្រឹងប្រែងព្យាយាម ត្រិះរិះពិចារណាឲ្យបានយល់ត្រូវ គិតត្រូវធ្វើត្រូវ និងចេះជ្រើសរើសមេដឹកនាំប្រទេស ដែលប្រកបដោយមនោសញ្ចេតនាមានមនសិការឧត្ដមគតិជាតិ និងចក្ខុវិស័យភ្លឺស្វាងបានជាមុននោះពិតណាស់គឺវាមិនយូរឡើយ មរតកដូនតារបស់យើងដែលបានបាត់បង់ទៅទាំងអម្បាលមាណនោះវានិងបានមកលើពូជសាសន៍យើងវិញ និងបានមកជួបជុំបងប្អូនពូជសាសន៍យើងវិញ ជាមិនខាននោះឡើយ។ នេះគឺជាបំណងពិតរបស់វិជ្ជា ហើយវិជ្ជាតែងតែពង្រឹង និងពង្រីកគំនិតឧត្ដមគតិមនសិកាទាំងនេះជារឿយៗឲ្យបានទៅដល់បងប្អូនពូជសាសន៍របស់ខ្លួនជាហូរហែរ រហូតបាន

គ្រប់ទិសទីគ្រប់កន្លែងទាំងអស់ ទីណាដែលមានវត្តមានវិជ្ជាបានទៅដល់ ទីនោះគឺត្រូវបានបណ្តុះគំនិតមនោសញ្ចេតនា ឧត្តមគតិមនសិកាជាតិដោយវិជ្ជា វិជ្ជាតែងតែធ្វើនៅសកម្មភាពបែបនេះជារឿយៗ រហូតដល់តំណាក់កាលជីវិតចុងក្រោយរបស់ខ្លួនគេ។ នេះឯងគឺជាតម្លៃពិតរបស់មនុស្ស ក្នុងការរស់នៅក្នុងសង្គមមួយជាគំរូតំណាងពិភពលោក ហើយវាក៏ជាតម្លៃពិតនៃជីវិតក្នុងការរស់នៅជារៀងរាល់ថ្ងៃរបស់វិជ្ជាខ្លួនគេនោះផ្ទាល់ផងដែរ។

# ជីជ័មោជ័លេជ័មាឌ

ជាធម្មតាមនុស្សទូទៅ គេធ្លាប់បានដឹងធ្លាប់បានស្គាល់រួចមកហើយពីរូបទីងមោង ហើយក៏គេអាចដឹងយ៉ាងជាក់ច្បាស់ពីសមត្ថភាព និងតួនាទីមុខងារ របស់ពួកវាថែមទៀតផង។ ជាទូទៅទីងមោង គេតែងតែយកទៅចងព្យួរ ឲ្យនៅក្នុងទីដីស្រែចំការ ដើម្បីសម្រាប់ទុកបង្អើលពពួកសត្វទាំងឡាយ មានសត្វចាបសត្វរលក និងសត្វដទៃផ្សេងៗទៀត។ល។ ដើម្បីកុំឲ្យពពួកសត្វទាំងនោះវាមកស៊ីស្រូវ និងផលដំណាំរបស់អ្នកស្រុក។ ហើយក៏មានទីងមោងមួយបែបទៀតដែរ ដែលគេតែងយកទៅលេងប្រគុំក្នុងកម្មវិធីផ្សេងៗទៀត ទៅតាមតែទំនៀមទម្លាប់ប្រពៃណីតាមស្រុកភូមិ ដែលគេត្រូវការយកវាទៅប្រើប្រាស់សម្រាប់យកទៅសម្តែងលេងប្រគុំនៅក្នុងកម្មវិធីណាមួយនោះឯង។ យើងធ្លាប់តែបានដឹងគ្រប់គ្នាកន្លងមកហើយ ទីមោងភាគច្រើនៗតែលេងមាឌ គឺរូបរបស់

ពួកវាធំៗប្រៀបដូចមាឌយក្សអញ្ចឹង តែជាតុពិតទៅទីងមោងទាំងនោះវាមិនមានសមត្ថភាពអីសូម្បីតែបន្តិច គ្រាន់តែនិងបំលាស់ទីដោយខ្លួនឯងហ្នឹងក៏ទៅមិនរួចផងទេ ទាំងដែលមិនមានសមត្ថភាពនិងចេះគិត ហើយទាំងដែលមិនអាចនិងនិយាយបានទៀតនោះផង រាល់ៗតែសកម្មភាពដែលរូបទីងមោងអាចបំលាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀតបាននោះ គឺសុទ្ធតែត្រូវពឹងផ្អែកទៅលើកម្លាំងរបស់មនុស្សទាំងអស់។ តែនោះវាមិនថ្មីទេ ដោយខ្ញុំគ្រាន់តែលើកយកមកនេះ គឺដើម្បីបញ្ជាក់បង្ហាញបន្តិចជាខាងដើម ទុកគ្រាន់តែជាការពិចារណាប្រៀបធៀបតែប៉ុណ្ណោះ។

ជាការពិតណាស់ក្នុងប្រទេសមួយ ត្រូវតែមានមេដឹកនាំ ឬហៅម្យ៉ាងទៀតថា(**រាជរដ្ឋាភិបាល**)ដែលត្រូវពឹងផ្អែកពីកំលាំងរបស់ពលរដ្ឋ ដែលកំពុងរស់នៅក្នុងប្រទេសនោះជាអ្នកគាំទ្រជាចាំបាច់ ដើម្បីឲ្យបុគ្គលខ្លួនបានក្លាយទៅជាមេដឹកនាំប្រទេស ឬក្លាយទៅជារាជរដ្ឋាភិបាលមួយដ៏ស្របច្បាប់សម្រាប់តំណាងប្រទេសតំណាងប្រជាពលរដ្ឋ ដោយសម្លេងឆ្នោត៥០%+១ សម្រាប់តំណាងប្រទេសមួយយ៉ាងពិតប្រាកដ គឺមិនអាចប្រកែកបាននោះឡើយ ។ តែវាពិតជាអកុសលយ៉ាងខ្លាំងសម្រាប់ស្រុកខ្មែរ និងប្រទេសមួយចំនួនទៀត ដោយនៅក្នុងសម័យកាលខ្លះប្រជាពលរដ្ឋនូវមានកម្រិតខាងចំណេះដឹងជាខ្លាំង គឺពួកគេគ្មានសមត្ថភាពក្នុងការជ្រើសរើសមេដឹកនាំល្អ

សម្រាប់ក្នុងការដឹកនាំប្រទេសរបស់ពួកគេបាននោះឡើយ តើហេតុអ្វី?តើខួររបស់ពួកគេជាខួរសត្វឬមួយខួរមនុស្ស?បើជាខួររបស់មនុស្សគឺមិនត្រូវអន់ជាសត្វនោះទេ ទោះបីជាចំណេះដឹងនូវមានកម្រិតក៏ដោយ ហេតុអ្វី បែរទៅជាជ្រើសរើសបានចំតែមនុស្សទីងមោង (**មនុស្សមិនយល់ការណ៍**) ឲ្យមកដឹកនាំប្រទេសជាតិរបស់ខ្លួននោះទៅវិញ តើពួកគេមិនដឹងថាគ្រោះថ្នាក់ធំរលាយជាតិទេរឺ?។ ហើយវាកាន់តែអកុសលហើយសែនអក័ព្ទ និងកាន់តែគ្រោះថ្នាក់បន្ថែមទៅទៀតនោះ គឺវាកាន់តែមានមនុស្សមិនយល់ការណ៍ប្រភេទមនុស្សទីមោងហ្នឹងកាន់តែមានច្រើនឡើងៗ នៅក្នុងស្រុករបស់ពួកគេ (**ពលរដ្ឋ**)ហើយសុទ្ធតែជាអ្នកមានតួនាទីធំៗ នៅក្នុងកិច្ចការរដ្ឋថែមទៀតនោះផង គឺមានពាស់ពេញប្រទេសតែម្តង។ ពាក្យ**អ្នកប្រាជ្ញខ្មែរ**មួយកន្លែងលោកបានពោលថាមនុស្សអាត្មានិយម គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន(**វាសុខចិត្តដោតផ្ទះអ្នកជិតខាង ដើម្បីយកមកស្ងោរពងមាន់វាស៊ី**) គឺវាពិតជាគួរឲ្យភ័យខ្លាចពេកណាស់ សម្រាប់អាយុជីវិតស្រុកទេសមួយទាំងមូល ដែលត្រូវបានឲ្យមនុស្សមិនយល់ការណ៍មកដឹកមុខនោះ។

(**ព្រះពុទ្ធ**)ទ្រង់ត្រាស់ថា: សេពគប់ពាលល្ងង់យកមកធ្វើជាគ្នាវានិងនាំឲ្យអន្តរាយដល់ខ្លួនជាមិនខាន់ ទោះយូរឬឆាប់វាគង់តែឲ្យផល បើវាមិនធ្វើឲ្យ

យើងដល់ថ្នាក់ស្លាប់ក៏វាធ្វើឲ្យយើងវេទនាដែរ។**សួរថា**:តើអារូបទីងមោងហ្នឹង វាពិតជាចង្រៃមែនរឺ?**ចម្លើយ**:បើចំពោះតែរូបទីងមោងពិតប្រាកដនោះ គឺវាគ្មានចង្រៃស្អីនោះទេ តែបើមនុស្សមានចិត្តគំនិត ប្រែក្លាយទៅជាមនុស្សទីងមោងវិញនោះ គឺវាច្បាស់ពេកណាស់ វាពិតជាចង្រៃមែនហើយ វាចង្រៃខ្លាំងថែមទៀតផង។ឱ! រូបមនុស្សទីងមោងដ៏សែនល្ងង់ខ្លៅអើយ! អ្នកឯងងងឹតអីក៏យ៉ាងៗនេះ!ពួកអ្នកឯងត្រូវដឹងឲ្យបានច្បាស់ អ្នកឯងធំតែមាឌទេណា!ទាំងដែលអ្នកឯងប្រហោងក្នុងទៀតផងនោះ អ្នកឯងគ្មានសមត្ថភាពឯណា ទៅដល់ថ្នាក់កាន់ការងារធំ រហូតដល់កាន់កិច្ចការងារប្រទេសជាតិ ទាំងមូលបាននោះ ដែលទៅតាមតែចំណង់ **កិលេស តណ្ហា អវិជ្ជាដ៏ងឹត** របស់ខ្លួនទៅវិញនោះ។ ហើយកុំចេះតែជឿដោរទៅតាមតែខ្យល់មាត់ ដែលចេញតែពីមាត់ពួកអាសំរាមអាម៉ែអាថោង និងពួកអាថោកទាបចិត្តអាត្មានិយមមួយចំនួន ដែលពួកវាតែងតែសរសើរលើកជើងនោះអីណា!។ អ្នកត្រូវតែដឹងឲ្យប្រាកដ «**ភាពល្ងង់ខ្លៅរបស់មេដឹកនាំ គឺជាគំនរភ្នក់ភ្លើង ដែលសម្រាប់ធ្វើឲ្យប្រទេសជាតិស្លាប់យ៉ាងពិតប្រាកដ**» ហើយអ្នកក៏ត្រូវដឹងដែរថា:«**មេដឹកនាំណា ដែលឆាប់ចេះភ្ញាក់រឭកនោះ គឺជាមេដឹកនាំដ៏គំរូ ដល់មនុស្សទូរទៅក្នុងលោកផង នាំងក្នុង**

ប្រវត្តិសាស្ត្រផង និងធ្វើឲ្យប្រទេសជាតិ ស្រស់បំព្រមយ៉ាងពិតប្រាកដផងដែរ» ខ្ញុំសូមគោរពទៅពីចម្ងាយចំពោះរដ្ឋាភិបាលថេងសេង នៃប្រទេសភូមា ដែលបានសម្រេចចិត្តចុះពីដំណែងដោយខ្លួនឯងលោកជាមេដឹកនាំមួយដ៏គំរូល្អបំផុតសម្រាប់ពិភពលោក។ បំណងល្អពីបុគ្គលត្រាស់ដឹងនិងពួកលោកអ្នកប្រាជ្ញបណ្ឌិតសប្បុរសទាំងឡាយ ក្នុងនោះមានព្រះសម្មាសម្ពុទ្ធផងដែលជាបុគ្គលត្រាស់ដឹង ដែលព្រះអង្គបានបន្សល់ទុកនូវមេរៀនខ្លឹមៗទាំងឡាយ ដែលមានអត្ថប្រយោជន៍ទុកគ្រាន់តែជាប្រយោជន៍សម្រាប់មនុស្សជាតិទូទៅ ដែលនិងកំពុងរស់នៅខាងក្រោយៗជាបន្តបន្ទាប់ក្នុងដំណើរជីវិតរស់លើភពផែនដីនេះ ដើម្បីបានរៀនយកជាប្រយោជន៍ ហើយងាយស្រួលក្នុងការពង្រីកអំពើល្អឲ្យបានដល់ពិភពលោកទាំងមូលផង ដើម្បីងាយស្រួលក្នុការយល់អព្យាស្រ័យយល់ក្នុងដំណើរផ្លូវ និងទង្វើល្អៗឲ្យបានដល់មនុស្សរួមលោកជាមួយគ្នាទូទៅ និងចេះចែករំលែកឲ្យដល់គ្នានិងគ្នា ក្នុងការរស់នៅនិងនាំគ្នាចេះផ្តល់ក្តីសុខសុភមង្គល ឲ្យបានដល់គ្នានិងគ្នានោះឯងផង។ លោកសប្បុរសអ្នកប្រាជ្ញទាំងនោះ ពួកលោកបានធ្វើប្រយោជន៍ទុកជាច្រើនរាប់មិនអស់ ច្រើនដល់ថ្នាក់ហ៊ានបូជាជីវិតរបស់ពួកលោកដើម្បីក្តីសុខដល់មនុស្សរួមលោកផង ហើយមានការងារជាច្រើនដែលពួកលោកបានបន្សល់សម្រាប់ទុកឲ្យសង្គមពិភពលោកទាំងមូលនេះ បានរួចរាល់អស់មួយចំនួនធំហើយដែរ។

នៅឡើយតែពួកយើងនោះទេ ដែលមិនទាន់បានដើរមិនទាន់បានធ្វើនោះ មកដល់តំណាក់កាលនេះពេលនេះហើយគឺថាដើរ ឬមិនដើរក៏ជារឿងរបស់ពួកយើងខ្លួនឯងនោះតែប៉ុណ្ណោះ ចំពោះពួកលោកអ្នកប្រាជ្ញសប្បុរសទាំងអស់នោះ គឺពួកលោកអស់កិច្ចការងារនិងត្រូវធ្វើបន្ទាន់ទៀតហើយ ទោះបីជានូវមានការងារមួយចំនួនខ្លះវាមិនទាន់រួចរាល់មែន តែវាជាជីវិតចុងក្រោយរបស់ពួកលោកហើយ ទោះបីជាពួកលោកនូវធ្វើបន្តទៅទៀតមិនដាច់ក្តី ក៏វាមិនមែនជាការងារត្រូវបន្ទាន់សំខាន់សម្រាប់ដំណើរជីវិតរបស់ពួកលោកទៀតនោះដែរ នោះវាគ្រាន់តែជាការងារជាបន្ទាប់បន្សំសម្រាប់ជីវិតចុងក្រោយដ៏តិចតួចរបស់ពួកលោកទេ។ នៅឡើយតែពួកយើងតែប៉ុណ្ណោះ ដែលនៅមានការងារត្រូវធ្វើជាបន្ទាន់ហើយច្រើនថែមទៀតនោះ ពីព្រោះពួកយើងនៅមានកូនរស់នៅបន្តទៀត។ បង្រៀនពន្យល់ ប្រាប់ បង្ហាញ សម្រាប់មនុស្សមានសន្តានជាមនុស្សគឺវាសមល្មមគ្រប់គ្រាន់នឹងស្តាប់គ្នាបាន និងអាចទាញយកមកធ្វើជាប្រយោជន៍បានហើយ តែផ្ទុយមកវិញសម្រាប់មនុស្សអវិជ្ជាទាំងឡាយ គឺពួកគេមិនអាចយល់បាននិងមិនទាំងនិងយកត្រចៀកយកភ្នែករបស់ពួកគេទាំងនោះ មកស្តាប់មកមើល៍សង្កេតពិនិត្យតាមដាននោះផងទេ ទោះបីជាយើងខំព្យាយាមជួយពន្យល់គ្រប់មធ្យោបាយណាក៏ដោយ ខំប្រឹងពន្យល់ប្រាប់ពីជាតុពិត និងពីទង្វើអាក្រក់ និងលទ្ធផលលំបាកដែលកើតពីទង្វើអាក្រក់ និងផ្តល់ផលអាក្រក់ អាចនិងកើត

មានដល់ពួកគេយ៉ាងណាក៏ដោយនោះក្តី ក៏ពួកគេនៅតែមិនចេះស្តាប់នូវហេតុផលក្នុងការពន្យល់របស់ពួកយើងនោះដដែល។ ដូច្នេះហើយភាពល្អអាក្រក់ គឺពួកគេមិនអាចនិងបែងចែកឲ្យបានដាច់ពីគ្នាបាននោះទេ រាល់ទង្វើរអាក្រក់ទាំងឡាយ ដែលពួកគេបានធ្លាប់តែធ្វើកន្លងមកហើយនោះ ពួកគេតែងតែយល់បានត្រឹមតែថាសកម្មភាពរបស់ពួកគេគឺល្អ វាគឺសុទ្ធតែជាទង្វើដ៏សមរម្យ សមស្របទាំងអស់ក្នុងទង្វើរបស់ពួកគេ ដែលពួកគេបានកំពុងធ្វើកន្លងមកហើយនោះ។ និយាយមួយមាត់ឲ្យខ្លីទៅគឺថា ពួកគេមិនស្គាល់ខ្លួនឯងមិនស្គាល់ទង្វើខ្លួនឯងច្បាស់ផងនោះទេ មុននឹងពួកគេបានចាប់ផ្តើមធ្វើអ្វីមួយនោះ គឺពួកគេមិនដែលនិងបានយកខួរក្បាល ជាមនុស្សរបស់ពួកគេយកមក ដើម្បីឆ្លុះបញ្ចាំងស្ទុងមើលមកក្នុងសន្តានចិត្តបេះដូង របស់ពួកគេជាមុនសិននោះទេ និងមិនដែលយកដៃរបស់ពួកគេមកស្ទាបឲ្យបានដល់អារម្មណ៍បេះដូងពិត របស់ពួកគេនោះឡើយ។ អញ្ចឹងហើយបានជារាល់ៗតែទង្វើរបស់ពួកគេភាគច្រើនៗតែភ្លៀវ ច្រើនតែផ្តល់ផលប៉ះពាល់និងភាពក្តៅក្រហាយជាច្រើនដល់ប្រយោជន៍រួម ប្រយោជន៍ជាតិនោះឯង។ វាពិតជារឿងគ្រោះថ្នាក់ខ្លាំងណាស់ នូវពេលណាដែលពួកគេយល់ឃើញនូវអំពើអាក្រក់ទៅជាល្អ សទៅជាខ្មៅ ខុសថាជាត្រូវទៅវិញនោះ។ ហើយវាកាន់តែគ្រោះជាន់លើគ្រោះទៅទៀតនោះ គឺថាគេមិនស្តាប់អ្នកណាៗទាំងអស់ ឲ្យតែពួកគេយល់យ៉ាងណាគឺពួកគេធ្វើយ៉ាងហ្នឹងហើយ។

ដូច្នេះហើយបានជាពួកគេ នៅតែព្យាយាមអាចប្រមូលបានគ្នីគ្នា នូវពពួកមនុស្សប្រភេទសន្តានប្រហាក់ប្រហែលបែបៗខ្លួនពួកគេដែលមានសន្តានប្រហាក់ប្រហែលគ្នា អាចឲ្យមកជួយគាំទ្រពួកគេ បានកាន់តែច្រើនថែមទៀតផង ទាំងដែលអាចឈានឆ្លងទៅដល់ បានកាន់ការងារស្រុកទេស គ្រប់ៗតែស្ថាប័ន បានថែមទៀតផងនោះ។ ទាំងនោះឯងហើយ វាគឺជាហេតុផលឲ្យពួកយើងនិងបានមើលឃើញថា វាជាផ្លូវនិងជាដំណើរនាំឲ្យរលំរលាយប្រទេសជាតិយ៉ាងពិតប្រាកដហើយក៏គ្មាននរណាម្នាក់អាចបដិសេធពីរឿងនេះបាននោះឡើយ។

(**ព្រះពុទ្ធ**)ទ្រង់ត្រាស់ថាខ្លួនគឺជាទីពឹងរបស់ខ្លួនណាកូន...!នោះគឺមិនខុសឡើយ ពួកយើងជាពលរដ្ឋ គឺជាមនុស្សល្អមានពូជមានពង្ស មានទាំងកូនមានទាំងចៅដែលកំពុងតែរស់នៅ ក្នុងសង្គមមួយនេះថែមទៀត ហើយវាក៏ជាសង្គមរបស់ពួកយើងទៀតផង ពិតណាស់គឺពួកយើងចង់ឲ្យកូនចៅរបស់ពួកយើងរស់បានសុខ និងចង់ឲ្យប្រទេសរបស់ពួកយើងមានមុខមាត់រីកចម្រើននិងគេដូចប្រទេសគេដទៃៗផងដែរ តើពួកយើងត្រូវធ្វើដូចម្តេច?បើស្ថានភាពពិតជាក់ស្តែងសព្វថ្ងៃប្រទេសមួយនេះ គឺត្រូវបានពពួកអាមិនយល់ការណ៍ជាអ្នកដឹកក្បាលពួកយើងនិងជាអ្នកសម្រេចកិច្ចការងារស្រុកទេសទាំងមូលជំនួសពួកយើងទៅហើយនោះ តើវាអាចធ្វើឲ្យប្រទេសជាតិនិងកូនចៅបងប្អូនបានសុខរីកចម្រើនទៅរួចកើតទេបងប្អូន?**ចម្លើយ**...............។ តើវាពិតជាសំណាង

របស់ពពួកមនុស្សទីងមោងទាំងនោះពិតមែនរឺ? ឬក៏មកតែពីអាពពួកមនុស្ស ល្អតែឆោតល្ងង់វង្វេងភាន់ច្រឡំសតិស្មារតី(**អាត្មានិយម**)ទាំងឡាយមួយ ចំនួនធំនោះ ពួកគេបែរជាទៅជួយគាំទ្រឲ្យអាពពួកមនុស្សទីងមោងទាំងនោះ មានឪកាសបានកាន់តែឡើងធ្វើធំបន្ថែមទៀតវិញនោះទេ? មិនគួរឲ្យជឿពី រឿងនេះទាល់តែសោះ តែក៏មិនសរសើរមិនជឿមិនបាន ពីព្រោះយើងឃើញស្រ ស់ៗជាក់ស្តែងនិងភ្នែកពេកហើយ ពលរដ្ឋក្នុងស្រុកមួយនេះ ត្រូវបានពពួក មនុស្សប្រភេទៗមនុស្សទីងមោងទាំងនេះ បោកបានម្តងជាពីរដង ម្តងហើយ ម្តងទៀតៗ សរុបទៅជាងមួយសតវត្សរ៍ គឺមិនគួរឲ្យជឿទាល់តែសោះឡើយ គឺ ថាជាសំណាងរបស់ពួកវាក៏ថាបាន តែតាមពិតវាមិនមែន បានមកពីសំណាង របស់ពួកវាស្អីនោះទេ។ គឺពួកគេអាចកាន់ការប្រទេសជាតិ ជាងមួយសតវត្សរ៍ កន្លងមកបាននោះ គឺដោយសារតែពួកគេចេះ ប្រមូលពពួកអាប្រភេទដូចខ្លួនគេ ឲ្យបានមកជួយគាំទ្រគ្នា និងពួកគេចេះនិយាយចាក់មនោគមន៍ដើម្បីពង្វក់ ស្មារតី ឲ្យពពួកមនុស្សល្អៗតែភ្លើ(**អាត្មានិយម**)មួយចំនួន អាចឲ្យវង្វេងក្នុង មនោគមន៍របស់ពួកគេបាន ដើម្បីឲ្យមនុស្សល្អទាំងនោះ បាននាំគ្នាមកជួយគាំ ទ្រពួកគេបានថែមទៀតផងនោះឯង បើឃើញជាក់ៗនិងភ្នែកបែបនេះហើយ មិនសរសើរមិនបានទេ។ ហេតុអ្វីបានជាពួកគេ អាចសម្រេចគោលបំណង់ ដោយមធ្យោបាយដ៏ថោកទាប នឹងអាចគ្រប់គ្រងមនុស្សមួយនគរបានយ៉ាងនេះ

ទៅវិញនោះ? ព្រោះហេតុអ្វី? វាគ្មានព្រោះហេតុអ្វី? ឬមកពីអ្វីនោះទេ ដែលក្រោមកតែពី**ភាពអវិជ្ជា** និង**ភាពអាត្មានិយម** ដ៏សែនល្ងង់ខ្លៅរបស់ពលរដ្ឋមួយចំនួនធំ ដែលមានតែគំនិតសន្តានស្មោកគ្រោកថោកទាប ជាងពពួកអាមនុស្សទីងមោងទៅទៀតផងនោះអី!ពួកគេបែរជានាំគ្នាមកជួយគាំទ្រថែមទៀតផងនោះ។ តែត្រឹមពពួកអាសន្តានថោកទាប ដូចគ្នាវាមកជួយគាំទ្រអាពពួកទីងមោងដូចគ្នានោះគឺវាមធ្យមទេ តែធំគឺពពួកមនុស្សល្អមួយចំនួនធំនោះ ដែលតែងធ្លាប់ត្រូវបានពពួកអាមនុស្សទីងមោងទាំងនោះ វាធ្វើបាបស្ទើរងាប់ស្ទើររស់ពីមុនកន្លងមកនោះ បែរជាពួកគេទាំងនោះមកនាំគ្នាជួយគាំទ្រអាមនុស្សទីងមោងឲ្យបានកាន់ការងារប្រទេសជាតិបានរាប់ជំនាន់ថែមទវិញទៀតផងដែរ។

បើពលរដ្ឋនៅក្នុងស្រុកមួយនេះចេញតែចរិតមកតែបែបៗនេះនោះ តើមានលោកព្រះណា!ដែលអាចជួយពួកគាត់បាននោះ គឺថាខ្ញុំអស់ធម៌សូត្រតែម្តងហើយខ្ញុំ។ តើពាក្យថាទីងមោងនិងពពួកអាមនុស្សទីងមោង ដែលបានកំពុងតែនិយាយមកនេះតើវាខុសគ្នាត្រង់ណាទៅបងប្អូន? គឺវាដូចតែគ្នាហ្នឹងណា...!ដូច្នេះហើយក្នុងសម័យក្រោមការដឹកនាំរបស់ពួកគេតើអ្វីទៅ ដែលជាសិទ្ធិសេរីភាពអំណាចពិតប្រាកដដែលពួកវាបានផ្តល់មកឲ្យបងប្អូន ដែលជាប្រជាពលរដ្ឋក្នុងមួយអាណត្តិៗ ដែលបងប្អូនខំទៅជួយបោះឆ្នោតឲ្យពួកវាបាន

ឡើងធ្វើធំនោះ?នៅពេលពួកគេបានដឹកនាំប្រទេសនិងគ្រប់គ្រងដឹកនាំបងប្អូនហើយនោះ តើចំណុចណាខ្លះដែលអាចធ្វើឲ្យបងប្អូនមានអារម្មណ៍ថាកក់ក្ដៅចិត្តជានិរន្តរ៍ទៅបាននោះ?តើពពួកអាមនុស្សទីងមោងទាំងនោះ ពួកគេអាចធ្វើអ្វីជាប្រាកដបានខ្លះឲ្យដល់បងប្អូនទៅ? **ឧទាហរណ៍÷**ដាក់ស្ដែងក្នុងស្រុករបស់បងប្អូនសព្វថ្ងៃ«**មេរហ័សដៃក្ងួនរហ័សភ្នែក**» គឺបងប្អូនត្រូវតែចេះ **រៀនមើល៍ រៀនតាមដាន រៀនសង្កេតពិនិត្យ** ក្នុងសម័យពួកអាមនុស្សទីងមោងដឹកនាំប្រទេសសព្វថ្ងៃនេះ តើរាល់ផ្នែកសមិទ្ធផល ក្រោមការដឹកនាំរបស់ពួកនេះទាំងប៉ុន្មាន សុទ្ធសឹងតែជាសមិទ្ធផលក្លែងក្លាយក្លែងបន្លំទាំងអស់តើអ្វីជាពិតប្រាកដទៅបងប្អូន?សូម្បីតែមួយកុំនិយាយថ្វីទៅដល់របស់ក្រៅខ្លួន សូម្បីតែរូបខ្លួនឯងផ្ទាល់ហ្នឹងក៏មិនទាំងពិតប្រាកដផងនោះ។

សូម្បីតែរូបខ្លួនឯងបក្សពួករបស់ពួកវា ក៏ស្ថិតនៅក្នុងចំណោមពពួកទីងមោង (**ពពួកាមិនយល់ការណ៍**)ផងដែរហ្នឹងនោះ តើអ្វីទៅដែលជាសកម្មភាពពិត? ហើយចុះអ្វីទៅដែលជាក្ដីសុខពិតប្រាកដរបស់បងប្អូនដែលពួកវាបានផ្ដល់មកឲ្យនោះ?**ចម្លើយ**: គឺទទេ! គឺមានតែអសន្តិសុខ មានតែភាពភ័យខ្លាចមានតែការជិះជាន់កាប់សម្លាប់លួចឆក់ប្លន់កេងប្រវ័ញ្ច កើតពាសពេញផ្ទៃប្រទេសរបស់បងប្អូនទៅវិញតែប៉ុណ្ណោះ។ និយាយឲ្យខ្លីបងប្អូន

នៅតែដេករង់ទុក្ខទោសដដែល បងប្អូនសព្វថ្ងៃ ប្រៀបបានទៅនិងត្រីចាញ់បោកនុយសន្ទូច របស់នាយសន្ទូចអញ្ចឹងតើអ្វីទៅដែលធ្វើឲ្យបងប្អូននៅតែទាក់ចិត្តជាប់ចិត្តនូវតែអាចគាំទ្រឲ្យក្រុមពពួកមនុស្សទីងមោង ឲ្យនៅបន្តការគ្រប់គ្រងដឹកនាំបងប្អូនបន្តទៅទៀតបាននោះ?តើវាមកតែពីការគិតប្រយោជន៍ផ្ទាល់ខ្លួន(**ភាពអាត្មានិយម**) របស់បងប្អូនរឺ?ឬក៏បងប្អូនយល់ថាគ្មានអ្នកណាមានសមត្ថភាពដឹកនាំកើតដូចក្រុមពួកនឹងទេមែនទេ?ពិតណាស់គេមិនមានសមត្ថភាពដឹកនាំដូចក្រុមនិងមែន តែគេមានសមត្ថភាពដឹកនាំលើសហ្នឹង ហើយល្អជាងក្រុមនេះឆ្ងាយផុតទៅទៀតផង។ បងប្អូនត្រូវដឹងថា ភាពអាត្មានិយមជាប្រភពខាងដើមរបស់មនុស្សភាគច្រើន ដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនហួសហេតុគ្មានព្រំដែននេះហើយ ដែលពួកគេអាចហ៊ានធ្វើអំពើអាក្រក់គ្រប់សព្វបែបយ៉ាង ដើម្បីបំពេញតែមហិច្ឆតាតណ្ហាដ៏ស្មោកគ្រោករបស់ខ្លួនឯងមិនចេះចប់មិនចេះឆ្អែតឆ្អន់ល្មមគ្រប់គ្រាន់ទាល់តែសោះនោះ គឺជាផ្លូវដែលកំពុងនាំឲ្យខ្លួនឯង និងប្រទេសជាតិរបស់ខ្លួន ដល់នៅសេចក្តីអន្តរាយទៅៗយ៉ាងពិតប្រាកដពីព្រោះពលរដ្ឋដែលមានតែភាពអាត្មានិយមគឺ(**គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន**)នៅក្នុងចិត្តរបស់ពួកគេហើយនោះ គឺពួកគេគិតថា ទោះបីប៉ះពាល់ប្រយោជន៍អ្នកណា ឬអ្នកណាងាប់ឯណាក៏ងាប់ទៅ កុំឡើយថាប៉ះពាល់ ឬនរណាងាប់ឯណា គឺថាពួកអាមនុស្សអាត្មានិយមទាំងនោះ គឺពួកគេនិងមិនខ្វី

គិតខ្វល់ឈឺក្បាលវានោះឡើយ វាមិនគិតទាំងដែលប្រទេសជាតិដូនតា របស់ពួកវាខំបន្សល់ទុកសម្រាប់ឲ្យពួកវា និងកូនចៅរបស់ពួកវាជាច្រើនសតវត្សរ៍កន្លងមកនោះ ខំរក្សាទុកឲ្យពួកវាបានរស់នៅរហូតមកដល់សព្វថ្ងៃ និងសម្រាប់ទុកឲ្យកូនចៅរបស់ពួកវាបានបន្តរស់បានថែមទៀតផងដែរនោះ ក៏ពួកវាមិនខ្វីនិងគិតខ្វល់ផងទេ តែផ្ទុយមកវិញគឺពួកវាគំនិតអាក្រក់ហ៊ានលក់ និងខុបខិតជាមួយនិងឈ្មួញទុច្ចរិតទាំងនៅក្នុងស្រុកនិងក្រៅស្រុក ដើម្បីលក់សម្បត្តិកេរ្តិ៍មរតកដូនតា ដែលជាព្រលឹងជាតិរបស់ខ្លួនឯង យកមកលក់ឲ្យគេទៅវិញថែមទៀត។ នេះពិតជាសន្តានដ៏ថោកទាបអត់កេរ្តិ៍ខ្មាសនៃពលរដ្ឋមួយចំនួនធំនៅក្នុងសង្គមមួយនេះ គឺថាកម្រិតចិត្តអាក្រក់របស់ពួគេដល់ថ្នាក់អស់ឈាមជ័រជាមនុស្សគឺគ្មានមនសិកាជាតិសូម្បីតែបន្តិច ដល់ថ្នាក់ហ៊ានបើកដៃឲ្យប្រទេសជិតខាង ឲ្យគេមកបំផ្លិចបំផ្លាញសម្បត្តិកេរ្តិ៍មរតកដូនតាខ្លួនឯងថែមទៀត បើមានតែគំនិតថោកទាបអាត្មានិយមបែបៗនេះ បើមិនរលាយប្រទេសទាំងមូលនោះទេ ទើបវាចំឡែក។ ឲ្យតែគេសរសើរ ឲ្យតែគេឲ្យលុយ ឲ្យតែគេឲ្យតំណែងឲ្យស្រី ។ល។ជាដើមនោះ គឺថាពួកគេវង្វេងភ្លេចប្រយោជន៍ជាតិអស់រលីងគឺយល់ព្រមបំផ្លាញជាតិគ្រប់សព្វបែបយ៉ាង។ គឺចាប់តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់កំពូល គឺថាពួកគេងើបមុខមិនរួចពីតណ្ហា និងប្រយោជន៍ផ្ទាល់ខ្លួននោះទាល់តែសោះតែម្តង។ នេះគឺជាចរិតដ៏ថោកទាបបំផុត ភាគច្រើនរបស់

ពពួកមនុស្សអាត្មានិយមទាំងនោះ ដែលពួកវាសុខចិត្តឲ្យអាពពួកមនុស្សទីងមោងដ៏ល្ងង់ខ្លៅ រូបមិនពិតប្រាកដមួយក្បាលមួយក្រុមនេះ អាចមកគ្រប់គ្រង់ក្បាលពួកខ្លួនជាបន្តបន្ទាប់ បានជាហូរហែររហូតមកទល់ដល់សព្វថ្ងៃនេះទៀតផង។ គួឲ្យសោកស្ដាយពេកណាស់ ខួរក្បាលមនុស្សមួយប្រទេស រាប់មឺនសែនលាននាក់ បែរជានាំគ្នាគិតចាញ់ខួរក្បាលពពួកអាមនុស្សទីងមោង សិប្បនិមិត្តខួរក្បាលទីមោងមួយក្រុមតូចនេះទៅវិញ ។ ពិតជាគួរឲ្យហួសចិត្តអស់សំណើចពេកណាស់ បើអ្នកពិតជាពលរដ្ឋ ដែលជាម្ចាស់ប្រទេសពិតជារូបមនុស្សចិត្តបេះដូងជាមនុស្សគំនិតប្រាជ្ញាជាមនុស្សពិតប្រាកដមែននោះ ពិតណាស់ពួកអ្នកនិងអាចយល់ពីបំណង់ បុព្វវីរបុរសដូនតាអ្នកប្រាជ្ញបណ្ឌិតរបស់ពួកអ្នក ដែលពួកលោកទាំងនោះខំលះបង់សាច់ស្រស់ឈាមស្រស់ ដើម្បីពួកអ្នកយ៉ាងពិតប្រាកដ ដែលពួកលោកសប្បុរសទាំងនោះសុខចិត្តស៊ូលះបង់ជីវិតរបស់ពួកលោក ដើម្បីការពារទឹកដីឲ្យបានគង់វង់ ទុកសម្រាប់ពួកយើងបានរស់និងទុកបន្តឲ្យកូនចៅខ្មែរគ្រប់ៗជំនាន់នៅខាងក្រោយឲ្យគ្នាបានរស់នៅនិងបានទទួលផលបានយ៉ាងពិតប្រាកដនោះ ពួកអ្នកមិនត្រូវនាំគ្នានូវស្ងៀមឈរមើលពួកអាសន្ដានខូចកាន់ការងារប្រទេសនោះទេ ពួកអ្នកត្រូវតែមានស្មារតីក្រោកឡើងនាំគ្នាជួយសង្គមរបស់ជាដាច់ខាត់។ បើឈាមពូជសាសន៍របស់អ្នកជាឈាមថ្លៃមែននោះ ពិតណាស់ពួកអ្នកត្រូវតែនាំគ្នាភ្ញាក់ខ្លួនឲ្យទាន់ពេល និង

មានមនោសញ្ចេតនារួមមួយ ត្រូវចេះអាណិតស្រឡាញ់កូនចៅ អាណិតប្រទេសជាតិ និងចេះស្តាយស្រណោះសម្បត្តិដូនតា របស់ពួកអ្នកឲ្យប្រាកដ។ ចង់មិនចង់អ្នកត្រូវតែនាំគ្នាចេះគិតសាឡើងវិញ ចង់មិនចង់អ្នកត្រូវតែគិតសាឡើងវិញ ដើម្បីនាំគ្នាជួយជាស់សតិពូជសាសន៍របស់ពួកអ្នកត្រូវនាំគ្នាចេះគិតគួរពីប្រទេសជាតិ ប្រយោជន៍រួមរបស់ពួកអ្នកជាមុនសិន សំខាន់បំផុតគឺមិនត្រូវឲ្យមានជម្ងឺវិប្បដិសារីវាត្រូវបានដេរស្តី និងមិនត្រូវទុកឲ្យក្មេងជំនាន់ក្រោយៗវាត្រូវបានដេរស្តីដាក់បណ្តាសាក្បាលពួកយើងជាដូនតា (**ជាមនុស្សកើតមុន**) នោះថាជាដូនតាល្ងង់នោះអី។ ដើម្បីកុំឲ្យពួកគេដេរក្បាលពួកយើងចារជាប្រវត្តិសាស្ត្របាននោះ ពិតណាស់ពួកយើងនៅជំនាន់នេះគឺត្រូវនាំគ្នាចេះជ្រើសរើសមើលអ្នកដឹកនាំប្រទេសល្អឲ្យមកដឹកនាំប្រទេសជាតិ របស់ពួកយើងទុកឲ្យបានជាមុនគឺរកមើលមេដឹកនាំដែលមានមនសិការឧត្តមគតិជាតិពិតប្រាកដ ទុកសម្រាប់ឲ្យពួកគេបានជាមុនឲ្យហើយនោះ ទើបអាចពួកយើងជាមនុស្សចាស់កើតមុនហ្នឹង ទើបនិងអាចរួចខ្លួនបានពីការដេរប្រទិចនិងដាក់បណ្តាសាពីពួកកូនចៅខ្មែរជំនាន់ក្រោយរបស់ពួកយើងបានយ៉ាងពិតប្រាកដ។ វាជាការពិតបើពេលហ្នឹងពួកយើងអាចជ្រើសរើសចំមេដឹកនាំដែលមានឧត្តមគតិជាតិបានពិតមែននោះ នោះទើបអាចធ្វើឲ្យគ្រួសាររបស់ពួកយើងទាំងអស់គ្នា អាចមានសុខសុវត្ថិភាពសុភមង្គលជានិរន្តរ៍ទៅបាន។

ផ្ទុយមកវិញបើអ្នកទាំងអស់គ្នា ជ្រើសរើសបានតែពពួកមនុស្ស ទីងមោង(មនុស្សមិនយល់ការណ៍)អោយមកដឹកនាំប្រទេសរបស់បងប្អូនវិញ នោះ ពិតប្រាកដណាស់ប្រទេសជាតិ របស់បងប្អូនមួយនេះគឺមិនអាចមាន ស្ថេរភាពទៅបាននោះឡើយ គឺមានតែអស្ថេរភាព អសន្តិសុខ មានតែភាពភ័យ ខ្លាច និងភាពព្រាត់ប្រាស់ជាបន្តបន្ទាប់ នៅពាសពេញតែក្នុងប្រទេសរបស់បង ប្អូនឥតល្ហែតែប៉ុណ្ណោះ។ តែបើបងប្អូនជាពលរដ្ឋចេះជ្រើសរើស មេដឹកនាំចំជា មនុស្សពិតប្រាកដបាន ជាមនុស្សមានគតិបណ្ឌិត សម្បូរទៅដោយទស្សន វិស័យចក្ខុវិស័យ និងគំនិតច្នៃប្រឌិត ក្នុងការដឹកនាំប្រទេសជាតិរបស់បងប្អូន បានពិតប្រាកដមែននោះ ប្រទេសជាតិរបស់បងប្អូននឹងប្រកបទៅដោយ ស្ថេរភាពសន្តិសុខយ៉ាងពេញលេញ និងមានក្តីសុខសុភមង្គលពេញលេញ និង មានឯករាជ្យភាពពេញលេញ សម្រាប់ប្រទេសជាតិ ក៏ដូចគ្រប់ក្រុមគ្រួសាររបស់ បងប្អូន ក៏មានសុភមង្គលពេញលេញស្ថិតស្ថេរជានិរន្តរ៍ទៅផងដែរ។ អ្នកទាំង អស់គ្នាត្រូវដឹងឲ្យបានច្បាស់ថា សេចក្តីទុក្ខរបស់ជាតិ និងសេចក្តីទុក្ខរបស់ប្រជា ពលរដ្ឋទាំងមូល មិនមែនមកតែពីកម្មពីជាតិមុននោះ វាបានមកផ្តល់ផលឲ្យ នោះទេ! តែពិតណាស់ វាមកតែពីកម្មបច្ចុប្បន្ននេះឯងតែម្តង គឺមកតែពីទង្វើរ ខុសរបស់ប្រជាពលរដ្ឋយើង នៅក្នុងប្រទេសសព្វថ្ងៃហ្នឹងដែល **គាំពុជ៍តែគិត ខុស យល់ខុស ធ្វើខុស សម្រេចខុស ជ្រើសរើសខុស ដឹង៍**

កាំពុជ៍តែតាំទ្រខុស ក្នុងបច្ចុប្បន្ននេះឯងតែម្តងគឺខុសជារឿយៗ ម្តងហើយម្តងទៀតៗ ម្តងជាពីរដង់ ដដែលជាដដែលនឹងឯង យ៉ាងពិតជាក់ស្តែងនិងហើយ ទើបបានជាបងប្អូនមានទុក្ខយ៉ាងដូច្នេះនោះ គួរតែបញ្ចប់ទៅពលរដ្ឋខ្មែររងទុក្ខយូរហើយ និងឈប់ប្រទូំបន្តទៀតទៅណាបងប្អូន។

## ភាពអសោចក្នុងគ្រួសារ

ជាការពិតជាក់ស្តែងទូទៅការបង្កើតជាក្រុមគ្រួសារមួយ គឺមិនងាយបុគ្គលណាម្នាក់អាចនិងជៀសឲ្យផុតបាននោះឡើយ បើបានមែននោះក៏មានចំនួនតិចនាក់ណាស់ ពាក្យថា«គ្រួសារ»នេះមានន័យថា ការនៅរួមការរស់នៅរួមគ្នារវាងម្តាយឪពុក និងកូនប្រុសស្រីទាំងឡាយ ដែលជាសមាជិកទាំងអស់ដែលរស់នៅក្នុងរង្វង់គ្រួសារនោះ។

ដូច្នេះហើយ ដើម្បីបង្កើតសង្គមគ្រួសារមួយ ឲ្យមាននូវសុខសុភមង្គលទៅបាននោះ ពិតណាស់គឺត្រូវតែមានការស្វែងយល់ពីគ្នានិងគ្នាជាចាំបាច់ នៅក្នុងរង្វង់សង្គមគ្រួសារនោះជាមុន គឺរវាងសមាជិកទាំងអស់ក្នុងគ្រួសាររបស់ខ្លួននោះឯង ឲ្យបានច្បាស់លាស់ជាមុនសិន។ យើងអាចនិងដាក់សំនួរសួរថា÷ បើបានប្រែក្លាយជាប្តីជាប្រពន្ធ បើកើតតែពីពោះម៉ែមួយជាមួយគ្នា ហើយនៅផ្ទះដំបូលតែមួយជាមួយគ្នាទៅហើយនោះ ចាំបាច់អីចំណាយ

ពេលមកខំសិក្សាស្វែងយល់ពីគ្នានាំឲ្យតែខាត់ពេលទៅទៀតនោះ? ពិតហើយនេះពិតជាសំនួរដ៏ត្រឹមត្រូវ ហើយក៏មិនត្រូវឲ្យសំនួរបែបៗនេះ កើតមានបន្តទៀតនោះផងដែរ អាចមិនមានសំនួរបែបៗនេះកើតមានទៀតបានទេ? តើមានអ្នកណាជាអ្នកមានចម្លើយ សម្រាប់ឆ្លើយតបទៅនិងសំនួរមួយនេះបានទៅហ្ន៎!ចម្លើយរបស់ខ្ញុំមួយផ្នែកគឺថា(**គ្រួសារខ្វះកក់ក្តៅ គ្រួសារខ្វះក្តៅក្រហាយ**)នេះគឺជាចម្លើយរបស់ខ្ញុំ សូមស្វែងយល់និងរកចម្លើយដោយខ្លួនឯងបន្ថែមទៀតទៅចុះ និយាយដោយខ្លីទៅថាគឺសំនួរមួយនេះគឺនូវតែមានវត្តមានអញ្ចឹង បើបញ្ហាបែបនេះវានូវតែកើតមានដដែលៗនោះ។ ភាពចុះសម្រុងគ្នា ភាពស្មោះត្រង់ចំពោះគ្នានិងគ្នា ទៅវិញទៅសម្រាប់សមាជិកក្នុងគ្រួសារមួយ វាជារឿងចាំចាច់ជាដំបូងបំផុតមិនអាចខ្វាះបាននោះឡើយ ត្រូវតែមានជាដាច់ខាតក្នុងគ្រួសារមួយមិនអាចប្រកែកបាននោះឡើយ បើពិតជាចង់ឲ្យមានសុខសុភមង្គល នៅក្នុងក្រុមគ្រួសារមែននោះ។ ចង់មិនចង់គឺវាត្រូវតែចេញតាមប្រទ្បោះមួយនឹង ទើបអាចឲ្យសង្គមគ្រួសារមួយនេះមានក្តីសុខសុភមង្គលរីកចម្រើនទៅបាន។ តើវាងាយស្រួលណាស់ទៅរឺ? ក្នុងកសាងបង្កើតជាសង្គមគ្រួសារមួយ សង្គមគ្រួសារមួយឲ្យមានសុខសុភមង្គល មានភាពរីកចម្រើនស្ថិតថេរជានិរន្តរ៍ទៅបាន ឬ វាពិតជាលំបាកណាស់ទៅរឺ? ត្រង់ចំនុចនេះបើតាមដំណើរច្បាប់ធម្មជាតិ ក្នុងពិភពលោកមួយនេះ គឺគ្មានអ្វីដែលថាពិបាក

ហើយក៏គ្មានអ្វីដែលថាងាយស្រួលនោះផងទេ សម្រាប់ពិភពលោកមួយនេះ។ តែអ្វីដែលជាសុខសុភមង្គលពិតប្រាកដ និងសុខសន្តិភាពពិតប្រាកដទៅបាននោះ ពិតណាស់គឺវាត្រូវស្ថិតនៅត្រង់**ឧបេក្ខាធម៌** ចន្លោះរវាងសភាពធម៌ពីរទៀតគឺ( **សុខ** និង**ទុក្ខ** ) នោះឯងយ៉ាងពិតប្រាកដ គឺគ្មានផ្លូវដទៃទៀតផ្សេងពីនេះឡើយ។ តាមដំណើរច្បាប់ធម្មជាតិនេះដដែលគឺថាអ្វីៗទាំងអស់ មិនមែនចេះតែសម្រេច ទៅតាមតែចំណង់ចិត្តចង់របស់យើងនោះទេ។ ដូច្នេះ ហើយតើពួកយើងមានសមត្ថភាពធ្វើឲ្យសង្គមគ្រួសារមួយនេះ អាចមានសុខសុភមង្គលទៅបានដែរឬទេ? អាចបាន!ហើយយ៉ាងពិតប្រាកដជាក់ច្បាស់ថែមទៀតផង ប្រសិនបើយើងចេះសិក្សាស្វែងយល់រវាងគ្នានិងគ្នា ទៅលើមនោសញ្ចេតនាជាបងជាប្អូនពីគ្នាទៅវិញទៅមក រវាងសមាជិកទាំងអស់ក្នុងគ្រួសាររបស់ខ្លួន ឲ្យបានច្បាស់ជាមុនសិននោះ។

តែវាមិនមែនសុទ្ធតែបានសម្រេចទៅតាមបំណង ដូចអ្វីដែលសមាជិកម្នាក់ៗរបស់គ្រួសារមួយចំនួនខ្លះចង់បាននោះឡើយ ទោះបីជាដឹងថាក្ដីសុខសុភមង្គលការរីកចម្រើន របស់គ្រួសារមួយចេញតែពីការយល់រវាងគ្នានិងគ្នាទៅវិញទៅមកចំពោះមនោសញ្ចេតនា ចេញតែពីភាពស្មោះត្រង់ពីការសាមគ្គីភាពគ្នា ចេញតែពីការចុះសម្រុងគ្នានោះក្ដី នោះគឺវាគ្រាន់តែបានត្រឹមតែម៉ាចេះនិយាយជជែកគ្នាមុនតែប៉ុណ្ណោះ និងត្រឹមតែនឹកស្រម៉ៃឃើញត្រូវតែមួយខណៈ

ពេលៗក្នុងខួរក្បាលរបស់ពួកគេតែប៉ុណ្ណឹងឯង តែតាមពិតជាក់ស្តែងគឺពួកគេនៅតែមិនអាចធ្វើឲ្យគ្រួសារមួយនេះ អាចនឹងក្លាយទៅជាគ្រួសារមួយមានក្តីសុខសុភមង្គលទៅបានពិតប្រាកដនូវឡើយនោះទេ។ តើមកតែពីមូលហេតុអ្វី?**ចម្លើយ**:គឺគ្មានមកពីមូលហេតុអ្វីឬមកអំពីអ្វីនោះទេ! ដែលវាក្រៅតែមកពីពួកគេមិនទុកចិត្តគ្នានិងគ្នា ដោយភាពមិនស្មោះត្រង់ចំពោះគ្នា ទៅវិញទៅមកនោះឯង សម្បត្តិត្រឹមតែជាបងប្អូនរួមផ្ទៃតែមួយជាមួយគ្នានោះ ហើយគ្រាន់តែចេះហាមាត់និយាយថា ចង់បានក្តីសុខសុភមង្គលផ្តល់ឲ្យដល់គ្រួសាររបស់ពួកយើងនោះ គឺវាពិតជាងាយស្រួលនិយាយពេកណាស់ សម្រាប់ក្នុងការនិយាយចេញមកនោះ។ ដើម្បីថាឲ្យគ្រួសារបងប្អូនរួមផ្ទៃតែមួយជាមួយគ្នា អោយមានក្តីសុខមានសុភមង្គលទៅបាននោះ បើវាមានត្រឹមតែប៉ុណ្ណឹងនោះគឺវានៅតែមិនទាន់គ្រប់គ្រាន់នៅឡើយនោះទេ បើពួកអ្នកនៅតែមិនព្រមនាំគ្នាបើកចិត្តស្តាប់ហេតុផលគ្នា ដើម្បីរកភាពត្រឹមត្រូវរកចំណុចគោលដៅរួមមិនឃើញដើម្បីមូលមតិគ្នាចុះដៃចុះជើងប្រឡូកអនុវត្តន៍ជាមុនទេនោះ ចូលកុំសង្ឃឹមថានិងមានក្តីសុខសុភមង្គលនិងរីកចម្រើនដើម្បីផ្តល់ឲ្យដល់ក្រុមគ្រួសាររបស់ពួកអ្នកមួយនេះបានឲ្យសោះ។ ដូច្នេះហើយការនិយាយពីមុនៗទាំងប៉ុន្មាន របស់ពួកអ្នកនិងការចាប់ផ្តើមចុះធ្វើរបស់ពួកអ្នកក្នុងពេលឥឡូវនេះ ពិតណាស់គឺវាមិនដែល

បានសមតាមបំណងដូចពាក្យសម្ដីដូចអ្វីៗពីកន្លងមកដែលខ្លួនពួកអ្នក ម្នាក់ៗ ដែលធ្លាប់តែបានគិត ដែលធ្លាប់តែបាននិយាយថាចង់បានពីមកនោះទេ។

សមាជិកគ្រួសារ ដែលចេញតែពីឈាមផ្ទៃម្ដាយតែមួយជាមួយគ្នា នាំគ្នារកតែសេចក្ដីសុខសុភមង្គល មកផ្ដល់ឲ្យគ្រួសាររបស់ពួកខ្លួនឲ្យបានសុខសន្តិភាពសូម្បីតែបន្តិចមិនទាំងនិងបានផងសោះនោះ តើវាសាកសមជាសមាជិកក្នុងសង្គមគ្រួសារមួយដែលមានពូជពង្សហ្នឹងគេដែរទេ?។ បងប្អូនដែលចេញតែពីពោះម្ដាយឪពុកតែមួយ នៅក្រោមដំបូលផ្ទះតែមួយ ហើយដែលធ្លាប់មានបំណងតែមួយ ដែលធ្លាប់ចង់ឲ្យគ្រួសាររបស់ខ្លួន មានសុខសុភមង្គលតាំងពីមុនមកនោះ ហើយគឺមិនមែនទើបតែនិងតាំងចិត្តថ្មីៗនោះផងទេ គឺថាវាធ្លាប់មានសុភមង្គលហ្នឹងជាច្រើនសតវត្សរ៍កន្លងមកហើយដែរនោះ តែឥឡូវបែរប្រែក្លាយទៅជាមិនទុកចិត្តចំពោះគ្នានិងគ្នា បែរជាមកប្រកាប់ប្រចាក់គ្នា មកនិយាយគ្នាស្ដាប់គ្នាលែងបាននោះទៅវិញ នោះវាពិតជាគួរឲ្យខ្មាសពិភពលោកមួយនេះខ្លាំងណាស់ នេះពិតជាទង្វើដ៏សែនអាក្រក់ជូរជាតិពិតមែន និងកំពុងតែបង្ហាញនៅភាពដ៏ថោកទាបបំផុត សម្រាប់សង្គមគ្រួសារមួយនេះយ៉ាងពិតប្រាកដ។

# រូបមនុស្សខួរសត្វ

កាលពីដើមឡើយ មានដីកោះដ៏វិចិត្រមួយដែលគេតែងតែហៅឈ្មោះថា«**កោះអច្ឆរិយៈ**»ដែលមានប្រជាពលរដ្ឋជាម្ចាស់កោះនោះ បានរស់នៅរួមគ្នាយ៉ាងមានក្តីសុខសុភមង្គលជាអនេកប្បការ។ ពីព្រោះជាទម្លាប់ក្នុងការរស់នៅរបស់ពួកគេទាំងនោះជាទូទៅ គឺពួកគេតែរស់នៅប្រកបទៅដោយក្រមសីលធម៌ គុណធម៌ សុជីវធម៌ និងមានមនោសញ្ចេតនាយ៉ាងជ្រាវជ្រៅរវាងគ្នានិងគ្នាយ៉ាងល្អនៅលើកោះមួយនេះ។ ដោយទម្លាប់រស់នៅ មានក្រមសីលធម៌ល្អយ៉ាងដូច្នេះហើយ ដែលជាហេតុបណ្តាលធ្វើឲ្យពូជសាសន៍នៅលើកោះមួយនេះ បានរស់នៅយ៉ាងមានក្តីសុខទាំងផ្លូវចិត្តត្រផ្លូវកាយនិងមានភាពមនោរម្យក្សេមក្សាន្ត យ៉ាងមានសុវត្ថិភាពសុភមង្គលនោះផង ហើយពួកគេក៏ត្រូវទទួលបាននៅតំណែលកេរ្តិ៍មរតកដ៏ពិចិត្រៗជាច្រើនលើសលប់ថែមទៀត ដែលត្រូវបានបន្សល់ទុកមកពីដូនតាដែលជាវីរបុរសជាតិរបស់ពួកគេនោះ គឺមានសម្បត្តិសព្វគ្រប់បែបយ៉ាងរាប់មិនអស់ថែមទៀត។ មរតកដ៏ពិចិត្រទាំងនោះ មានដូចជាទឹកដីភ្នំព្រៃព្រឹក្សាលតាវល្លិ៍ ប្រាសាទរាប់ពាន់រាប់ម៉ឺនប្រាសាទ សាសនា ទំនៀមទម្លាប់ប្រពៃណីវប្បធម៌ដ៏ល្អ និងមានអ្វីៗដទៃផ្សេងទៀត។ល។ ជាច្រើនថែមទៀតផង។ ដែលពួកគេត្រូវបាន ទទួលមកពីបុព្វវីរបុរសជាតិរបស់ពួកគេ ដែលជាដូនតារបស់ពួកគេ ដោយដូនតារបស់ពួកគេទាំងនោះបានខំការពារថែរក្សា និងបន្សល់ទុកតាំងតែពីច្រើនសតវត្សរ៍កន្លងមកហើយ ដើម្បីបន្សល់ទុកឲ្យមក

នោះ គឺជាសម្បត្តិសម្រាប់ទុកឲ្យពួកគេ(**ពលរដ្ឋខ្មែរសព្វថ្ងៃ**) និងកូនចៅរបស់ពួកគេនៅជំនាន់ក្រោយៗមកនេះឲ្យបានទទួលផលផងដែរ ហើយក៏បានធ្វើឲ្យពួកគេបានរស់នៅលើកោះមួយនេះ មានសុខសុភមង្គលយ៉ាងក្រៃលែងថែមទៀតផង។ កោះដ៏ពិចិត្រមួយនេះគឺជាកោះមួយ ដែលមានអ្វីៗគ្រប់សព្វបែបយ៉ាងមិនចេះខ្វះ។ ដូច្នេះហើយ បានជាគេឲ្យឈ្មោះកោះនេះថា ជា **«កោះអច្ឆរិយៈ»**។ ពិសេសលើសជាងនេះទៅទៀតនោះ ពីដើមឡើយបុព្វបុរសដូនតាជាតិរបស់ពួកគេ ដែលជាជាតិសាសន៍ដើមកំណើតជាម្ចាស់ទឹកដីម្ចាស់ដើមរបស់កោះមួយនេះ គឺសុទ្ធតែជាវីរបុរសដ៏ឆ្នើមៗ គឺជាជនជាតិពូជសាសន៍អ្នកចម្បាំង គឺជាឈាមអ្នកចម្បាំង បុព្វបុរសដែលជាដូនតារបស់ពួកគេជាម្ចាស់ទឹកដីកោះនេះពីដើមឡើយ ពួកគាត់ទាំងនោះបើនិយាយពីទឹកចិត្តចំពោះជាតិទឹកដីមាតុភូមិរបស់ពួកគាត់ទាំងនោះវិញ គឺថាពួកគាត់មានទឹកចិត្តពោរពេញទៅដោយមនសិការឧត្តមគតិជាតិទៅលើទឹកដី និងប្រជាពលរដ្ឋកូនចៅរួមឈាមរបស់ពួកគាត់មួយនេះយ៉ាងប្ដូរផ្ដាច់យ៉ាងក្រៃលែងណាស់។ ដូច្នេះហើយការចុះដៃចុះជើងធ្វើកិច្ចការងារនៅលើកោះ របស់ពួកគាត់ទាំងនោះគឺថាមហាស្រុះដៃស្រុះជើងគ្នាយ៉ាងខ្លាំង ក្នុងការការពារទឹកដីថែរក្សាទឹកដីរបស់ពួកគាត់ និងប្រជាជនកូនចៅដែលជាពូជសាសន៍របស់ពួកគាត់ទាំងនោះបានយ៉ាងល្អគង់វង់ជាទីបំផុតថែមទៀតផង គឺបាននៅសល់រហូតមកដល់សព្វថ្ងៃនេះគឺ

សម្រាប់ទុកឲ្យកូនចៅ និងមនុស្សជំនាន់ក្រោយរបស់ពួកគាត់គ្រាន់និងបានរស់នៅយ៉ាងមានសុភមង្គលបិតថេរល្អថែមទៀតផង។ ដោយមានប្រវត្តិ និងស្នាដៃដ៏ល្បីរន្ទឺបុព្វវីរបុរសជាតិ ដែលមានមនសិការជាតិ និងឧត្តមគិជាតិ យ៉ាងអង្គអាចក្លាហាន ក្នុងការឲពារទឹកដីយ៉ាងស្វិតស្វាញដូច្នេះហើយ បានជាធ្វើឲ្យកោះមួយនេះបានប្រែក្លាយទៅជាកោះមួយដ៏វិចិត្រឥតខ្ចោះ ទើបបានជាគេឲ្យប្រសិទ្ធិនាមមួយទៀតថា«**កោះពូជអ្នកចម្បាំង**»។

ដោយដូនតាជំនាន់មុនៗសុទ្ធសឹងតែជាមនុស្សមានឧត្តមគតិមនសិការជាតិ ដូច្នេះហើយ ទើបបានជាកោះមួយនេះសម្បូរ និងសេសសល់ អ្វីៗមានគ្រប់សព្វបែបយ៉ាង ដែលមិនចេះខ្វះនោះឯង។ វាមិនចំឡែកនោះទេ! ឲ្យតែសម័យកាលណាសង្គមមួយដែលមានពលរដ្ឋខ្លាំងនោះ ពិតណាស់គឺអាចធ្វើឲ្យកន្លែងរស់នៅរបស់ពួកគេទាំងនោះ ប្រែក្លាយទៅជាទឹកដីខ្លាំង ទឹកដីសន្តិភាព ជាទឹកដីមាស និងក្លាយទៅជាទឹកដីដ៏អច្ឆរិយៈ បានយ៉ាងពិតប្រាកដទៀតផង ហើយក៏អាចផ្តល់ឲ្យកូនចៅប្រជាពលរដ្ឋនៅខាងក្រោយៗ ដែលជាម្ចាស់ទឹកដីម្ចាស់ស្រុកកំណើតនៅលើកោះនោះ ក៏មាននូវសេចក្តីសុខសុវត្ថិភាពសុភមង្គល និងសន្តិភាពបានយ៉ាងពិតប្រាកដថែមទៀតផង។ ប៉ុន្តែដោយអកុសលដល់សម័យជាបន្តបន្ទាប់ជាខាងក្រោយៗមក ដោយឥតពីដូនតាជាវីរបុរសជាតិទាំងឡាយនោះទៅ ដោយកូនចៅនៅសារក្រោយមានតែភាពសប្បាយភ្លើតភ្លើនភ្លេចខ្លួន

និងភ្លេចសតិស្មារតីមានតែចិត្តអាត្មានិយម ទាំងមេដឹកនាំ(**រដ្ឋាភិបាល**)និង ពលរដ្ឋជាទូទៅដែលពួកគេនៅលើកោះនោះ ពួកគេគិតតែពីសប្បាយគ្មានគិត គ្មានគំនិត ស៊ីតែកេរ្តិ៍ដែលបានបន្សល់ទុកតែពីដូនតា ទាំងអម្បាលមាណរបស់ ពួកគេ ដែលជាបុព្វបុរសនិងវីរបុរសរបស់ពួកខ្លួនដែលបានបន្សល់ទុកពីមុនមក នោះតែប៉ុណ្ណោះ។ បែរជានាំគ្នាភ្លេចសតិ ភ្លេចស្មារតីភ្លេចខ្លួន ភ្លេចនាំគ្នាខំប្រឹង ស្វែងរករៀនសូត្រ **ក្បួនតម្រា ច្បាប់វិធី យុទ្ធសាស្ត្រ ចិត្តសាស្ត្រ និង មនោគមន៍វិជ្ជា** បន្ថែមទៀត ដើម្បីនឹងទុកសម្រាប់ការពារកោះរបស់ ពួកខ្លួនផងនោះទេ ទាំងដែលពួកគេគ្មានទស្សនវិស័យ និងចក្ខុវិស័យ(**មិន ចេះប្រមើលមើលទៅខាងមុខ**) មិនបានគិតស្មានដល់ថានឹងមានពេល សម័យកាលទេសទៅមុខ វានិងត្រូវមានការផ្លាស់ប្តូរជាបន្តបន្ទាប់ផងទេនោះ ក៏វាបានចាប់ផ្តើមបណ្តាលធ្វើឲ្យពលរដ្ឋ នៅលើកោះអច្ឆរិយៈមួយនេះ បានផុង លុងខ្លួនធ្លាក់ចុះយ៉ាងវេទនាយ៉ាងដុនដាប មានការយ៉ាប់យឺនយ៉ាងខ្លាំងជាទី បំផុតថែមទៀតផង។ ហើយបើនិយាយអំពីកោះទាំងមូលនេះវិញ ក៏បានប្រែ ក្លាយធ្លាក់ខ្លួនទៅជាកោះដ៏កម្សត់ ដល់ថ្នាក់ហៅលែងទាំងឮថែមទៀតផង។

អាចហៅម្យ៉ាងទៀតថា«**កោះដ៏សែនកំសត់**» ចាប់តាំងពីការ ធ្លាក់ចុះយ៉ាងកំហុកនោះមក កោះនេះក៏លែងមានអធិបតេយ្យភាពឯករាជ្យ និង

លែងមានសន្តិភាព ដោយខ្លួនឯងទៀតហើយ គឺត្រូវបានជាតិសាសន៍ដទៃ ដែលជាប្រទេសនៅជុំវិញកោះមួយនេះ មានឱកាសចូលមកបំពារបំពានមក ចូលមកឈ្លានពាន មកលើអាធិបតេយ្យភាពរបស់ខ្លួន ជារៀងរហូតមកដល់ សព្វថ្ងៃនេះផងដែរ។ ពួកគេ(**ពូជសាសន៍ប្រទេសជិតខាង**) បាន ព្យាយាមរកមធ្យោបាយគ្រប់សព្វបែបយ៉ាងទាំងអស់ ដើម្បីបានចូលមកបំផ្លិច បំផ្លាញសេចក្ដីសុខសន្តិភាព និងអធិបតេយ្យភាពឯករាជ្យភាពនិងសន្តិភាព នៅ លើកោះមួយនេះឲ្យខ្ទិចខ្ទីបានគ្រប់សព្វបែបយ៉ាងទាំងអស់ ពួកគេគិតរកគ្រប់ ពេលគ្រប់វេលា គ្រប់វិនាទីទាំងអស់ឲ្យតែជាអ្វីដែលពួកគេអាចបំផ្លាញបានគឺគេ បំផ្លាញទាំងអស់ តើគេធ្វើដើម្បីអី? គឺដើម្បីធ្វើឲ្យប្រទេស និងប្រជាពលរដ្ឋរបស់ ពួកគេមានឱកាស បានចូលមករស់នៅឲ្យបានស្រប់ច្បាប់តែម្ដងនោះអី! ដើម្បី បានគ្រប់គ្រងលើកោះមួយនេះនោះអី! ហើយសព្វថ្ងៃកោះមួយនេះក៏ត្រូវបាន ប្រទេសដែលនៅជុំវិញខ្លួន គេបានមកគ្រប់គ្រងស្ទើទាំងស្រុងទៅហើយ ហើយ ក៏ជិតនិងបានសម្រេចតាមបំណង ដូចអ្វីដែលគេបានប៉ងប្រាថ្នាទៅហើយ ទាំង ដែលដូនតារបស់ពួកគេធ្លាប់តែគិតចង់បាន មានបំណងចង់យកកោះមួយនេះ ជាយូរយាកន្លងមកហើយនោះឯងផង។ ដូច្នេះហើយពួកគេតែងបណ្ដុះគំនិត មនោគមន៍ឈ្លានពានវាតទីយកទឹកដីមួយនេះឲ្យខានតែបាន គឺពួកគេធ្វើដើម្បី សម្រាប់ទុកឲ្យដល់កូនចៅ និងប្រជាជនរបស់គេនៅជំនាន់ក្រោយៗឲ្យបានរស់

នៅ ហើយពួកគេក៏ខំព្យាយាមរកគ្រប់មធ្យោបាយ គ្រប់សព្វបែបយ៉ាងទាំងអស់ ដើម្បីចូលមកបំផ្លិចផ្លាញរដ្ឋបាលនៅលើកោះមួយនេះ ឲ្យទាល់តែរលាយខ្ទីចខ្ទី ទោះតាមមធ្យោបាយណាក៏ដោយ គឺដើម្បីបំពេញមហិច្ឆតារបស់ដូនតាពួកគេ និងប្រជាជាតិសាសន៍កូនចៅរបស់គេផង និងដើម្បីបំពេញបំណង់វីរបុរសជាតិ របស់ពួកគេផងនោះ ដែលជាបំណងដូនតារបស់ពួកគេ ដែលមានបំណងចង់ បានកោះនេះជាច្រើន សតវត្សរ៍កន្លងមកហើយនោះឯង។ ចាប់តាំងពីពេល នោះមក **មនោគមន៍ក្ដៅត្រជាក់ មនោគមន៍បំភាន់ភ្នែកមនោគមន៍បង្ខាន់ផ្អើដ មនោគមន៍បញ្ចុះបញ្ចូល មនោគមន៍បំបែកបំចាក មនោគមន៍ធ្វើជាបងជាប្អូនជាមិត្តមឹងឆ្នាំ** និងមានមនោគមន៍ជាច្រើនផ្សេងៗទៀត។ល។ ក៏បានបញ្ចូលមកជាបន្តបន្ទាប់ បានកំពុងធ្វើ ឲ្យពលរដ្ឋនៅលើកោះមួយនេះបានកំពុងវង្វេងវង្វាន់ លែងទុកចិត្តគ្នាលែង ស្គាល់ជាតិសាសន៍ វប្បធម៌ វីរបុរស លែងស្គាល់មនុស្សណាល្អ មនុស្សណា អាក្រក់ គឺពួកគេលែងចេះចែករំលែក លែងស្គាល់និងលែងចេះជួយពូជសាសន៍ ខ្លួនឯង ដូចពីមុនៗទៀតនោះហើយ គឺពួកគេមកពាក់មុខយក្សដាក់គ្នា ហើយ មកប្រកាប់ប្រចាក់គ្នា រកតែប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ៗទៅវិញម្ដង។ គឺថាក្នុង ខ្លួនរបស់ពួកគេ គឺមានតែភាពអាត្មានិយមរៀងៗខ្លួនតែប៉ុណ្ណោះ គិតតែពី ប្រយោជន៍ផ្ទាល់ខ្លួនរៀងៗខ្លួនជាធំ សំខាន់ជាងប្រយោជន៍ជាតិ ដែលជា

ប្រយោជន៍រួមទៅវិញ។ នេះឯងហើយដែលជាឱកាសល្អ សម្រាប់ជាតិសាសន៍ ប្រទេសដែលនៅជុំវិញកោះមួយនេះគេឆក់ឱកាស ចូលមកឈ្លានពានមកលើ កោះដ៏កំសត់មួយនេះតែម្តង ដើម្បីនិងយកកោះនេះមកគ្រប់គ្រងធ្វើជាកម្មសិទ្ធិ របស់ពួកគេ ដើម្បីបំពេញមហិច្ឆតាវីរបុរសរបស់ជាតិសាសន៍គេផង ពិសេស ជាងនេះទៅទៀតនោះពួកគេបានប្តេជ្ញានិងនាំគ្នា(**ជាំបុស្សី**)ប្តូរផ្តាច់ថាពួកគេ និងព្យាយាមយកទឹកដីកោះមួយនេះឲ្យទាល់តែបាន ដើម្បីសម្រាប់ទុកឲ្យប្រជា ពលរដ្ឋកូនចៅរបស់ពួកគេបានរស់នៅក្នុងទឹកដីនេះ ធ្វើជាកម្មសិទ្ធិតែម្តង។ ធ្លាប់តែជាទឹកដីកោះដ៏ល្បីល្បាយ ធ្លាប់តែជាកោះអច្ឆរិយៈតែឥឡូវ បែរជាប្រែក្លាយធ្លាក់មកកម្រិតជា«**ទឹកដីដ៏សែនកម្សត់**»នោះទៅវិញ។ ពិត មែនហើយវាមិនខុសទេហើយក៏វាមិនត្រូវដែរ ទាំងដែលវាមិនចម្លែកទៅទៀត ផងនោះ ហេតុអ្វីបានជាខ្ញុំនិយាយអញ្ចឹង? វាជាធម្មតាទេឲ្យតែរបស់អ្វីមួយ ដែលមនុស្សជាទូទៅគេមើលឃើញថាវាមានតម្លៃ ហើយមើលឃើញថាស្អាតល្អ នោះ ពិតណាស់មនុស្សម្នាក់ៗសុទ្ធតែមានបំណងប៉ងប្រាថ្នាចង់បានយកមកជា កម្មសិទ្ធិផ្ទាល់ខ្លួនយ៉ាងពិតប្រាកដ គឺវាគ្មានអ្វីចម្លែកនោះទេ គឺថាយើងក៏ចង់ បានគេក៏ចង់បានដែរ គឺវាមិនចម្លែកអីនោះទេ តែអ្វីដែលខុសនោះ ហើយចម្លែក ថែមទៅទៀតនោះគឺនៅត្រង់ថា របស់ដ៏មានតម្លៃមួយនេះរបស់ដ៏ស្អាតមួយនេះ គឺមានម្ចាស់ហើយ ហើយមានគេចាំថែរក្សាជាកម្មសិទ្ធិរបស់គេហើយ ហេតុអ្វី

បានជាយើងចេះតែចង់មកបំពារបំពាន ចេះតែចង់បានរបស់គេយ៉ាងគគ្លើន ថែមទៀតនោះ ?

នេះយើងនិយាយជាលក្ខណៈទូទៅបែបចិត្តមនុស្ស ដែលមានចិត្តពេញលក្ខណៈជាមនុស្ស សារជាតិជាមនុស្សលោកដូចគ្នាតែប៉ុណ្ណោះគឺពួកគេអាចនិងយល់ពីចំណុចនេះបាន។ តែផ្ទុយមកវិញចំពោះមនុស្ស ឬជាជាតិសាសន៍ដែលមានសារជាតិលក្ខណៈនិស្ស័យជាសន្តានចោរ ឬពូជសាសន៍ដែលមានសារជាតិជាចរិតលក្ខណៈនិស្ស័យសន្តានជាចោរនោះ គឺពួកវាមិនដែលយល់បែបនេះនោះទេ គឺថាពួកគេមិនអាចយល់បានទេ តែបើប្រសិនបើពួកគេយល់បានដូចគេដែរមែននោះ ក៏ពួកគេនៅតែមិនចង់យល់ដែរ ហើយពួកគេនៅតែបំពារពាននិងចង់ឈ្លានពានដដែលហ្នឹង ឲ្យតែពួកវាមើលឃើញថាមានឱកាសគឺពួកវាឈ្លានពានយកហើយ មិនខុសអីពីពាក្យថា «**សម័យកាលណាមានមនុស្សអវិជ្ជាច្រើន គុណធម៌ សីលធម៌ របស់មនុស្សនាំងនោះត្រូវតែធ្លាក់ចុះ ហើយអ្នកណាខ្លាំងអ្នកនោះរស់ អ្នកណាខ្សោយអ្នកនោះស្លាប់**»យ៉ាងនោះឯង។ ដូច្នេះហើយដោយពូជសាសន៍ ដែលធ្លាប់តែជាដើមកំណើតនឹងជាម្ចាស់ទឹកដីកោះនោះដែលមានតែសន្តានខ្លាចតែបាបរហូត សូម្បីតែនឹកគិតចង់ធ្វើបាប មិនដែលនិង

នឹកគិតឃើញផងនោះ គឺបានកំពុងតែធ្វើឲ្យជនជាតិពូជសាសន៍មួយនេះ មានចរិតស្លូតបូតរហូតដល់ស្លូតស្លាប់ ស្លូតល្ងង់ខ្លៅថែមទៀតផង។ ពីព្រោះពូជសាសន៍មួយនេះ មានសន្តានចិត្តល្អទូលាយ មានចិត្តសង្គ្រោះបែបមនុស្សល្ងង់ជាច្រើនសតវត្សរ៍កន្លងមកហើយ តាំងតែពីកំណើតដំបូងនៃកោះនេះមកម្ល៉េះ។ ហើយការអាណិតការសង្គ្រោះ របស់ពួកគេគឺមិនបានត្រូវសង្គ្រោះអាណិតត្រឹមតែក្របខ័ណ្ឌចំពោះមនុស្ស ដែលមានសារជាតិជាមនុស្សល្អនោះទេ សូម្បីតែមនុស្សមានសន្តានជាចោរសារជាតិជាចោរ ឬដល់ថ្នាក់ដឹងថាគេជាសត្រូវស៊ូពូជរបស់ខ្លួនក៏ដោយ ក៏ជនជាតិពូជសាសន៍នៅលើកោះអច្ឆរិយៈមួយនេះ ពួកគេនៅតែសង្គ្រោះអាណិតដែរ។ ដោយមានចិត្តសង្គ្រោះដោយទឹកចិត្តល្ងង់ខ្លៅ និងមានចរិតទន់ភ្លន់ហួសហេតុបែបនេះ ស្លូតស្លាប់ស្លូតល្ងង់ជ្រុលហួសហេតុ មិនចេះចប់មិនចេះហើយយ៉ាងនេះហើយ ដែលជាការបើកឱកាសឲ្យពួកអាបរទេស ជាតិសាសន៍ដែលនៅជិតខាងជុំវិញស្រុករបស់ខ្លួន ដែលមានសន្តានមហិច្ឆតាជាចោរប្រវត្តិសាស្ត្រទាំងនោះ វាកាន់តែមកមើលងាយមើលថោកមកធ្វើបាប វាកាន់តែមកបំពារបំពានឈ្លានពានទឹកដីលើកោះមួយនេះ មិនចេះចប់មិនហើយដូច្នេះនោះឯង។ តាមដែលបានសិក្សា ទៅលើប្រវត្តិសាស្ត្រ ជាហូរហែរមកនោះគឺឲ្យពួកយើងបានឃើញថា ការឈ្លានពានពីសំណាក់បរទេស ដែលមានប្រទេសនៅជុំវិញមកបំពារបំពានមកលើកោះមួយនេះ មកលើប្រជាជន

ជាតិសាសន៍ ដែលមានចរិតលក្ខណៈដ៏ទន់ភ្លន់មួយនេះ មិនមែនមកតែពីជនបរទេសទាំងនោះ គេចង់ឈ្លានពានមកលើកោះមួយនេះ ទាំងស្រុងនោះទេ គឺកំហុសដ៏ធំបំផុតនោះគឺមកតែពីពួកគេ (ម្ចាស់កោះខ្មែរ) អសមត្ថក្នុងការការពារដែនដីរបស់ពួកគេដោយខ្លួនឯងនោះទៅវិញទេ។ ហើយពិសេសជាងនេះទៅទៀតនោះ គឺពួកគេមានចរិតស្លូតនិងល្ងង់ហួសហេតុពាន់ពេក គឺថាល្ងង់ដល់កម្រិតថ្នាក់កែមិនបេះចង់ឡើងមកវិញនោះឯងហើយ ទើបបានជាគេបេះតែឈ្លានពានបែបនេះ។

# អាសូរជីវិតអ្នកក្រោដ

ជាការពិតមនុស្សជាទូទៅភាគច្រើន ដែលពួកគេបានកំពុងតែរស់នៅលើភពផែនដីទាំងមូលនេះ គឺពួកគេរស់នៅទៅតាមតែប្រពៃណី ទៅតាមតែចរិតទម្លាប់ថ្នាក់ចិត្តសាមញ្ញៗរបស់ពួកគេតែប៉ុណ្ណោះ គឺថាពួកគេគ្មានគំនិតក្នុងការខំប្រឹងអប់រំហ្វឹកហាត់ព័ទ្ធកែច្នៃឲ្យបានខ្ពស់ទៅលើអង្គកាយ និងចិត្តគំនិតរបស់ពួកគេឲ្យបានខ្ពស់នោះឡើយ ដើម្បីនឹងឲ្យបានក្លាយខ្លួនទៅជាមនុស្សមានកម្រិតទឹកចិត្តខ្ពស់ឲ្យលើសពីទម្លាប់ធម្មតា ដែលមានមនោសញ្ចេតនាខ្ពស់សម្រាប់មនុស្សជាតិទូទៅនោះទេ តែផ្ទុយមកវិញក្នុងការអប់រំហ្វឹកហាត់ ព័ទ្ធកែច្នៃអង្គកាយចិត្តរបស់ពួកគេទាំងនោះ គឺបានត្រឹមតែប្រែខ្លួនប្រែចិត្តរបស់ពួកគេក្លាយទៅជាមនុស្សចង្រៃ ជីវិត និងការរស់នៅដ៏ចង្រៃ សម្រាប់ផ្តល់ឲ្យពិភព

លោកនេះទៅវិញតែប៉ុណ្ណោះ។ តើមកពីមូលហេតុអ្វី? គឺគ្មានមកពីមូលហេតុអ្វីក្រៅតែពីភាពអំនួតអួតអាងអញនិយមនោះទេ! ធម៌អញនិយមមួយនេះ គឺជាធម៌ដ៏ចង្រៃបំផុតសម្រាប់មនុស្សជាតិទូទៅ ប្រសិនបើវាមាននៅក្នុងចិត្តមនុស្សណាម្នាក់ហើយនោះ។

(**ព្រះពុទ្ធ**):ទ្រង់ត្រាស់សម្តែងថា**អវិជ្ជា**ជាខាងដើមដែលជាឫសគល់ដ៏រឹងមាំនៃអកុសលធម៌ទាំងឡាយ ដែលជាហេតុបង្ករឲ្យមានបញ្ហាទាំងពួងជាហេតុបណ្តាលឲ្យបញ្ហាមានឱកាសបានកើតឡើងក្នុងលោកនេះមិនចេះចប់មិនចេះហើយនោះឯង។ អវិជ្ជាគឺសេចក្តីលង់ក្នុងជម្រៅនៃ**បរមត្ថធម៌** អវិជ្ជាគឺជាភាពងងឹតក្នុងជម្រៅចិត្ត ដែលវាបានធ្វើឲ្យចិត្តមិនអាចពាល់ត្រូវនូវត្រ័យលក្ខធម៌គឺ(**អនិច្ចំ ទុក្ខំ អនត្តា**)នោះឯងបានឡើយ។ យ៉ាងដូច្នេះហើយបានជា(**ព្រះពុទ្ធ**)ទ្រង់បានឲ្យតម្លៃជាខ្លាំងទៅលើការផ្តល់នូវ(**ធម្មទាន**) គឺឲ្យនូវធម៌ពន្យល់ហេតុផល ឲ្យដល់អ្នកដទៃឲ្យគេបាននូវចំណេះដឹងគឺ(**វិជ្ជា**)នោះឯង។ មនុស្សដែលមានចំណូលចូលចិត្តសិក្សា ចង់បានចំណេះដឹងដាក់ខ្លួន ចង់ចេះចង់ដឹងគឺគេត្រូវតាំងចិត្តព្យាយាមខ្លាំងណាស់ ដើម្បីទៅសួរគេនិងបានដូរយកមកវិញនូវចំណេះដឹង សូម្បីពេលដែលព្រះអង្គទ្រង់ជៀបនិងចូលបរិនិព្វានទៅហើយនោះក្តី មានភិក្ខុចង់ចេះចង់ដឹងក៏ចូលមកសួរព្រះអង្គដើម្បីឲ្យ

បាត់នូវចម្ងល់និងភាពសង្ស័យទាំងឡាយ ក៏ព្រះអង្គទ្រង់អនុញ្ញាតឲ្យចូលមកសាកសួរព្រះអង្គផងទៀត ទាំងដែលព្រះអង្គទ្រង់ជៀបនិងចូលបរិនិព្វានទៅហើយនោះ នេះឯងគឺសរបញ្ជាក់ឲ្យឃើញថា ព្រះអង្គទ្រង់ឲ្យតម្លៃខ្ពស់ខ្លាំងណាស់ទៅលើវិជ្ជាគឺ(**ចំណេះដឹង**)នោះឯង។ ព្រោះកាលណាបើមនុស្សមានចំណេះដឹងហើយ ពួកគេអាចនិងគិតបានជ្រៅជ្រះច្បាស់លាស់ ពិចារណាបានគ្រប់សព្វជ្រុងជ្រោយ បានដោយត្រឹមត្រូវមុនពេលដែលពួកគេសម្រេចចិត្តនិងធ្វើនូវអ្វីមួយ ពិសេសក្នុងកិច្ចការងារសង្គមរបស់ពួកគេនោះឯង ផ្ទាល់តែម្តង។ ជាធម្មតាការរស់នៅក្នុងសង្គមមនុស្សជាតិ ជាចាំបាច់ត្រូវការប្រាស្រ័យទាក់ទងគ្នា និងការសេពគប់មិត្តភ័ក្រ្តជាចាំបាច់នៅក្នុងសង្គម គឺថាជៀសមិនផុតនោះទេ ទោះបីតិចឬច្រើនគឺត្រូវតែមាន ខណៈពេលដែលចូលទៅប្រាស្រ័យជាមួយមិត្តភ័ក្រ្តនោះ បើប៉ះចំមិត្តល្អគឺបានទទួលមកវិញនូវទិន្នន័យល្អៗ បើទៅសេពគប់ប៉ះចំនិងមិត្តអាក្រក់ ឬក្រុមពួកអាក្រក់ និងបានទទួលផលមកវិញនូវទិន្នន័យអាក្រក់ៗនោះឯងយ៉ាងជាក់ប្រាកដ។ ដូច្នេះហើយក្នុងការរស់នៅក្នុងក្របខណ្ឌពិភពលោកជាមួយគ្នានេះ គឺមានមនុស្សរស់បែបចង្រៃក៏មាន មានមនុស្សរស់បែបសាមញ្ញៗក៏មាន មានមនុស្សរស់នាំមកនូវសេចក្តីសុខចម្រើន ឲ្យបានដល់សង្គមជាតិនិងពិភពលោកទាំងមូលនេះក៏មាន តែមានភាគតិចណាស់នៅលើភពផែនដីយើងនេះ ដែលមានមនុស្សកើតមកហើយនាំ

កំណើតរបស់ពួកគេ បាននាំប្រយោជន៍ឲ្យដល់សង្គមជាតិ និងពិភពលោករបស់ពួកគេឲ្យបានមានក្តីសុខរីកចម្រើនបាននោះ យើងអាចហៅម្យ៉ាងទៀតថា **«មនុស្សពិសេស ឬមនុស្សលើមនុស្ស»** តើមនុស្សលើមនុស្សនោះយ៉ាងដូចម្តេចទៅ? គឺថាដួងវិញ្ញាណរបស់ពួកលោកទាំងស្រុងនោះ គឺពោរពេញទៅដោយ**«មនោសញ្ចេតនា»**ឥតព្រំដែន **គឺមានមេត្តា ករុណា** ការអាណិតអាសូរស្រឡាញ់រាប់អានមនុស្សទូទាំងពិភពលោកស្មើគ្នាជាប់មិនដាច់ និងមានចរិតលក្ខណៈពីធម្មជាតិខុសពីមនុស្សសាមញ្ញគឺថា ស្អប់ភាពអត្តានិយម មិនចូលចិត្តមនុស្សណា ដែលចូលចិត្តជិះជាន់អ្នកដទៃ ចង់តែបានសុខនៅលើតែគំនរទុក្ខមនុស្សទូទៅ ដែលជាមនុស្សជាតិដូចគ្នានោះឯង នេះគឺជាចរិតពិតសន្តានពិតពីធម្មជាតិ របស់ពួកលោកអ្នកសប្បុរសទាំងនោះ តែពួកលោកនូវតែមានទឹកចិត្ត មហាករុណាគ្មានព្រំដែន ចំពោះមនុស្សសត្វទូទៅគ្មានរើសមុខដដែល។

ការមានទឹកចិត្តមនោសញ្ចេតនា ដ៏លើសលប់គ្មានព្រំដែនទៅលើមនុស្សទូទាំងសកលលោក គឺជាឱសថដ៏ពូកែយ៉ាងស័ក្តិសិទ្ធិប្រចាំជីវិត របស់ពួកលោកអ្នកត្រាស់ដឹងគ្រប់ៗអង្គ របស់ពួកលោកអ្នកប្រាជ្ញសប្បុរស អ្នកទស្សនវិទូគ្រប់ៗរូប សម្រាប់ក្នុងដំណើរជួយសង្គ្រោះ ដល់មនុស្សជាតិទូទៅក្នុងលោកនោះឯង ពិសេសពួកលោកខំជួយពង្រឹងឲ្យមានភាពរឹងមាំជាដំបូងផ្នែក

ខាងក្នុងគឺសន្តានបេះដូង និងខាងផ្លូវសតិអារម្មណ៍ជាពិសេស។ ដើម្បីឲ្យមនុស្សលោកចេះរស់នៅប្រកបទៅដោយ មនោសញ្ចេតនាល្អជាមួយនិងមនុស្សលោកដូចគ្នាជាមុនសិន ហើយក៏ពួកលោកជួយបង្ហាត់បង្រៀនមនុស្សឲ្យចេះស្វែងរកនូវសេរីភាព និងសន្តិភាពចេញពីក្នុងខ្លួនឯងផ្ទាល់ម្នាក់ៗឲ្យបានជាបន្តទៀត មុននិងធ្វើឲ្យពិភពលោកខាងក្រៅទាំងមូលនេះ បានដល់នៅសុខសន្តិភាពជានិរន្តរ៍ទៅបាននោះ ហើយនេះក៏ដើម្បីបញ្ជាក់ឲ្យឃើញពីតម្លៃពិតដែលចេញតែអំពីទង្វើដ៏បរិសុទ្ធរបស់ពួកលោកទាំងនោះ ថាជាមនុស្សស្រាលលោកនោះឯងផងដែរ។ ហើយយើងអាចនិងបានឃើញ នូវការនាំកំណើតរបស់ពួកលោក និងដំណើរជីវិតរស់នៅរបស់ពួកលោក មកលើភពផែនដីនេះក៏បាននាំភាពរីកចម្រើន និងសេចក្តីថ្លៃថ្នូរនាំសុខសន្តិភាពឲ្យពិភពលោកយើងនេះបានជាច្រើនថែមទៀតផង។ ហើយក៏មិនខុសអីពីអ្នកប្រាជ្ញទាំងឡាយ និងពួកវីរបុរសសប្បុរសអ្នកប្រាជ្ញទាំងឡាយ នៅក្នុងប្រទេសរបស់ខ្ញុំគឺ( **កម្ពុជា** ) នោះផងដែរទេ។ កម្ពុជាគឺជាទឹកដីសុវណ្ណភូមិ ហើយក៏ជាប្រទេសដែលធ្លាប់ជាទឹកដីមហានគរ ដែលមានទឹកដីដ៏ធំលាតសន្ធឹងផងដែរ ប៉ុន្តែជាខាងក្រោយជាបន្តបន្ទាប់មកប្រទេសមួយនេះត្រូវបានធ្លាក់ចុះអន់ថយខ្សោយទៅៗ ជាបន្តបន្ទាប់ទៅជាលំដាប់ គឺដោយសាតែភាព**អវិជ្ជា**របស់មេដឹកនាំ និងគំនិតល្ងង់

ខ្លៅរបស់ពលរដ្ឋជាង៩០% ក្នុងចំណោមពលរដ្ឋ១០០%នៃប្រជាជនសរុបនៅក្នុងប្រទេសមហានគរមួយនេះនោះឯង។

ហើយនូវមានពលរដ្ឋដែលមានសន្តានដែលល្អ តែនៅទាន់ផ្អឹងគឺនៅមានភាពភិតភ័យខ្លាចពីសំណាក់អំពើអាក្រក់ និងពីពពួកមនុស្សអាក្រក់ទាំងទាំងឡាយនៅក្នុងសង្គមនោះអស់ជាង៥%ផងទៀត ពលរដ្ឋដែលអាចនៅទុកចិត្តជឿជាក់ និងអាចនូវនិយាយស្តាប់គ្នាបាននោះ នៅសល់ត្រឹមប្រមាណប្រហែលជាង៤-3% តែប៉ុណ្ណោះ។ ដោយភាពកំទ្បៅនិងភាពអាត្មានិយមរបស់ពួកគេ គឺបានកំពុងតែធ្វើឲ្យខ្លួនក្នុងនាមជា(**មេដឹកនាំប្រទេស**)មួយទាំងមូល និងជាមួយប្រជាពលរដ្ឋរបស់ខ្លួនផ្ទាល់ បែរជាលែងទុកចិត្តគ្នាលែងជឿជាក់ចំពោះគ្នានោះទៅវិញ។ សម័យកាលខ្លះ មេដឹកនាំក្នុងស្រុកមួយនេះបែរជាប្រែក្លាយទៅជាសត្វក្រពើវង្វេងបឹង លែងទុកចិត្តបងប្អូនពូជសាសន៍ប្រជាពលរដ្ឋរួមឈាមឯងនោះ បែរជាទៅទុកចិត្តជឿជាក់ ទៅទុកចិត្តធ្វើតាមប្រទេសដទៃពូជសាសន៍ជាតិសាសន៍ដទៃដទៃ ដែលជាមិនមែនជាពូជសាសន៍របស់ខ្លួននោះទៅវិញ ជាពូជសាសន៍ធ្លាប់តែជាសត្រូវស៊ីសាច់ហូតឈាមចារជាប្រវត្តិសាស្ត្រ ជាសត្រូវស៊ូពូជឯងនោះទៅវិញ ។ គំនិតលីលា ត្រង់ចំណុចនេះឯងហើយដែលធ្វើឲ្យប្រទេស ដែលធ្លាប់តែជាប្រទេសមហានគរ បែរជាប្រែក្លាយទៅជាប្រទេសពលរដ្ឋ រកតែដីនៅរកតែខ្ទមជ្រកកោណនៅសព្វថ្ងៃនេះមិន

ទាំងនិងចង់បានផងនោះ។ ព្រមទាំងដែលធ្វើឲ្យពលរដ្ឋ ដែលជាម្ចាស់ប្រទេស រងនៅការឈឺចាប់ធ្វើទុក្ខទោសបុកទុក្ខម្នេញ មិនចេះចប់មិនចេះហើយថែម ទៀតផងនោះ ត្រូវបានបំពារបំពានគ្រប់សព្វបែបយ៉ាង មកលើប្រជាពលរដ្ឋខ្លួន ឯង ពីសំណាក់ពពួកអ្នកមានលុយ មានស័ក្តិ មានអំណាច គ្រប់ៗតែសម័យ កាលគ្រប់តែជំនាន់ទៅវិញនោះ។ ចាប់តាំពីក្រោយសម័យមហានគរ រហូតមក ដល់សម័យសតវត្សរ៍ទី២១នេះ គឺពលរដ្ឋខ្មែរនៅមិនទាន់និងរកក្តីសុខពិត ប្រាកដបានផងទេ ឃើញច្រើនតែសេចក្តីសុខបន្លំភ្នែក សេចក្តីសុខបិទពួន សេ ចក្តីសុខឆាកល្ខោន និងមានតែសេចក្តីសុខបាយឡុកបាយឡរតែប៉ុណ្ណោះ សេច ក្តីសុខទាំងនេះសុទ្ធសឹងតែជាសេចក្តីសុខក្លែងក្លាយ សេចក្តីសុខដ្បិនភ្នែកតែ ប៉ុណ្ណោះ ដែលត្រូវបានផ្តល់ឲ្យមកពីសំណាក់ ពពួកលោកមេដឹកនាំនៅក្នុង ប្រទេស ដ៏កំទ្បៅរបស់ពួកខ្លួននោះឯង។ ការរស់នៅរបស់ពលរដ្ឋ ពោរពេញទៅ ដោយភាពភ័យខ្លាចច្រើន ជាជាងភាពសុខស្រួល ពលរដ្ឋត្រូវមានការរង សំពៀតគំរៀមកំហែង មកពីសំណាក់ពពួកមនុស្សមានអំណាច មានលុយមាន បុណ្យស័ក្តិមួយចំនួន ដែលសព្វថ្ងៃគឺពួកគេកំពុងរស់នៅយ៉ាងសប្បាយ យ៉ាង មានសេរីភាពបែបដាច់បង្ហៀរ គឺគ្មានច្បាប់ណាមួយអាចចងពួកគេបាននោះទេ ដែលពួកគេកំពុងធ្វើមានធ្វើបាន នៅលើគំនរទុក្ខរបស់ពលរដ្ឋ ដែលរស់នៅក្នុង សង្គមជាមួយគ្នាសព្វថ្ងៃនេះទៅវិញនោះ។ (អ្នកមានដែលមានទ្រព្យតាមផ្លូវ

សុចរិតគឺយើងមិននិយាយដល់ទេ ពួកយើងជួយត្រេកអរ ហើយគ្មានពាក្យអី ក្រៅពីពាក្យថាឲ្យអ្នកកាន់តែមានសម្មាទិដ្ឋិ( យល់ត្រូវ )ជារៀងរហូតទាំងក្រុមគ្រួសារឲ្យបានគ្រប់ៗជាតិ ហើយឲ្យកាន់តែមានបានបន្ថែមទៀត និងបរិបូរដោយសេចក្ដីសុខក្នុងវង្វង់គ្រួសារជានិរន្តន៍ទៅតែប៉ុណ្ណោះ )។ លើសពីនេះទៅទៀតនោះ គឺមេដឹកនាំប្រទេសខ្លួនឯងផ្ទាល់ ដែលជាទូទៅពលរដ្ឋរបស់គេ ដែលតែងតែចាត់ទុកគេប្រៀបបានទៅនិងព្រះអាទិទេព ដូចជាម្ដាយដូចជាឪពុកអញ្ចឹងនោះ តែមេដឹកនាំទាំងនោះបែរទៅជាមានភាពពុតថ្បុត់ មានចិត្តមិនស្មោះត្រង់និងពលរដ្ឋខ្លួនឯងទៅវិញនោះ បែរជាមកមើលងាយទឹកចិត្តដ៏ស្មោះត្រង់ របស់ពលរដ្ឋដែលខំជឿទុកចិត្តទៅលើខ្លួននោះទៅវិញ ហើយមានតែទង្វើរដ៏ថោកទាប មានការលាក់បាំងភាពស្មោគគ្រោកនៅពីក្រោយខ្នង ដោយយកស្បែកចៀមមកបិទបាំងសត្វចចក ដើម្បីបន្លំធ្វើដូចជាកូនចៀមគួរឲ្យស្រឡាញ់នោះទៅវិញ ហើយបែរជាពួនសម្ងំធ្វើទង្វើដ៏ថោកទាបលាមក ក្រោមរូបភាពមនុស្សធម៌មនុស្សសប្បុរសទៅវិញ បែរជាមកគំរាមកំហែងមកលើពលរដ្ឋខ្លួនឯង ធ្វើទុក្ខបុកម្នេញផ្ដាច់ផ្ដិលជីវិតប្រជាពលរដ្ឋខ្លួនឯងនោះទៅវិញ។ អំពើទាំងប៉ុន្មាននេះសរបញ្ជាក់ឲ្យឃើញថា គឺដើម្បីតែការពារមុខតំណែងអំណាច ដ៏ថោកទាបរបស់ពួកបក្សក្រុមរបស់ខ្លួនតែប៉ុណ្ណោះ ហើយលទ្ធផលដែលទៅប្រកាប់ប្រចាក់គ្នា ដើម្បីបំពេញតែតណ្ហារខ្លួនឯងមិនចេះគ្រប់គ្រាន់នេះ គឺលទ្ធ

ផលមកវិញគឺបានត្រឹមតែ បាត់បង់ទឹកដីទ្រព្យសម្បត្តិជាកេរ្តិ៍មរតកដូនតារបស់ខ្លួន និងឲ្យតែពលរដ្ឋខ្មែរខ្លួនឯងរងនូវទុក្ខទោសជាបន្តបន្ទាប់តែប៉ុណ្ណោះ និងបានតែការបើកឱកាសឲ្យមនោគមន៍វិជ្ជាបរទេស ដែលជាសត្រូវស៊ូពូជរបស់ខ្លួនដាក់ជំនឿ ភាពជ្រួលច្រើមភាពភ្ញាក់ផ្អើលជំនឿរឥតហេតុផល ធ្វើឲ្យតែខ្មែរទន់ផ្អឹងកើនឡើងពាសពេញតែផ្ទៃប្រទេស និងកើតភាពអាណាធិបតេយ្យអសន្តិសុខកើតគ្រប់ទិសទីគ្រប់ទីកន្លែងតែប៉ុណ្ណោះ។ ចំណែកទឹកចិត្តខ្មែរដែលធ្លាប់តែមានមនោសញ្ចេតនាជាខ្លាំងពីមុនមកនោះ ក៏លែងមាននិងអាចជជែកគ្នារកហេតុផល ដើម្បីនិងកសាងជាតិសម្រាប់ទុកឲ្យពូជសាសន៍របស់ខ្លួនទាំងមូលក៏ស្ដាប់ហេតុផលគ្នាលែងកើតទៅថែមទៀត គឺមានតែការធ្លាក់ចុះរហូតដល់ថ្នាក់លែងចង់ស្គាល់គ្នានោះទៅវិញ ដែលវាជាឱកាសដ៏ល្អសម្រាប់មនោគមន៍បរទេសជិតខាង គេងាយស្រួលសាបព្រោះ និងដាក់បញ្ចូលនូវមនោគមន៍វិជ្ជាមកឲ្យពលរដ្ឋខ្មែរទាំងមូលដើម្បីឲ្យខ្មែរភ្លេចខ្លួន និងធ្វើឲ្យខ្មែរទន់ផ្អឹងកាន់តែកើនឡើងៗជាបន្តបន្ទាប់ពីមួយជំនាន់ទៅមួយជំនាន់នោះឯង។ តម្លៃសម្រាប់ជាតិសាសន៍មួយត្រូវបានធ្លាក់ចុះ ភាពថោកទាបខ្ញុំកញ្ជះគេត្រូវបានល្បីលេចឆ្លោរឡើងពាសពេញពិភពលោក សំរាប់ពូជសាសន៍មួយនេះគឺត្រូវបានល្បីទូទាំងពិភពលោកជាបន្តបន្ទាប់ ការបានទទួលនូវការគំរាមកំហែង ធ្វើបាបមកពីសំណាក់បរទេស និងប្រទេសជិតខាងសឹងតែមានរាល់ថ្ងៃ ការសម្លាប់

វីរបុរសជាតិ បណ្ឌិត អ្នកប្រាជ្ញ វីរបញ្ញវ័ន្តសង្ឃ សមណសិស្ស សមណនិស្សិត និស្សិតបញ្ញវ័ន្ត និងអ្នកស្នេហាជាតិ មានជាបន្តបន្ទាប់។ តែបែរមកមើល៍ពួកលោកជាអ្នកគ្រប់គ្រងប្រទេសវិញ ដែលពលរដ្ឋបានចាត់ទុកដូចជាម្ដាយឪពុកនោះ បែរជាពួកគេខំព្យាយាមបំភ្លៃបំភាន់បិទបាំងភ្នែកបរទេស និងពលរដ្ឋរបស់ខ្លួន ពួកគេខំព្យាយាមបំភ្លៃការពិតដើម្បីបង្ហាញពិភពបលោក អោយបានដឹងថាប្រទេសដែលបានកំពុងតែគ្រប់គ្រងដឹកនាំដោយខ្លួនសព្វថ្ងៃនេះ គឺថាកំពុងតែមានអធិបតេយ្យភាពឯកភាពជាតិសុខសន្តិភាពស្ថិតស្ថេរមានឯករាជ្យភាព និងអភិវឌ្ឍន៍មានការរីកចម្រើនបានល្អពេញលេញណាស់ទៅវិញ។ឱ!ទឹកដីសុវណ្ណភូមិ សម្បត្តិដូនតាអង្គរដ៏កំសត់ខ្ញុំអើយ! ខ្ញុំសូមតែសរសេរពាក្យពិត និយាយពិតតែប៉ុណ្ណោះ ចាប់តាំងពីសម័យក្រោយអង្គរ រហូតមកដល់សម័យសតវត្សរ៍ទី២១ នេះ ប្រទេសខ្មែរ និងកូនចៅដូនតាអង្គរគឺនៅមិនទាន់រកឯកភាពជាតិ និងឯករាជ្យភាពពិតប្រាកដណាមួយឲ្យបាននៅឡើយនោះទេណា! ដោយសំអាងទៅលើការស្រាវជ្រាវ និងសិក្សាទៅលើប្រវត្តិសាស្ត្រ និងសិក្សាតាមស្ថានភាពជាក់ស្ដែងសព្វថ្ងៃបន្ថែមទៀតនោះ ក៏បានធ្វើឲ្យយើងបានកាន់តែយល់យ៉ាងជាក់ច្បាស់ថែមទៀតថា តាំងតែពីសម័យក្រោយអង្គររហូតមក ប្រទេសមួយនេះមានមេដឹកនាំតិចនាក់ណាស់ ដែលមានឧត្តមគតិមនសិការជាតិពិតប្រាកដ និងមានបេះដូងពោរពេញទៅដោយមនោសញ្ចេតនាពិតប្រាកដ ដែលអាចហូរ

ស្រោចមកលើពលរដ្ឋរបស់ខ្លួននោះគឺវាមានតិចពេកណាស់ តាមតែខ្ញុំធ្លាប់មើលប្រវត្តិសាស្ត្រមិនច្រឡំទេនោះគឺព្រះបាទ«**ហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គឌួង**» គឺព្រះអង្គមានគតិបណ្ឌិតឧត្តមគតិមនសិកា បេះដូងព្រះអង្គផ្ទាល់គឺពោរពេញទៅដោយមនោសញ្ចេតនាហូរស្រោចចំពោះជាតិមាតុភូមិ និងប្រជាពលរដ្ឋរបស់ព្រះអង្គជាខ្លាំង ហើយក៏មានមេដឹកនាំខ្មែរមួយចំនួនផ្សេងៗទៀតផងដែរ ដែលមានឧត្តមគតិមនសិការជាតិមានមនោសញ្ចេតនាចំពោះជាតិ និងប្រជាពលរដ្ឋ ដូចព្រះអង្គឌួងខ្លះអញ្ចឹងផងដែរ។

ហើយបន្តបន្ទាប់មកក៏មានមេដឹកនាំចោលម្សៀតមិនតិចនាក់ផងដែរទេ ដែលមានភាពអាត្មានិយមនោះ ពួកគេសុខចិត្តឲ្យជាតិរបស់ពួកគេរលាយ សុខចិត្តឲ្យពលរដ្ឋខ្លួនឯង រងទុក្ខវេទនាសុខចិត្តសម្លាប់វីរបុរសជាតិខ្លួនឯងចោល កុំឲ្យតែបាត់អំណាច និងប្រយោជន៍ផ្ទាល់ខ្លួន និងពួកបក្សក្រុមគ្រួសាររបស់ពួកខ្លួននោះ គឺពួកគេមិនខ្វីខ្វល់អ្វីទាំងអស់។

**សំនួរ**:ទឹកដីដូនតាអង្គរនៅសល់ប៉ុណ្ណឹងតើដោយសារបុព្វវីរបុរសខ្មែរប្រភេទណាមួយ?ចូលជ្រើសរើសតាមសមគួរ!

**១**-មេដឹកនាំមានឧត្តមគតិមនសិការ មានមនោសញ្ចេតនាចំពោះជាតិចំពោះប្រជាពលរដ្ឋពិតប្រាកដ និងក្រុមវីរបុរសជាតិបណ្ឌិតបញ្ញាវន្ត វីរ

សមណៈ ដែលពួកលោកហ៊ានពលីជីវិត សម្រាប់ទឹកដីនិងប្រជាពលរដ្ឋរបស់ពួកលោកគ្រប់ៗជំនាន់។

២-មេដឹកនាំកំឡៅមានតែភាពអាត្មានិយម (**គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួននិងក្រុមពួកបក្សត្រកូលនិយម**) មិនគិតជាតិមិនគិតប្រជាពលរដ្ឋខ្លួន មិនទុកចិត្តពូជសាសន៍ជាតិឯង បែរជាទៅទុកចិត្តជាតិសាសន៍ដទៃដែលជាសត្រូវប្រវត្តិសាស្ត្ររបស់ខ្លួននោះទៅវិញ។

ក្រុមទាំងពីនេះតើប្រភេទចំណុចណាមួយ ដែលពលរដ្ឋខ្មែរយល់ច្បាស់ និងគាំទ្រថាជាវីរបុរសជាតិពិតប្រាកដរបស់ខ្លួននោះ?ចូលជ្រើសរើស។

តើក្នុងជំនាន់ពួកយើងក្នុងសម័យសតវត្សទី**២១**នេះ តើពួកយើងអាចនឹងជ្រើសរើសបានមេដឹកនាំដែលជាវីរបុរសជាតិ ដែលជាវីរជនសម្រាប់ដឹកនាំប្រទេស និងកសាងប្រទេសជាតិដើម្បីឲ្យរីកចម្រើន សម្រាប់ទុកឲ្យកូនចៅខ្មែរយើងនៅជំនាន់ក្រោយៗគ្នាបានរស់ស្រួលឬទេ? ឲ្យគ្នាអាចដើម្បីទទួលបាននិងស្គាល់បានថាអ្វីជាការរីកចម្រើនពិត និងសេចក្តីសុខពិតប្រាកដបានទេ?តែពលរដ្ឋខ្មែរគ្រប់ៗជំនាន់ត្រូវដឹងឲ្យបានច្បាស់ ការមិនឆាប់ប្រញាប់ព្រមភ្ញាក់រឭក និងភ្ញាក់ខ្លួន ភ្ញាក់កំណើត ភ្ញាក់សតិស្មារតី ដើម្បីធ្វើការបោះឆ្នោតទម្លាក់មេដឹកនាំប្រទេសគឺ(រដ្ឋាភិបាល)ដែលមានគំនិតខូចមានគំនិតអាត្មានិយម ដែល

ប្រកាន់តែពួកបក្សក្រុមគ្រួសារនិយមចោលទេនោះ តែបែរទៅជានាំគ្នាជួយគាំទ្រមនុស្ស និងមេដឹកនាំអាក្រក់ទាំងនោះឲ្យកាន់តែធំឡើងៗ និងកាន់តែបន្តការកាន់អំណាចបានយូរតទៅបន្ថែមទៀតនោះ បងប្អូនត្រូវយល់ឲ្យបានច្បាស់ថាធ្វើបែបនេះគឺស្មើនឹងកំពុងសម្លាប់ខ្លួនឯងហើយ ហើយក៏មានន័យថា ពួកអ្នក(**ពលរដ្ឋខ្មែរ**)គឺកំពុងតែទម្លាក់អំពើរអាយុត្តិធម៌ ទាំងអម្បាលមាណនេះទៅឲ្យវីរបុរសជាតិដែលជាវីរជនពិតប្រាកដរបស់ពួកអ្នកទាំងស្រុងហើយ ហើយកំពុងឲ្យពួកគាត់ជាអ្នកជាប់ឈ្មោះ ជាអ្នកទទួលកំហុសទាំងអស់នោះទៅវិញហើយ ស្មើនិងកំពុងយកដៃដ៏បរិសុទ្ធរបស់ពួកអ្នក(ជាប្រជាពលរដ្ឋ) ទៅទទួលកាំបិតដ៏មុតស្រួច ពីពពួកអាមនុស្សថោកទាបទាំងនោះ យកមកជួយកាត់ក្បាលបុព្វវីរបុរស និងកំពុងតែអារកវីរបុរសជាតិខ្លួនឯង ជំនួសពួកអាមនុស្សខូចទាំងនោះទៅវិញហើយណា! ទាំងដែលក្នុងមួយជីវិតរបស់ពួកលោកអ្នកប្រាជ្ញសប្បុរសទាំងនោះ ពួកលោកសុខចិត្តស៊ូលះបង់ជីវិតរបស់ខ្លួន ធ្វើដើម្បីតែប្រយោជន៍សម្រាប់ជាតិទឹកដី និងប្រជាតិរួមឈាម ប្រជាពលរដ្ឋ របស់ពួកគាត់បូករួមនិងពួកអ្នកផងនោះ ដែលពួកគាត់ស៊ូពលីជីវិត ដើម្បីតែការពារជាតិការពារប្រយោជន៍រួមសម្រាប់ឲ្យពួកយើង ដែលជាកូនចៅជំនាន់ក្រោយបានរស់នៅបានរហូតមកដល់សព្វថ្ងៃផងនោះ។

-តើអីណាទៅយុត្តិធម៌សម្រាប់វីរបុរសជាតិរបស់ពួកយើង?

-តើហេតុដូចម្ដេចបានត្រូវឲ្យវីរបុរសជាតិ ពិតប្រាកដរបស់ពួកយើងត្រូវបានជាប់ឈ្មោះថាជាអ្នកក្បត់ជាតិទៅវិញអញ្ចឹងនោះ? ដូចម្ដេចបានជាពួកអ្នកអនុញ្ញាតឲ្យគេមកសម្លាប់និងចោទវីរបុរស របស់ខ្លួនថាជាចោរប្រវត្តិសាស្ត្រទៅវិញដូច្នេះ?

-តើហេតុអ្វីបានជាអនុញ្ញាតឲ្យពួកអាក្បត់ជាតិទាំងឡាយនោះ បានក្លាយទៅជា អ្នកមានគុណនិងក្លាយទៅជាវីរបុរសជាតិទៅវិញអញ្ចឹង?

-ពលរដ្ឋ តើពួកអ្នកមិនមែនជាមនុស្សទេរឺបានជាមិនចេះមើលមនុស្សដូច្នេះ?

-តើពួកអ្នកមិនមានខួរក្បាលគិតទេរឺ?

-តើតម្លៃក្នុងការរស់ជាមនុស្សរបស់ពួកអ្នកនៅត្រង់ណា?

-តើពួកអ្នកមិនមានវិប្បដិសារីទេរឺ?

-តើអ្នកមិនចេះដាក់ទោសខ្លួនឯងទេអី?

-វាពិតជាមានវិប្បដិសារីខ្លាំងណាស់ បើអ្នកជាមនុស្សដែលសម្លាប់មនុស្សគ្មានកំហុសដូច្នេះនោះ។

-ការមើលទឹកចិត្តសង្គ្រោះមិនឃើញ គឺជារឿងអភ័ព្វរបស់សត្វ។

## ((ម៉ែឪមិនយល់ការក្លួននិជវេទនា))

នៅក្នុងសង្គមមួយពលរដ្ឋគឺជាម្ចាស់ប្រទេសយ៉ាងពិតប្រាកដ តែមិនមែនអ្នកដឹកនាំប្រទេស(**រដ្ឋាភិបាល**)តែម្នាក់ឯងនោះទេ ដែលជាម្ចាស់ប្រទេសនោះ ផ្ទុយមកវិញពួកគេ(រដ្ឋាភិបាល និងមន្ត្រីថ្នាក់ក្រោមៗ)ទាំងនោះគឺជាអ្នកបម្រើនិងជាកញ្ជះរបស់ប្រជាពលរដ្ឋទៅវិញនោះទេ។ តែដោយភាពអវិជ្ជា និងភាពល្ងង់ខ្លៅដោយមិនដឹងច្បាប់ទម្លាប់ពីរបៀប និងតួនាទីរបៀងអ្នកដឹកនាំ និងពលរដ្ឋក្នុងសង្គមរបស់ពួកខ្លួនម្នាក់បន្តិចៗនោះ ក៏បែរជាធ្វើឲ្យពួកគេទាំងសង្ខាងយល់ថា អ្នកដឹកនាំប្រទេសគឺទៅជាម្ចាស់ប្រទេស ជាមេជាម៉ែជាឪរបស់ពួកខ្លួន ដែលជាម្ចាស់ប្រទេសពិតប្រាកដនោះទៅវិញ។ ហើយក៏ឲ្យអំណាចរបស់ខ្លួនទាំងស្រុងដែលជាម្ចាស់ប្រទេសជាថៅហ្វាយគេពិតប្រាកដនោះ ទៅឲ្យគេជាអ្នកចាតចែងជំនួសខ្លួននោះទៅវិញ ហើយបែរជាមកនាំគ្នាយល់ថាពួកខ្លួនគឺជាកូនចៅជាអ្នកបម្រើគេ ក៏កើតមានអារម្មណ៍នាំគ្នាទៅជាខ្លាចគេ(**រដ្ឋាភិបាលនិជមន្ត្រី**)មួយចំនួនខ្លះនោះទៅវិញ។

ហើយបែរមកមើល៍អ្នកដឹកនាំប្រទេស(**រដ្ឋាភិបាល និជ័មន្ត្រី**) មួយចំនួនទាំងនោះ ក៏បានចាប់ផ្តើមមានចិត្តអំនួតកើតឡើង យ៉ាងចាងដៃតែម្តង គឺថាមានតែអញមុខខ្លាញ់ស៊ីដោរជានិរន្តន៍តែម្តង អញគឺត្រូវតែធំ ត្រូវតែនៅលើគេ ។ ការយល់ខុសបែបនេះ ក៏កាន់តែខុសជ្រៅទៅៗជារៀងរហូតដល់ថ្នាក់បានបណ្តាលធ្វើឲ្យអ្នកកាន់ការប្រទេសជាតិ កាន់តែមានភាពអំនួតចិត្តអាត្មានិយមពេញតែខ្លួន បណ្តាលឲ្យគេមានឱកាស (**រដ្ឋាភិបាលនិជ័មន្ត្រី**) បានគិតតែពីផលប្រយោជន៍បក្សពួក និងក្រុមគ្រួសារផ្ទាល់ខ្លួនម្នាក់ៗ របស់ពួកគេតែប៉ុណ្ណោះ។ នេះមកតែពីពលរដ្ឋជាម្ចាស់ប្រទេសល្ងង់ពេក នាំគ្នាឲ្យសិទ្ធិឲ្យអំណាចរបស់ពួកខ្លួនឲ្យគេចាត់ចែងជំនួសនោះឯង។

នៅពេលប្រទេសមានភាពអសកម្ម(**មិនប្រក្រតី**)ប្រជាពលរដ្ឋធ្វើបាតុកម្មត៌វ៉ា ពេលនោះឯងហើយមេដឹកនាំប្រទេស របស់បងប្អូនក៏ចាប់ផ្តើមដំឡើងសាច់ដុំដាក់បងប្អូនយ៉ាងពិតប្រាកដ គឺពួកគេព្យាយាមរារាំងទប់ស្កាត់ទៅលើបងប្អូនដោយគ្រប់មធ្យោបាយទាំងអស់ អោយតែគេមើល៍ឃើញថាវាជាសកម្មភាព ដែលអាចនិងធ្វើឲ្យប៉ះពាល់ដល់តំណែងពួកគេ នឹងធ្វើឲ្យខូចផលប្រយោជន៍របស់ពួកគេនោះ គឺពួកគេហ៊ានធ្វើអ្វីៗគ្រប់សព្វបែបយ៉ាងទាំងអស់មកលើពួកអ្នក(**ពលរដ្ឋ**) ដែលជាម្ចាស់ប្រទេសយ៉ាងប្រាកដ អ្នកត្រូវដឹងឲ្យ

បានច្បាស់ក្នុងចំណុចត្រង់នេះ នេះហើយដែលជាលទ្ធផលពួកអ្នកជាប្រជាពលរដ្ឋគ្មានសិទ្ធិគ្មានអំណាចក្នុងដៃនោះឯង។ ចង់សួរទៅលើពលរដ្ឋម្នាក់ៗថាតើពួកអ្នកមានជីវិតប៉ុន្មានជីវិតទៅ ដើម្បីយកមកកំដរលេងជាមួយហ្វូងខ្លាទាំងនោះ? អំពើអយុត្តិធម៌ទាំងនេះវាមិនចម្លែកអីនោះទេ ដែលកំពុងកើតឡើងចំពោះសង្គម និងពលរដ្ឋនោះ!ពីព្រោះអ្វី? ពីព្រោះគាត់គឺជាមេតំណាងតែក្រុមបក្សពួកគ្រួសាររបស់គាត់តែប៉ុណ្ណោះផលប្រយោជន៍នោះអី?ពួកគេមិនមែនជាមេតំណាងខាងយើងជា( **ពលរដ្ឋ** )នោះទេណា...! គាត់បានក្លាយទៅជាមេដឹកនាំ លុងទៅក្នុងភាពអាត្មានិយមបាត់ទៅហើយនោះអី! ដូចជាការទប់ស្កាត់មិនចង់ឲ្យពលរដ្ឋរបស់ខ្លួនមានចំណេះដឹងជាដើម គឺជាគោលដៅចម្បងរបស់មេដឹកនាំដែលមានភាពអាត្មានិយមផ្តាច់ការ និងជាមហិច្ឆតាដ៏ថោកទាបបំផុតរបស់មេដឹកនាំដ៏ល្ងង់ខ្លៅនោះឯង បងប្អូនត្រូវចេះរៀនមើល៍ ហើយនៅក្នុងស្រុកមួយសង្គមមួយឲ្យតែស្រុកណាមួយ ដែលមានមេដឹកនាំល្ងង់ខ្លៅគឺពួកគេតែងតែសម្លឹងឃើញពលរដ្ឋរបស់ខ្លួន ដែលមានចំណេះដឹងច្រើននោះឯង គឺជាឆ្អឹងទទឹងករបស់ពួកគេយ៉ាងពិតប្រាកដ ក្នុងសម័យកាលក្នុងការដឹកនាំប្រទេសរបស់ពួកគេនោះតែម្តង។ ដូច្នេះហើយអ្វីៗ ដែលធ្វើឲ្យគេមិនសប្បាយចិត្តនោះគឺថាប្រជាពលរដ្ឋដែលមានចំណេះដឹងច្រើន នឹងហ៊ានប្រឆាំង ចំពោះទង្វើអាក្រក់ថោកទាបរបស់ពួកគេ ជាអ្នកដឹកនាំនោះឯង តែផ្ទុយមកវិញពួកគេ

(**រដ្ឋាភិបាលអាត្មានិយម**) គឺគេសប្បាយចិត្តយ៉ាងខ្លាំងនៅពេលណាដែលពលរដ្ឋរបស់ពួកគេទាំងនោះល្ងង់ខ្លៅមិនចង់គិតមិនចង់ខ្វល់ខ្វាយ ក្នុងដំណើរការដឹកនាំប្រទេស ដោយអសីលធម៌របស់ខ្លួនគេនោះឯងទៅវិញ។ តើហេតុអ្វី?**ចម្លើយ**:……………….បិត្តចង្អៀតចង្អល់បេះដូងមិនព្រមបើកមានខួរតែគ្មានគំនិតគ្មានទស្សនវិស័យ គ្មានចក្ខុវិស័យមានភ្នែកតែមិនចេះមើល៍ រាល់ទង្វើរគ្មានសេរី រាល់ពាក្យសម្តីគ្មានខ្លឹមសារ គ្មានប្រយោជន៍សូម្បីតែបន្តិច តាំងពីចុងសក់រហូតដល់ចុងជើង ពោរពេញទៅដោយចិត្តអាត្មានិយម គឺគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ។

ឱ!ភាពអាត្មានិយមធម៌ចង្រៃអើយ ម្តេចឡើយ បានជាពួកឯងចូលចិត្តមកសន្ធិតនៅក្នុងសន្តានបេះដូងគំនិតខួរក្បាល មេដឹកនាំប្រទេសរបស់ខ្ញុំយ៉ាងដូច្នេះទៅវិញនោះអញ្ចឹង? ភាពអាត្មានិយម គឺច្បាស់ណាស់វាមានលក្ខណៈមានរូបទំហំបរិមាណ និងលទ្ធផលរបស់វាជាភាពអាត្មានិយម មេដឹកនាំគឺច្បាស់ណាស់ជាមេដឹកនាំ ប្រជាពលរដ្ឋគឺច្បាស់ណាស់ជាប្រជាពលរដ្ឋ អ្វីៗដទៃទៀតនោះគឺជាអ្វីៗដទៃផ្សេងទៀតតែប៉ុណ្ណោះ គឺទៅតាមតែបែបពួកផែនរបស់វា ទៅតាមតែច្បាប់ធម្មជាតិរបស់វានោះឯង។ ដូច្នេះភាពអាត្មានិយម មេដឹកនាំពលរដ្ឋនិងអ្វីៗដទៃទៀត គឺវាស្ថិតនៅក្នុងបរិយាកាសរបស់ខ្លួន រៀងៗខ្លួនរបស់ពួកវា

ពាក្យស្លោកខ្មែរមួយបានពោលថា **«បើខ្មោចស្រុកវាមិនឲ្យដៃ តើខ្មោចព្រៃឯណាវាហ៊ានមកចូលស្រុកដោះ»** បានន័យថាមិច? **ចម្លើយ**...........។ ម្យ៉ាងទៀតគេតែងនិយាយថា ពួកអពមង្គលពួកអមនុស្សទាំងឡាយ មានដូចជា ពពួកខ្មោចពពួកព្រាយបិសាច ដែលពួកវាអាចចូលមកសន្ធិតក្នុងខ្លួនមនុស្សណាម្នាក់បាននោះ ពីព្រោះមកតែពីពពួកមនុស្សទាំងនោះពួកគេជាមនុស្សមានរាសីដាក់ ឬអាចថាជាពពួកមនុស្សគ្មានបុណ្យក្នុងខ្លួននោះឯង តែសូមកុំច្រលំក្នុងចំណុចសំណោរត្រង់នេះឲ្យសោះ មិនមែនរាសីដាក់បែរជានាំគ្នាទៅនិមន្តលោក ឬអាចារ្យឲ្យមកសូត្រលើករាសីកាត់គ្រោះស្រោចទឹកដើម្បីឲ្យដាច់គ្រោះដាច់កម្ម ដើម្បីឲ្យបានឡើងរាសីវិញនោះក៏ទេ មិនមែនដើម្បីឲ្យមានបុណ្យក្នុងខ្លួន បែរជានាំគ្នាទៅបួងសួងទៅបង្កើតជារបៀបពិធីសាសនាបែបជំនឿល្ងិតល្ងង់ផ្សេងៗដែលនាំមនុស្សទៅឡប់ ដើម្បីឲ្យមានបុណ្យនៅក្នុងខ្លួននោះក៏មិនមែនដែរ សូមកុំយល់ច្រឡំក្នុងចំណុចត្រង់នេះឲ្យសោះ តែជាការពិតពួកអមនុស្សទាំងនោះ គឺពួកវាមិនហ៊ានចូលមកស្ថិតក្នុងខ្លួនពពួកមនុស្សណា ដែលមានរាសីខ្ពស់ និងមានបុណ្យគ្រប់គ្រាន់នៅក្នុងខ្លួនរបស់ពួកគេនោះយ៉ាងពិតប្រាកដមែន! យ៉ាងណាមិញភាពអាត្មានិយម និងបរិវារបស់ពួកវាទាំងឡាយ មានជាអាថ៌ដូចជាសភាពសន្តានជាចិត្តអាក្រក់ វាចាអាក្រក់ទង្វើអាក្រក់ ដែលវាបានចេញតែពីសន្តានបេះដូង ដ៏ស្មោកគ្រោក ។ល។ គឺពួកវា

ទាំងនោះ តែងតែមកស្ថិតក្នុងខ្លួនពពួកមេដឹកនាំគ្មានរាសី គ្មានបុណ្យនោះឯង យ៉ាងពិតប្រាកដ។ ហើយតែងស្ថិតនៅក្នុងខ្លួនរបស់ពលរដ្ឋណា ដែលគ្មានបុណ្យគ្មានរាសីក៏ដូច្នោះដែរ។ មិនដឹងជាមនុស្សស្អីទេ! មិនចេះស្រឡាញ់អំពើល្អនោះ!

មេដឹកនាំគឺជាមនុស្សសាធារណៈ។ ដូច្នេះហើយត្រូវតែជាមនុស្សមានពន្លឺ មានរស្មី សូមកុំប្រទាំ្បត្រង់ពាក្យថាពន្លឺ និងរស្មីនេះឲ្យសោះ មិនត្រូវយល់ទៅន័យផ្សេងៗ នាំឲ្យខុសពីបំណង់សំណេររបស់ខ្ញុំ ត្រង់ចំណុចនេះនោះឡើយ ត្រង់អត្ថន័យនៃពាក្យថា( **ពន្លឺរបស់មេដឹកនាំ** ) គឺខ្ញុំចង់និយាយសំដៅទៅលើសមត្ថភាពនិងគំនិត ជាអ្នកមានប្រាជ្ញាជាអ្នកមានទស្សនវិស័យ និងចក្ខុវិស័យដ៏ភ្លឺស្វាងរបស់មេដឹកនាំនោះ សម្រាប់ប្រទេសមួយ សម្រាប់ក្រុម សហគមន៍ និងសង្គមណាមួយតែប៉ុណ្ណោះ ឬសម្រាប់មេដឹកនាំទាំងឡាយលើពិភពលោកទាំងមូលផងដែរ។ ពិតណាស់មេដឹកនាំជាទូទៅ តែងតែមានកាតព្វកិច្ចតួនាទីជាអ្នកទទួលខុសត្រូវជាច្រើន សម្រាប់កិច្ចការងារជាប្រយោជន៍សាធារណៈ ដូចជាក្រុមសហគមន៍ សង្គម ឬពិភពលោកទាំងមូលរបស់ខ្លួន ដែលខ្លួនត្រូវមានតួនាទីកាតព្វកិច្ចក្នុងការងារថែរក្សា និងអភិវឌ្ឍន៍ឲ្យរីកចម្រើន ដើម្បីធ្វើឲ្យក្រុមសហគមន៍សង្គម និងពិភពលោករបស់ខ្លួនទាំងមូលឲ្យមានការរីកចម្រើនទៅបាន ពិតណាស់មេដឹកនាំទាំងនោះ ត្រូវតែមានការលះបង់ខ្ពស់ជាងមនុស្ស

ធម្មតាជាចាំបាច់។ ដូច្នេះហើយមេដឹកនាំត្រូវតែមានពន្លឺជានិច្ច មិនត្រូវអនុញ្ញាតឲ្យភាពអាត្មានិយម វាមានឱកាសចូលមកសន្ធំសន្ធិតគ្រប់គ្រងលើខ្លួនបាននោះឡើយ គឺត្រូវតែមានស្មារតីជានិច្ចគឺមិនត្រូវធ្វេសប្រហែសបានឡើយ ត្រង់ចំណុចនេះ ខ្ញុំចង់ឲ្យន័យមួយបែបទៀត ទៅតាមគំនិតស្មោះត្រង់ចំណុចពាក្យថា«**មេដឹកនាំ**» ក្នុងគោលបំណងសរសេរនេះ មេដឹកនាំមានន័យថា **«មនុស្សស្រឡាញ់អំពើល្អ ធ្វើអំពើល្អ ចូលចិត្តពង្រីក និងចូលចិត្តនាំបណ្ដុះអំពើល្អ»** គឺគិតប្រយោជន៍រួមជាធំ។

ដូច្នេះពាក្យថា«**ល្អ**»នេះមនុស្សណាក៏ចង់បានត្រូវការវាដែរ កុំឡើយនិយាយដល់មនុស្សដែលមានសន្ដានជាមនុស្ស សូម្បីតែមនុស្សមានសន្ដានជាចោរ ក៏វាចង់បានពាក្យថាល្អនិងភាពល្អស្មោះត្រង់ហ្នឹងឯងដែរ បើមាននរណាម្នាក់ ឬក្រុមប៉ូលិសចាប់វាបាននោះ ហើយនិងយកពួកវាមកសួរថា តើលោកចោរឯងចង់បានសេចក្ដីសុខសេចក្ដីល្អ និងភាពស្មោះត្រង់ទេ? ពិតណាស់ពួកលោកចោរទាំងនោះ ពួកវានិងឆ្លើយថាខ្ញុំពិតជាចង់បានសេចក្ដីល្អ និងសេចក្ដីសុខនិងភាពស្មោះត្រង់នេះខ្លាំងណាស់។ សូម្បីតែចោរដែលជាទូទៅគេតែងតែដឹង និងចាត់ទុកថាពួកវាជាមនុស្សអាក្រក់ពាលលូងអាប់ឥតប្រាជ្ញា មិនចេះគិតពិចារណាថ្លឹងថ្លែងវែងឆ្ងាយមិនចេះ ពិចារណារកហេតុរកផល មិនគិតមិនចង់

ធ្វើអំពើល្អ ធ្វើតែអំពើអាក្រក់តែមួយជីវិតរបស់ពួកវាហើយនោះ ក៏ពួកវានៅតែចង់បានសេចក្តីសុខ និងអំពើល្អនោះផងដែរ។ គ្រាន់តែថាពួកចោរទាំងនោះ គ្នាមានគំនិតខ្លីគិតខ្លីចិត្តស្មោកគ្រោក គ្នាមានតែនិស្ស័យយល់ខុសជាចោរតាំងតែពីដើមទៅហើយនោះ តែពួកវាក៏នៅតែចង់បានសេចក្តីសុខ និងសេចក្តីល្អដូចជាមនុស្សពេញលក្ខណៈជាធម្មតាទូទៅផងដែរតើ។ យើងថាចោរទៅ វាជាមនុស្សអាក្រក់ គេទទួលស្គាល់ជាសកលទៅហើយថាគ្នាជាមនុស្សដើរបំពុលសង្គម ហើយចុះចំណែកឯមេដឹកនាំមួយចំនួនវិញនោះ? ដែលជាមនុស្សសាធារណៈទៅទៀតនោះ ខ្លះក៏គេចាត់ទុកដូចជាម្តាយឪពុក និងចាត់ទុកដូចជាព្រះអាទិទេពថែមទៀតផងនោះ បែរជាមេដឹកនាំប្រទេសមួយចំនួនខ្លះទាំងនោះមានចិត្តដូចជាចោរយ៉ាងនោះទៅវិញ? ខ្លះទៀតនោះចិត្តមេដឹកនាំទាំងនោះមានចិត្តល្បិចកិច្ចកលពុតថ្បត់យ៉ាងអាក្រក់ថោកទាបគួរឲ្យខ្លាចជាងពួកចោរទាំងនោះរាប់រយដងថែមទៀតផង។

ហេតុដូចម្តេចបានជាពួកគេ( **មេដឹកនាំ** )ទៅជាបែបនោះទៅវិញហ្ន៎! ភាពអាត្មានិយម គឺមានតែបេះដូងតែគ្មានមនោសញ្ចេតនាពូជសាសន៍ និងគ្មានមនសិការឧត្តមគតិជាតិនោះឯង ហើយនោះគឺជាប្រភពខាងដើមដែលបណ្តាលធ្វើឲ្យខ្លួនកំពុងធ្លាក់ចុះតម្លៃក្នុងនាមជាមេដឹកនាំម្នាក់ ហើយក៏ជាប្រភពខាងដើមនៃភាពថោកទាបបំផុត របស់មេដឹនាំទាំងឡាយផង។ មេដឹកនាំ

គឺជាតំណាងនៃប្រទេសជាតិសាសន៍មួយទាំងមូល តែបែរជាធ្វើតែអំពើអាក្រក់ មិនព្រមធ្វើជាគំរូល្អមិនព្រមធ្វើអំពើល្អ ពិតណាស់ខ្លួនគេផ្ទាល់គឺជាមេដឹកនាំបិសាចយ៉ាងពិតជាក់ស្តែង គេអាចនិងក្លាយទៅជាមេដឹកនាំងប់និងអំណាច ប្រមូលផ្តុំអំណាច រហូតដល់បង្កើតក្រុមពួកឃាតករ សម្រាប់សម្លាប់មនុស្សណា ដែលហ៊ានប្រឆាំងត៉វ៉ាទៅនិងទង្វើអាក្រក់របស់ខ្លួនគេជាមេដឹកនាំ ក្នុងរបបសម័យកាលដឹកនាំរបស់ខ្លួននេះថែមទៀតផង។ ហើយយើងបានដឹងជាច្រើនកន្លងមកហើយដែរ ក៏ធ្លាប់បានដឹងដែរថាមានមេដឹកនាំដ៏ថោកទាបបែបៗនេះមួយចំនួន នៅក្នុងពិភពលោកដែលគេធ្លាប់បានយកទៅដាក់ទោស និងសម្លាប់ចោលយ៉ាងសាកសម ទៅនិងទង្វើរដ៏ថោកទាបរបស់ពួកគេដែលជាមេដឹកនាំទាំងនោះ ដែលពួកគេធ្លាប់តែបានធ្វើកន្លងមកផងនោះ ហើយនេះឯងដែលជាលទ្ធផលទង្វើរអាក្រក់ ដែលពួកគេធ្លាប់តែបានធ្វើមក វាបានឲ្យផលគឺបែបហ្នឹងមុននិងក្រោយនោះ នេះឯងគឺជាហេតុផលតុលាការ កាត់ទោសក្នុងដំណើរការប្រព្រឹត្តទៅនៃច្បាប់ជាតិ ច្បាប់អន្តរជាតិ និងច្បាប់របស់ធម្មជាតិជាសកលនោះឯង។

# ជម្ងឺចំឡែកក្នុងខ្លួនខ្ញុំ

បើនិយាយអំពីជម្ងឺ គឺមានជម្ងឺជាច្រើនប្រភេទណាស់ នៅក្នុងពិភពលោកយើងនេះ ជាការពិតណាស់មនុស្សជាទូទៅគឺពួកគេមិនចង់ឲ្យជួប និងមិនចង់ឲ្យជម្ងឺណាមួយបៀតបៀនកើតមកលើខ្លួនគេ និងមកលើក្រុមគ្រួសាររបស់ពួកគេនោះទេ។ យ៉ាងណាមិញខ្ញុំក៏មិនចង់ឲ្យជម្ងឺទាំងនោះ កើតមកលើរូបខ្ញុំ និងគ្រួសារបងប្អូនរបស់ខ្ញុំនោះផងដែរ តែបើវាត្រូវកើតហើយនោះ ទោះបីបងប្អូនចង់កើតក្តីមិនចង់កើតក្តី ឬ ខ្ញុំចង់មិនចង់យ៉ាងណាក៏ដោយនោះក្តី គឺវាត្រូវតែកើតហើយ ទាំងដែលវាបានកំពុងតែកើតមកលើរូបខ្ញុំរួចបាត់ទៅហើយ ហើយវាមិនមែនចម្លែកត្រង់ ដែលថាខ្ញុំចង់កើតឬមិនចង់កើតនោះទេ តែវាបានកើតមកលើខ្ញុំដោយមិនដឹងខ្លួនរួចស្រេចបាត់ទៅហើយ ហើយវាគឺជាជម្ងឺដ៏ចម្លែកថែមទៀតផង។ តើនៅលើភពផែនដីនេះ មានមនុស្សប៉ុន្មាននាក់ទៅហ្ន៎! ដែលជម្ងឺចំឡែកមួយនេះ បានកើតនៅលើពួកគេនោះ? តើជម្ងឺចំឡែកនោះគឺជាជម្ងឺអ្វីទៅហ្ន៎! ជម្ងឺដែលខ្ញុំកំពុងតែនិយាយហូរហែរមកនោះ គឺវាគ្មានជម្ងឺអ្វីណាក្រៅតែពីជម្ងឺដែល **«ស្អប់អាពពួកមនុស្សសន្តានពុតត្បុតពពួកជនចិត្តអាត្មានិយមជ្ញរជាតិ»** ទាំងឡាយនោះទេណា។ ជម្ងឺទាំងនេះគឺវាតែងតែមាននៅក្នុងសន្តានចិត្ត និងអារម្មណ៍របស់ខ្ញុំជានិច្ចកាល ទោះបីជាពេលខ្លះខ្ញុំខំព្យាយាមធ្វើជាមិនដឹងមិនឮ មិនខ្វីខ្វល់ជាមួយពួកវាយ៉ាងណាក៏ដោយនោះក្តី ខ្ញុំខំរៀនសម្របខ្លួនខំប្រឹងធ្វើជាធម្មតារស់នៅដូចគេដូចឯង

ដើម្បីជំរុញចិត្តនេះឲ្យវាទៅជួយគាំទ្រ ពពួកមនុស្សថោកទាបទាំងនោះ ដូច មនុស្សមួយចំនួនដែលពួកគេអាចនាំគ្នា ទៅគាំទ្រពួកទាំងនោះកើតក្តី ក៏ចិត្ត របស់ខ្ញុំមួយនេះវាមិនព្រមស្របទៅតាមជាមួយឡើយ តែបែរជាវាកាន់តែធ្វើឲ្យ ក្នុងខ្លួនរបស់ខ្ញុំមានអារម្មណ៍ថា ស្អប់ពពួកអាមនុស្សថោកទាបទាំងនោះ កាន់តែខ្លាំងឡើងៗមួយកម្រិតជាទ្វេដងថែមទៀតផង។ ដូច្នេះពួកមនុស្សមួយ ចំនួន ដែលពួកគេអាចលើកដៃគាំទ្រ ពពួកអាមនុស្សអាក្រក់ទាំងនោះកើតបាន នោះ តើពួកគេមានអារម្មណ៍ក្នុងសន្តានចិត្តគំនិតខួរក្បាល របស់ពួកគេទាំង នោះយ៉ាងដូចម្តេចទៅហ្ន៎! តើក្នុងចំណោមពួកគេទាំងនោះ ដែលជាអ្នកគាំទ្រ មនុស្សអាក្រក់ទាំងនោះ តើមានប៉ុន្មានអ្នកទៅហ្ន៎! ដែលមានជម្ងឺចម្លែកមួយ នេះដូចខ្ញុំនោះ? តែបើនិយាយចំពោះខ្លួនខ្ញុំផ្ទាល់វិញ អ្នកដែលកំពុងកាន់ សៀវភៅអាននេះអាចនិងយល់ថា ខ្ញុំសរសេរនេះគឺសរសេរអួតតែពីខ្លួនឯងតែ ប៉ុណ្ណោះ តែនេះវាគឺជាអ្វីដែលមានពិតនៅក្នុងចិត្តរបស់ខ្ញុំពិតមែន ហើយអ្នកក៏ មានសេរីភាពក្នុងការគិត ក្នុងការយល់ក្នុងការវិនិច្ឆ័យនិងវាយតម្លៃ មកលើស ភាពចិត្តរបស់ខ្ញុំបាន ពីព្រោះថានេះវាគឺជាសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗក្នុង ការវាយតម្លៃបាន វាគឺជាសិទ្ធិ របស់ពួកលោកអ្នកអាន ជាអ្នកថ្លឹងថ្លែងក្នុងការ ពិចារណារកហេតុផល សម្រាប់ខ្ញុំសូមសរសេរបញ្ជាក់ត្រឹមតែពីស្ថានភាពពិត ដែលវាកំពុងតែកើតមានជាបន្តបន្ទាប់ ជាប់មិនដាច់ក្នុងខ្សែសន្តានវិញ្ញាណចិត្ត

អារម្មណ៍បេះដូងរបស់ខ្ញុំតែប៉ុណ្ណោះ ដែលខ្ញុំធ្លាប់មានបទពិសោធ ធ្លាប់ជួបប្រទះមកហើយ មានក្នុងដំណើរជីវិតរបស់ខ្ញុំកន្លងមកហើយនោះ។ដូច្នេះ តាមតែសន្តានចិត្តគំនិតអារម្មណ៍វិញ្ញាណ និងខួរក្បាលរបស់ខ្ញុំនៅក្នុងពេលបច្ចុប្បន្ននេះ គឺនូវតែមិនអាចធ្វើឲ្យខ្ញុំទន់ចិត្ត ឬ ប្រទ្បំវង្វេងភាន់ស្មារតីសូម្បីតែម្តង ដើម្បីឲ្យខ្ញុំលើកដៃទៅគាំទ្រពពួកអាមនុស្សសំរាមទាំងនោះ គឺនូវតែមិនអាចធ្វើឲ្យខ្ញុំអាចគាំទ្រពួកគេកើតបានដដែល បែរជាកាន់តែធ្វើឲ្យខ្ញុំមានអារម្មណ៍ថាចេះតែចង់ក្អួតទៅវិញ ពេលដែលឃើញមុខឮសំលេង ពពួកមនុស្សមានចិត្តខូចវៀចវេរចិត្តអាត្មានិយមទាំងនោះ និងពួកអាប្រចុបប្រចែងពួកអាម៉ែអាថោងពួកអាជ័យធ្លាក់ទឹក ពួកអាធ្វើយកតែមុខទាំងឡាយនោះ។ និងមនុស្សសន្តានថោកទាបផ្កាប់មុខមួយចំនួនធំទៀត។ល។ គឺធ្វើឲ្យខ្ញុំកាន់តែមានអារម្មណ៍ថាខ្ពើមរអើមស្អីញ និងពពួកទាំងនោះកាន់តែខ្លាំងឡើងៗជាទ្វេដងថែមមួយកម្រិតទៀតផង។ ឱ!ជម្ងឺចំឡែក អ្នកពិតជាចំឡែកមែន ខ្ញុំពិតជាអរគុណអ្នកឯងជាខ្លាំង អ្នកឯងពិតជាមានតម្លៃខ្លាំងណាស់ គ្មានអ្វីមកអាចកាត់ថ្លៃនិងតម្លៃអ្នកឯងបានឡើយ ខ្ញុំពិតជាមានមោទនភាពជាខ្លាំង ដែលមានវត្តមានពួកឯងបានមកសន្និតក្នុងបេះដូងសន្តានខួរក្បាល របស់ខ្ញុំឲ្យបានប្រែទៅជាមនសិការឧត្តមគតិក្នុងអារម្មណ៍របស់ខ្ញុំនោះ អ្នកពិតជាសភាវៈមួយដ៏មានតម្លៃខ្លាំងពេកណាស់ ដែលបានធ្វើឲ្យខ្លួនខ្ញុំបានពេញលក្ខណៈជាមនុស្សយ៉ាងពិត

ប្រាកដ និងមានតម្លៃជាមនុស្សពិតប្រាកដ ការអរគុណរបស់ខ្ញុំទៅកាន់ពួកឯង នោះ មិនមែនមកតែពីពួកឯងឲ្យប្រយោជន៍ដល់ខ្ញុំនោះទេ តែមកតែពីពួកឯង បានធ្វើឲ្យខ្ញុំបានក្លាយទៅជាមនុស្សថ្មីម្នាក់ ដែរអាចមានសមត្ថភាពនឹងបានធ្វើ ប្រយោជន៍ឲ្យដល់ជនទូទៅបានបន្តថែមទៀតផងនោះឯង ហើយមិនមែនត្រឹម តែខ្លួនខ្ញុំតែម្នាក់នោះទេ ដែលអ្នកមកជួយបំពេញឲ្យបានពេញលក្ខណៈជា មនុស្ស និងមានតម្លៃជាមនុស្សជាមនុស្សពិតប្រាកដនោះ តែក៏មានជនដទៃ ផ្សេងជាច្រើនទៀតផង ក៏និងត្រូវបានទទួលពីពួកឯងបន្តរៗទៀតផងដែរ ឲ្យតែ ពួកគេជាមនុស្សចេះបើកចិត្តជាមនុស្សចេះស្តាប់ហេតុផល ជាមនុស្សមិនមាន អគតិធម៌ទេនោះ នោះគឺពួកគេក៏និងត្រូវបាន( **ជម្ងឺចំឡែក** )ដ៏មានតម្លៃមួយ នេះ ជួយឲ្យបានមានតម្លៃនិងពេញលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដផងដែរ សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួគេនោះ។ ពិតណាស់ជម្ងឺចម្លែកដ៏មានតម្លៃ មួយនេះ មិនមែនចេះតែទៅកើតមានលើមនុស្សបានគ្រប់ៗតែរូបបានងាយៗ នោះឡើយ បើមនុស្សទាំងនោះពួកគេគ្មានសារជាតុល្អក្នុងចរន្តចិត្តរបស់ពួកគេ ទេនោះ ទាំងដែលពួកគេបែរជាកាន់តែធម៌ទិដ្ឋិមានៈ និងអគតិធម៌ពេញតែខ្លួន ទៅវិញថែមទៀតនោះ ពិតណាស់ជម្ងឺចំឡែកមួយនេះ ដាច់ខាត់គឺមិនអាច ទៅស្ថិតនៅលើខ្លួន ពពួកប្រភេទមនុស្សដែលមានសន្តានចិត្ត បែបនោះបាន ឡើយ។ តែវាពិតប្រាកដណាស់ ជម្ងឺចំឡែកមួយនេះនិងផ្តល់តម្លៃឲ្យមនុស្ស

ណា ដែលមានតែដួងចិត្តជាមនុស្សតែម៉្យាងយ៉ាងពិតប្រាកដ វានិងស្ថិតទៅតាមធម្មជាតិ គឺទៅតាមចរន្តសែរសៃនិងការសន្សំនិស្ស័យ ជាសាជាតុជាមនុស្សល្អ វាអាចស្ថិត និងជួយបំពេញឲ្យមនុស្សទាំងនោះ មានលក្ខណៈជាមនុស្សពេញលេញ និងធ្វើឲ្យពួកគេមានតម្លៃក្នុងជីវិតរស់នៅ ដ៏សមស្របទៅនឹងដំណើរច្បាប់ធម្មជាតិ របស់ពួកគេបានយ៉ាងពិតប្រាកដ ដែលវាជាតម្លៃហើយក៏ពិតជាបំណងពិតរបស់ព្រះទូទៅ លោកអ្នកទស្សនវិទូ លោកអ្នកប្រាជ្ញសប្បុរស និងមនុស្សល្អទូទៅនៅលើភពផែនដីយើងនេះ ដែលពួកលោកទាំងនោះមានបំណងចង់ឲ្យពួកយើងដើរផងដែរ មិនត្រឹមតែប៉ុណ្ណោះទេគឺពួកលោកសប្បុរសទាំងនោះពួកលោកបានបន្សល់ទុកនូវមេរៀន និងរូបមន្តល្អៗជាច្រើនថែមទៀតដែលសម្រាប់ទុកធ្វើជាគំរូជារូបមន្តឲ្យដល់ពួកយើង ដែលនឹងកំពុងរស់នៅជំនាន់ក្រោយៗនេះ គ្រាន់និងបានធ្វើជាគំរូមេរៀនសម្រាប់សិក្សា ហើយឲ្យនាំគ្នាយកមកអនុវត្តតាមធ្វើជាគំរូ ដើម្បីជាការផ្តល់នូវសេចក្តីសុខ ឲ្យបានដល់គ្នានិងគ្នាក្នុងការរស់នៅ ក្នុងភពផែនដីជាមួយគ្នាក្នុងពេលបច្ចុប្បន្នសព្វថ្ងៃនេះផងនិយាយមកដល់ត្រង់ចំណុចនេះ ក៏ចង់បញ្ជាក់ប្រាប់ដល់ពួកលោកអ្នកកាន់អានថាដោយសារពួកលោកទាំងនោះ ពួកលោកក៏ជាអ្នកធ្លាប់មានជម្ងឺចំឡែកផ្សេងនេះរួចមកហើយ ដែលបានធ្វើឲ្យចិត្តពួកលោកផ្លែកខុសពីមនុស្សធម្មតាទូទៅផងដែរ ទើបបានជាពួកលោកមានតម្លៃដ៏ខ្ពស់ឯក ខុសផ្សេងពីមនុស្សសាមញ្ញ

ធម្មតានោះឯង វាជាអារម្មណ៍មនុស្សលើមនុស្សជារបស់ពួកលោកផ្ទាល់យ៉ាង នោះឯង ហើយដែលពិសេសជាងនេះទៅទៀតនោះ ដែលធ្វើឲ្យពួកយើងជាអ្នក និពន្ធជាទូទៅដែលចង់និពន្ធទៅលើអ្វីមួយគឺថាមិនអាចបំភ្លេច និងមិនសរសើរ មិនបាន នូវរាល់ៗតែទង្វើសកម្មភាពពាក្យសម្ដី ដែលមានខ្លឹមសារដ៏មានតម្លៃ របស់ពួកលោកទាំងនោះបានឡើយ។

# មិនស្គាល់ខ្លួនឯងមិនស្គាល់តួនាទី

ពលរដ្ឋការមិនស្គាល់ខ្លួនឯង និងមិនស្គាល់តួនាទីរបស់ខ្លួនឯង វាពិតជា បញ្ហាដ៏គ្រោះថ្នាក់ខ្លាំងណាស់ សម្រាប់សង្គមជាតិមួយក៏ដូចសង្គមពិភពលោក ទាំងមូលនោះផងដែរ។ ទោះបីជាសង្គមគ្រួសារក្ដី ក៏មិនអាចនិងធ្វើឲ្យសង្គម គ្រួសារមួយនោះ មានសុខសុភមង្គលរីកចំរើនទៅបាននោះឡើយ បើសមាជិក ក្នុងគ្រួសារនោះមិននឹងដឹងថាខ្លួនឯងជាស្អី មិនដឹងតួនាទីខ្លួនឯងនិងត្រូវធ្វើអ្វី ផងនោះ។ ចុះទម្រាំសង្គមជាតិទាំងមូល តើវានិងក្លាយទៅជាយ៉ាងណាទៅ? បើប្រជាពលរដ្ឋនិងរដ្ឋាភិបាល មិននឹងទាំងស្គាល់ខ្លួនឯង មិននឹងទាំងស្គាល់តួ នាទីរបស់ខ្លួនឯងផង? តើទាំងនោះវាមិនមែនជាបញ្ហាគ្រោះថ្នាក់ដល់សង្គម ជាតិទេរឺ?ពេលខ្លះដោយសារតែមានភាពមមាញឹក ក្នុងកិច្ចការងាររកស៊ីខ្លាំង ពេកទៅ ក៏ជាហេតុបណ្ដាលធ្វើឲ្យពលរដ្ឋ ដែលជាម្ចាស់ប្រទេសមិនខ្វីចាប់ អារម្មណ៍ខ្វាយខ្វល់គិតពីតួនាទីរបស់ពួកខ្លួន ក្នុងនាមពួកគេជាប្រជាពលរដ្ឋជា

ម្ចាស់ប្រទេសសម្រាប់សង្គមខ្លួននោះទៅវិញ ភ្លេចពីកាតព្វកិច្ចក្នុងកិច្ចការងារជួយសង្គមជាតិ ក្នុងនាមជាប្រជាពលរដ្ឋម្ចាស់ប្រទេសនោះ ទៅទាំងស្រុងតែម្តង ចំណែកឯមេដឹកនាំដែលពលរដ្ឋខំទុកចិត្ត បានបោះឆ្នោតឲ្យគ្រាន់តែដើម្បីធ្វើជាតំណាងពលដ្ឋមួយប្រទេសឯណោះវិញនោះ ក៏គាត់កំពុងតែជាប់ផុងលុងវង្វេងភាន់គំនិតឈ្លក់ក្នុងអំណាច លុយកាកបុណ្យស័ក្តិបក្សពួកក្រុមគ្រួសារនិយមរបស់គាត់នោះម៉ាសន្ធឹកទៅមួយប៉ែកទៀតទៅ។

ពេលខ្ញុំសរសេរមកដល់ត្រង់ចំណុចនេះ គឺមានបំណង់តែម៉្យាងនោះទេ គឺដើម្បីតែចង់ដាស់សតិឲ្យប្រជាពលរដ្ឋខ្មែរ ត្រូវតែចេះនាំគ្នាចូលរួមជួយគិតគូរពីរឿងប្រទេសជាតិ គិតគូរពីនយោបាយដោយខ្លួនឯងវិញម្តង។ ពីព្រោះតាមដែលខ្ញុំធ្លាប់បានដឹងកន្លងមក វាជាកំហុសរបស់ពួកអ្នក(**ពលរដ្ឋ**)ជាម្ចាស់ប្រទេសដែលបានរកតំណាងឲ្យខ្លួនឯង ខុសជាបន្តបន្ទាប់រាប់ជំនាន់មកហើយ ហើយត្រូវដឹងនូវក្នុងខួរខ្លួនឯងម្នាក់ៗឲ្យបានច្បាស់ថា វាមិនមែនជាកំហុសរបស់អ្នកតំណាង(**រដ្ឋាភិបាល**)ទាំងស្រុងនោះទេ តែវាគឺពិតជាកំហុសដ៏ធំបំផុតរបស់ពួកអ្នក ហើយក៏ជាកំហុសដ៏ធំមួយរបស់ពួកអ្នក ដែលនិងធ្វើឲ្យកូនចៅជំនាន់ក្រោយៗរបស់ពួកអ្នក និងមិនអាចលើកលែងទោសឲ្យដល់ពួកអ្នកបានជាដាច់ខាត ដែលពួកអ្នកក្នុងពេលនេះបាននាំគ្នា សម្រេចចិត្តជ្រើសរើសមេដឹកនាំខុសបានគ្រប់គ្រងប្រទេស ទុកឲ្យពួកគេជាកូនរបស់ពួកអ្នកបានរងទុក្ខ

បន្ទាប់នោះ គិតបន្តិចទៅមកដល់ពាក្យហ្នឹងដូចជា «**ចាំចហាចពេក ហើយ**» មើលទៅប្រជាពលរដ្ឋខ្មែរ ដូចជាមនុស្សពីរនាក់និយាយស្ដាប់គ្នាមិនបាន ដូចមានម្នាក់នៅលើមាត់ជ្រោះ និងម្នាក់ទៀតកំពុងតែនៅក្នុងបាតជ្រោះអញ្ចឹង។ បើមានអ្នកណាម្នាក់ មកជួយណែនាំដាស់តឿនពួកគាត់ឲ្យចេះនាំគ្នាមកគិតពីសង្គមជាតិរបស់ពួកគាត់វិញនោះពលរដ្ឋខ្មែរទាំងនោះ និងមានសំនួរផុសឡើងក្នុងក្បាលរបស់ពួកគាត់ភ្លាម ហើយនិងលើកជាសំនួរសួរថា: តើឲ្យពួកយើងជួយជាតិទៅតាមរបៀបណាកើតទៅ?បើខ្ញុំមិនចេះអក្សរផងនោះ ខ្ញុំជារាស្ត្រតូចតាចសាមញ្ញ ជារាស្ត្រក្រីក្រហ្នឹង តើខ្ញុំអាចនិងជួយជាតិកើតដែររឺ? បើជីវភាពរបស់ពួកខ្ញុំក្រយ៉ាងនេះនោះ? ការឆ្លើយតបរបស់ពួកអ្នកខ្ញុំពិតជាទទួលស្គាល់រាល់បញ្ហា ដែលពួកអ្នកបានកំពុងលើកឡើងយកមកត្អូញត្អែរវាពិតជាបញ្ហាពិតកំពុងមាននៅក្នុងសង្គមរបស់អ្នកមែនហើយ តែតាម«**ទស្សនវិជ្ជា**» ការជួយជាតិមិនមែនទាល់តែពលរដ្ឋនោះមានជីវភាពធូរធា ឬទាល់តែមានលុយកាក់មាសប្រាក់ទ្រព្យច្រើននោះ ទើបបានអាចជួយជាតិបាននោះទេ។ សិក្សាទៅលើ(**ទស្សនវិជ្ជា**) យើងអាចនិងយកមកនិយាយ ដើម្បីបង្ហាញឲ្យជាគំនិតបានថា «**ទាំងអ្នកមានទាំងអ្នកក្រអាចជួយជាតិបានដូចតែគ្នាដឹង**» បើពួកគេទាំងនោះដឹងខ្លួនច្បាស់ថា ខ្លួនរបស់

ពួកគេគឺជាប្រជាពលរដ្ឋ ដែលជាម្ចាស់នៃប្រទេសមួយនឹងគេដែរ និងព្រមទាំងដែលដឹងពីតួនាទីកតព្វកិច្ច និងមានឧត្តមគតិមនសិកាជាតិផងនោះ។ «**ពលរដ្ឋអន់គឺពលរដ្ឋដែលចាញ់ក្នុងដំណើរបញ្ហាជីវិត តែពលរដ្ឋដែលខ្លាំងគឺជាពលរដ្ឋ ដែលហ៊ានប្រឈមមុខដោះស្រាយបញ្ហាក្នុងដំណើរជីវិត**» ពាក្យមួយគេនិយាយថា«**អ្នកក្រក៏មានអ្នកមានក៏មាន អ្នកមានក៏មាន អ្នកក្រក៏ក្រ**»។ ឥឡូវអារឿងក្រ អារឿងមាន យើងទុកវាមួយឡែកសិនទៅចុះ តែពួកយើងមកនិយាយគ្នាអារឿង**កាតព្វកិច្ច តួនាទី ឧត្តមគតិ និងមនសិការជាតិ** របស់ពួកយើងនេះជាមុនសិន។ ***សួរថា***:ក្នុងនាមអ្នកជាប្រជាពលរដ្ឋនៅក្នុងសង្គមមួយ តើស្គាល់ច្បាស់និងមានពួកវា(កាតព្វកិច្ច តួនាទី ឧត្តមគតិ និងមនសិការជាតិ)នៅក្នុងសន្តានបេះដូងខួរក្បាល របស់ពួកអ្នកគ្រប់ៗគ្នាហើយឬនៅ?ចម្លើយ...........។ ការមានគូរស្រករជាប្ដីជាប្រពន្ធ វាជាច្បាប់ធម្មជាតិ គឺថាវាមិនងាយនរណាម្នាក់អាចស្ទុះឲ្យរួចផុតបាននោះឡើយ ការបានគ្នាជាប្ដីជាប្រពន្ធ ហើយអារឿងមានកូននោះសោធក៏កាន់តែពិបាកថែមទៀតហើយ ដែលថានិងស្ទុះឲ្យផុតគឺមិនងាយនោះឡើយ។ ដូច្នេះហើយការមានកូនចៅគឺមានទាំងអ្នកមាន និងមានទាំងអ្នកក្រ យ៉ាងពិតប្រាកដគឺគ្មាននរណាម្នាក់

អាចបដិសេធ ឬប្រកែកពីរឿងនេះបានឡើយ។ តែបើយើងអាចស្ទុះផុតពីការមិនមានប្ដីប្រពន្ធបាននោះ នោះវាគឺជាមនុស្សម្នាក់ដ៏អស្ចារ្យតែសាមញ្ញបំផុតហើយក្នុងចំណោមមនុស្សសាមញ្ញទូទៅ។

បើកូនៗពួកអ្នក ដែលពួកអ្នកបានបង្កើតពួកគេមកហើយ ក្នុងនាមពួកអ្នកដែលត្រូវជាឪពុកម្ដាយរបស់ពួកគេនោះ តើពួកអ្នកជាមនុស្សមានជំហរទំនួលខុសត្រូវខ្ពស់ទៅលើពួកគេជាកូននោះហើយឬនូវ? ឬក៏គ្រាន់តែបង្កើតគេមកនេះទៅតាមតែចំណង់តណ្ហារបស់ពួកខ្លួនជាស្រីជាប្រុស ដោយគ្មានទំនួលខុសត្រូវលើកំណើតពួកគេទេ? តើមុននិងសម្រេចបង្កើតគេមកនោះ ពួកអ្នកមានមនោសញ្ចេតនាចំពោះពួកគេទេ ហើយស្គាល់ច្បាស់ពីតួនាទីមានកាតព្វកិច្ចមានភាពជាគំរូ និងមានមនសិកាជាតិហើយរឺ? ការចេះបង្រៀននិងចេះពន្យល់ណែនាំកូនឲ្យបានចូលសាលារៀន និងចេះផ្ដល់ដំបូន្មានឲ្យដល់កូនដើម្បីឲ្យពួកគេបានដុះមនសិការឧត្ដមគតិជាតិនោះហើយឬនៅ? ដែលពួកអ្នកជាម្ដាយជាឪពុកបានបង្កើតគេមកហើយ ព្រមទាំងបានផ្ដល់ឲ្យពួកគេចេះមានមនសិការឧត្ដមគតិជាតិនោះឯងហើយគឺជាការជួយជាតិ ទាំងពលរដ្ឋអ្នកមានទាំងពលរដ្ឋអ្នកក្រនោះឯង។ ការជួយជាតិរបស់ខ្លួនសោះហ្នឹង ចាំបាច់ស្អីឲ្យជីវភាពក្រីក្រហ្នឹងវាមករាំងស្ទះដំណើរដែរនោះ តើហេតុអ្វីបានជាពួកអ្នកឲ្យតម្លៃទៅលើភាពក្រីក្រនិងអីក៏ខ្លាំងម្ល៉េះ? ទាំងដែលសង្គមជាតិរបស់ពួកអ្នក

កំពុងតែលិចលុងយ៉ាងជ្រៅបែបនេះទៀតនោះ? បើពួកអ្នកធ្វើរឿងប៉ុណ្ណឹងមិនបានទេនោះ សូមកុំបង្កើតពួកគេមកឲ្យទទួលរងទុក្ខទោសនៅក្នុងសង្គមមួយនេះឲ្យសោះ ពីព្រោះកូនប្រុសស្រីរបស់ពួកអ្នកទាំងនោះ គឺថាពួកគេមិនបានមកសុំពួកអ្នកមកកើតជាមួយពួកអ្នកនោះទេ ហើយឈប់ប្រទ្បំមកចង់ទាមទារគុណពីពួកកូនៗទាំងនោះទៀតទៅ បើពួកអ្នកបានបង្កើតគេមកហើយមិនទាំងនិងបានអប់រំគេឲ្យបានជាមនុស្សល្អមានឧត្តមគតិជាតិ និងមនសិការជាតិផងទេនោះ។ មនុស្សដែលមិនហ៊ានប្រឈមមុខ និងបញ្ហាគឺជាមនុស្សសំរាម គឺជាមនុស្សមេរោគដ៏ចង្រៃបំផុតនៅក្នុងសង្គមជាតិមួយនេះ ក៏ដូចសង្គមជាតិទូទៅក្នុងពិភពលោកទាំងមូលផងដែរ។

# គំនិតក្ដួយអណ្ដើក

នៅពេលដែលយើងនឹកទៅដល់រឿងស្រុកខ្មែរ គឺយើងនឹកភ្នក់ភ្លាមទៅលើគំនិតខ្លីរបស់ពលរដ្ឋខ្មែរភាគច្រើន គឺថាសម្បូរទៅដោយមនុស្សគំនិតខ្លី វាមិនត្រឹមតែគំនិតខ្លីនោះទេ គឺវាមានអាជម្ងឺចង្រៃ៥យ៉ាងទៀតនោះគឺជម្ងឺ«**អួត អឿ ជឿ ដោរ ងឺង៉អារឿង៉មុខមាត់**»ប៉ុនបាត់ដៃនឹងគឺជាសភាពចង្រៃនេះឯង ដែលតែងតែមាននៅជាប្រចាំជីវិត នៅលើជនជាតិពូជសាសន៍មួយនេះភាគច្រើន។ តាំងតែពីសម័យក្រោយអង្គរ រហូតមកដល់សម័យបច្ចុប្បន្ន តាំងពី

សម័យទឹកដីនៅសល់ច្រើន រហូតមកដល់សម័យជិតនិងអស់ដីសម្រាប់ពលរដ្ឋរស់នៅ គឺសរបញ្ជាក់បង្ហាញឲ្យឃើញជាទូទៅពីគំនិត ទៅលើអត្តចរិតនិងលក្ខណៈរបស់ពលរដ្ឋខ្មែរ ដែលកំពុងតែរស់នៅក្នុងប្រទេសមួយនេះ ដែលពលរដ្ឋភាគច្រើនៗតែមានគំនិតតែប្រវែងនិងកន្ទុយអណ្តើកនោះឯង។ ហើយក៏បានបញ្ជាក់យ៉ាងជាក់ច្បាស់ថែមទៀតថាពូជសាសន៍មួយនេះ គឺសម្បូរតែមនុស្សមិនដែលយកឈ្នះខ្លួនឯងហ្នឹងទាល់តែសោះ។ «ព្រះពុទ្ធ» សម្តែងថា **«មនុស្សបើមិនយកឈ្នះខ្លួនឯង ជាមុនសិននោះ កុំសង្ឃឹមថា និងយកឈ្នះអ្នកដទៃ ឬសត្រូវចាំងឡាយបាន ឲ្យសោះ»**។ យើងធ្លាប់បានដឹងបានឮ គ្រប់ៗតែគ្នារួចមកហើយតើ នៅក្នុងប្រវត្តិសាស្ត្រជាបន្តបន្ទាប់ **ការបាត់បង់ទឹកដីប្រទេសចំប៉ា របស់ជនជាតិពូជសាសន៍ចាមកន្លងមកហើយនោះ** ជនជាតិចាមជាជាតិសាសន៍មួយ ដែលធ្លាប់មានប្រទេសជាកម្មសិទ្ធិមួយនិងគេដែរនៅក្នុងផែនទីពិភពលោក តែឥឡូវត្រូវបានបាត់បង់ប្រទេសទាំងមូល គឺបានបាត់បង់ទៅលើនៅប្រទេសវៀតណាម(យួន)សព្វថ្ងៃនេះឯង ឥឡូវនេះពូជសាសន៍ចាមមួយនេះ គឺគ្នាគ្មានប្រទេសគ្មានទឹកដីនៅជារៀងរហូតមកដល់ទាល់សព្វថ្ងៃ គឺបាត់ចេញពីផែនទីពិភពលោកនេះតែម្តង។ ជាច្រើនសតវត្សរ៍កន្លងមកហើយ

នេះទុកជាមេរៀនដ៏រសើមមួយ គ្រាន់តែទុកសម្រាប់ដាស់សតិស្មារតីដល់ប្រជាពលរដ្ឋខ្មែរសព្វថ្ងៃ ដែលជាជាតិសាសន៍មួយ ដែលតែងតែមានអត្តចរិត**ជើងមិនជាប់ដីក្បាលមិនជាប់មេឃ** សម្រាប់ទុកជាគំរូដ៏អាក្រក់ សម្រាប់ឲ្យខ្មែរមើលឲ្យចេះពិចារណាឲ្យចេះការពារឲ្យចេះរៀនមើលពីបច្ចុប្បន្ន និងទៅអាគតបន្តទៀត។ សរសេរមកដល់ត្រង់ចំណុចនេះខ្ញុំចង់ដាក់**សំនួរ**សួរលេងៗថា តើការបាត់បង់ទឹកដីប្រទេសចំប៉ា ទាំងមូលរបស់ជនជាតិចាម ទៅលើកណ្តាប់ដៃរបស់ប្រទេសវៀតណាម(យួន)សព្វថ្ងៃនេះ ថាតើវាគឺជាកំហុសរបស់ជនជាតិសាសន៍យួនទាំងស្រុង ឬក៏ជាកំហុសរបស់ជនជាតិសាសន៍ចាមខ្លួនឯងផ្ទាល់នោះទៅវិញទេ? បើជាពូជសាសន៍ដែលច្រើនទៅដោយចិត្តអាត្មានិយមមានតែ**អំនួត អួត អឿ ជឿជោរ** នោះដែលធ្វើអ្វីៗយកតែមុខខ្លាចតែអន់នោះគឺជាជាតិសាសន៍មួយដ៏ល្ងង់ខ្លាំងណាស់ ហើយគឺជាពូជសាសន៍ដែលចាញ់តែខ្លួនឯងទៀតនោះ គឺថាពួកគេខំឆ្លើយ និងព្យាយាមបកស្រាយឲ្យខ្លួនពួកគេបានល្អនិងឲ្យបានត្រូវថែមទៀតក្នុងទង្វើថោកទាបរបស់ពួកគេថែមទៀតផង ទាំងដែលខ្លួនកំពុងចាញ់សត្រូវអស់អ្វីៗពីខ្លួនគ្មានសល់នោះ។ តើបងប្អូនអ្នកអានអាចនិងដឹងបានថាពួកគេទាំងនោះ និងឆ្លើយយ៉ាងដូចម្តេចទេ?គឺពិតណាស់ពួកគេនិងឆ្លើយថា មកតែពីអាពូជសាសន៍យួនហ្នឹង វាចេះតែចង់បានទឹកដីរបស់គេនុងឯង តែបែរជាពួកគេមើលមិនបានឃើញពីកំហុសដ៏ធំសម្បើម

របស់ពួកខ្លួនដែលបានកំពុងមានការធ្វេសប្រហែស ដែលជាអ្នកផ្ដើមកំហុសដំបូងនោះទេ។ បើចរិតពូជបាត់ដីដែលចេញមកមួយៗបន្ទោសតែគេបន្ទោសតែឯងរបៀបៗនេះនោះ គឺថាវាសមនិងបាត់ទឹកបាត់ដីអស់គ្មានកន្លែងជ្រក់នឹងវាសមមុខនុងហើយ គឺសមណាស់សមបំផុតសមរកលេខដាក់គ្មាន បើពូជសាសន៍យួនគេមិនយកទើបចំឡែក បើពូជសាសន៍យួនវាមិនយកទេនោះ ក៏ត្រូវបានហ្វូងឆ្កែវាមកអង្គាមកកេរស៊ីអស់ដែរ ព្រោះហេតុអ្វី? ពីព្រោះថា មកតែពីយើងអន់គំនិត អន់ចរិត អត់មាយាទហ្នឹងឯង និយាយឲ្យខ្លីទៅគឺថា «**មិនឈ្នះខ្លួនឯងនោះអី**!»។ មនុស្សដែលមិនឈ្នះខ្លួនឯងហ្នឹង គឺងាយនិងបានសត្រូវធ្វើឲ្យវិនាស់ណាស់។ ពូជសាសន៍ចាមមិនឈ្នះខ្លួនឯង ងាយនិងយួនដាក់មនោគមន៍ ឥលូវបានយកទឹកដីប្រទេសចំប៉ាបានសម្រេចហើយ គឺបានរហូតមកទាល់ដល់សព្វថ្ងៃហ្នឹងឯង គឺថាចាមអស់កម្មសិទ្ធិជាប្រទេសរបស់ខ្លួនទៀតហើយ គឺបានមកយួនទាំងអស់ហើយចប់ហើយឯរំហើយ។ ចុះចំណែកឯលោកខ្មែរវិញ តើពេលណាបានលោកម្ចាស់ខ្មែរឯងចេះនាំគ្នាភ្ញាក់ខ្លួនភ្ញាក់កំណើតទៅ? ពេលណាបានពលរដ្ឋខ្មែរ ចេះនិយាយស្ដាប់ហេតុផលគ្នាបានទៅ?នៅដេកយូរម្លេះបងប្អូនហួសពេលឥលូវហើយ យួនសៀមយកដីអស់ហើយ យួនគេយកអស់ទឹកដីខ្មែរផ្នែកខាងកើត អស់ពាក់កណ្ដាលទៅហើយ ចំណែកឯសៀមក៏យកទឹកដីខ្មែរផ្នែកខាងលិច ក៏អស់ទៅពាក់កណ្ដាលផង

ទៀត ឥឡូវខ្មែរយើងនៅសល់ដីតែប៉ុនបាតដៃប៉ុណ្ណឹងទេណា! តើពលរដ្ឋខ្មែរនៅតែមិនព្រមនាំគ្នាភ្ញាក់ខ្លួនភ្ញាក់កំណើតទៀតទេអី?តើពេលណាទៅបានពលរដ្ឋខ្មែរលែងឈប់គិតខ្លី? តើពេលណាទៅបានពលរដ្ឋខ្មែរលែងឈប់ចង់បានមុខមាត់ លែងមាន អំនួត អួត អឿ ជឿ ជោរតទៅទៀតទៅនោះ?តើអស់កេរ្តិ៍ដូនតាខ្មែរអង្គរប៉ុណ្ណឹងហើយ ពលរដ្ឋខ្មែរជាម្ចាស់ប្រទេសនូវតែមិនទាន់ដឹងខ្លួនទៀតទេឬអី?ឱ!ទឹកដីដូនតាប្រាសាទអង្គរដ៏កម្សត់របស់ខ្ញុំអើយ! ម្ដេចឡើយបានជាត្រូវបានមករងកម្មនៅស៊ូទ្រាំទ្រពពួកពលរដ្ឋ ដែលសម្បូរតែភាពអាត្មានិយមដូចពូជខ្មែរបែបនេះទៅវិញអញ្ចឹង? បើពលរដ្ឋខ្មែរមិនព្រមនាំគ្នាប្រញាប់ភ្ញាក់កំណើតទាន់ពេលវេលាទេនោះណា! សូមកុំសង្ឃឹមថា សង្គមប្រទេសជាតិទឹកដីសុវណ្ណភូមិរបស់ពួកអ្នកមួយនេះ និងបានទទួលក្តីសុខសន្តិភាពឯកភាពជាតិ និងមានការរីកចម្រើនទៅបានឲ្យនោះសោះ គឺមានតែការរលាយទៅម្តងបន្តិចៗរហូតដូចទឹកដីចំប៉ាជាតិសាសន៍ចាមអញ្ចឹងណា! ចូលចាំឲ្យបានច្បាស់ទៅ។ ហើយចូលប្រាប់កូនចៅតៗជំនាន់របស់ពួកអ្នក ដែលពួកអស់អ្នកបានបង្កើតទុកឲ្យពួកវារស់នៅខាងក្រោយជំនាន់របស់ពួកអ្នក ឲ្យពួកវាបានដឹងឲ្យហើយទៅមុននិងជីវិតរបស់ពួកអ្នកនិងលាចាកពីភពផែនដីនេះទៅនោះ ថាបើកូនមានតែចិត្តអាត្មានិយមគំនិតខ្លីដូចតែឪពុកម្តាយរបស់កូននោះទេ ទឹកដី

ជូនតាអង្គរបស់កូនឯងមួយនេះ និងត្រូវធ្លាក់ក្នុងកណ្ដាប់ដៃយួនដូចតែប្រទេសចំប៉ាពុំខាននោះឡើយណាកូន!។

# ចង់តែចានចង់តែរស់ជាចរិតពូជសាសន៍ខ្ញុំ

ត្រីចេះតែរស់នៅក្នុងទឹក តែមិននាំគ្នាគិតខ្វល់ខ្វាយអំពីទឹកគឺជាបញ្ហា ពលរដ្ឋខ្មែរចេះតែរស់នៅក្នុងប្រទេស តែបែរជាមិននាំគ្នាគិតខ្វល់ខ្វាយអំពីនយោបាយប្រទេសជាតិរបស់ខ្លួននោះគឺជាបញ្ហា។ បើយើងដាក់សំនួរសួរទៅកាន់ពួកគេថា តើពួកលោកអ្នកសព្វថ្ងៃហ្នឹង ដែលបានធ្លាប់គិតពីសង្គមរបស់ពួកអ្នកដែរឬទេ?ពិតណាស់ពួកគេ(**ពលរដ្ឋ**)ខ្មែរទាំងនោះ និងមានចម្លើយឆ្លើយយ៉ាងលឿនតបមកយើងវិញភ្លាមៗ ដោយមិនចាំបាច់គិតច្រើននាំឲ្យតែឈឺក្បាលរបស់ពួកគេនោះទេ ពួកគេនិងឆ្លើយឡើងយ៉ាងព្រមៗគ្នាមកកាន់យើងតែម្ដងថា ពួកខ្ញុំសព្វថ្ងៃនេះគិតសង្គមដែរតើ ថាពួកខ្ញុំមិនដែលធ្លាប់គិតពីសង្គមយ៉ាងមិចទៅកើត បើវាជាប្រទេសរបស់ពួកខ្ញុំផងដែរនោះ។ ពិតណាស់ពលរដ្ឋខ្មែរទាំងនោះ ពួកគេគឺបាននិងកំពុងតែគិតពីសង្គមរបស់ពួកគេពិតមែន បើតាមតែយើងមើលឃើញពួកគេជាទូទៅរាល់ថ្ងៃនេះ តែការគិតជាតិរបស់ពួកគេនោះសោធ គឺបានត្រឹមតែម៉ាគិតតែប៉ុណ្ណោះ គឺពួកគេមិនបានគិតប្រទេសទៅជាមួយនិង**ឧស្សុះ ចក្ខុវិស័យ មនសិការ និង ឧត្តមគតិជាតិ**

នោះទេ គឺពួកគេគិតជាតិតាមតែរបៀបភ្លើងឆេះចម្បើង តាមតែរបៀបសាមញ្ញធម្មតាៗតែប៉ុណ្ណោះ គិតជាតិតាមតែរបៀបទម្លាប់ឡេឡេជាទម្លាប់របស់ពួកគេតែប៉ុណ្ណោះ ហើយសូមកុំសួរពួកគេបន្តទៅទៀតចំពោះអារឿងតាមដានអារឿងនយោបាយជាតិ ការជួយដាំបណ្តុះអំពើល្អសម្រាប់ជាតិ និងសិល្បៈក្នុងការពារជាតិ ដើម្បីទប់ស្កាត់ពីការហូរចូលមនោគមន៍របស់បរទេស និងពូជសាសន៍ជិតខាង ដោយរបៀបណាដោយបែបណានោះមិនចាំបាច់ឡើយ។ តើស្គាល់មិត្តស្គាល់សត្រូវទេ? គឺពួកគេឆ្លើយបានគ្រប់ៗតែសំនួរទាំងអស់គឺមិនដែលចេះទាក់ម្តងណាឡើយ ទាំងក្នុងដៃរបស់ពួកគេដែលកំពុងមានវត្តមានដបស្រា កែវស្រា និងទាំងដែលមានវត្តមានស្រាយ៉ាងដោគដាំ នៅក្នុងខ្លួនរបស់ពួកគេផងនោះ ដែលស្រាកំពុងតែចូលរុករៀនទន្ទ្រានសណ្តំចិត្តគំនិត និងសតិប្រាជ្ញាស្មារតីរបស់ពួកមនុស្សទាំងនោះ ឲ្យបានកំពុងតែប្រែក្លាយទៅជាគំនិតសត្វតិច្ឆានធ្លួតបាត់ទៅហើយនោះ ទាំងដែលពួកគាត់មិនអាចនិងបើកភ្នែករួចពីអំណាចស្រាផងនោះ។ ធ្លាប់តាមតែបានដឹង និងបានឃើញកន្លងមកហើយទៅលើសកម្មភាព និងជីវភាពតាមស្ថានភាពពិតជាក់ស្តែងរបស់ពួកគាត់ ដែលជាប្រជាពលរដ្ឋខ្មែរទាំងនោះ ពិសេសពលរដ្ឋខ្មែរមួយចំនួនធំ ស្ទើរថាទូទាំងប្រទេសយើងអាចហ៊ានថាជាង៩០% ដែលពួកគេបានសេពសុរាសឹងគ្រប់វ័យគ្រប់ឋានៈគ្រាប់ជាន់ថ្នាក់ មានចាប់តាំងពីកុមារ សិស្ស-និស្សិត គ្រូបង្រៀន មន្ត្រីរាជការ

គ្រប់ស្ថាប័ន ពពួកលោកសង្ឃអលជ្ជី(**មិនចេះខ្មាស់អៀន**)មួយចំនួន ឪពុកម្តាយ កម្មករ-កម្មការិនី និងពពួកមនុស្សកញ្ជាស់ក្បាលទំនើងៗមួយចំនួនផងដែរនោះ ដែលកំពុងតែបង្ហាញ និងកំពុងតែពង្រីកនូវទង្វើដ៏ថោកទាបដ៏លាមកដ៏ចោលម្សៀត របស់ពួកខ្លួនគេទាំងនោះជាគំរូដ៏អាក្រក់បំផុត ដែលកំពុងតែបង្ហាញនិងកំពុងតែបញ្ចូលទិន្នន័យអាក្រក់ៗទាំងនោះ ឲ្យទៅដល់កូនចៅរបស់ពួកគេ ដែលកំពុងតែរស់នៅក្នុងសង្គមមួយនេះឲ្យពួកគេ (**ក្មេងៗជំនាន់ក្រោយ**)នោះបានឃើញនិងយកជាគំរូអាក្រក់នោះ ដើម្បីនិងបំផ្លាញសង្គមជាតិរបស់ខ្លួន ទាំងដែលពួកគេកំពុងតែរស់នៅ និងនៅមានទាំងកូនចៅរបស់ពួកគេផងដែរនោះ។ ទាំងនេះហើយដែលជាភាពផ្ទុយស្រឡះឆ្ងាយបំផុតដូចមេឃនិងដីអញ្ចឹង រវាងពាក្យសម្តីដែលពួកខ្លួនគេ ដែលធ្លាប់បាននិយាយកន្លងមកថា ពួកគេជាអ្នកស្រឡាញ់ជាតិ ជាអ្នកយកចិត្តទុកដាក់គិតពីសង្គមណាស់ និងស្រលាញ់សង្គមពិសេសគឺថា ស្រឡាញ់គ្រួសាររបស់ពួកគេខ្លាំងណាស់នោះ តែជាតុពិតជាក់ស្តែងអ្វីៗ ឃើញថាវាផ្ទុយស្រលះពីការពិតទាំងអស់ ពីពាក្យសម្តីដែលពួកគេធ្លាប់តែបាននិយាយពីមុនមកនោះ របស់ពួកគេទាំងអស់ ទាំងដែលរាល់ទង្វើសកម្មភាព ហើយអ្វីដែលពួកគេកំពុងធ្វើកំពុងតែពង្រីកនូវពេលសព្វថ្ងៃនេះសោធ គឺថាជាផ្លូវដែលបានកំពុងតែបង្ហាញនូវដំណើរនាំទៅឲ្យរលំរលាយសង្គមជាតិ និងគ្រួសារដែលជាទីស្រឡាញ់របស់

ពួកគេនោះទៅថែមទៀតផង។ តែដោយភាពធ្វេសប្រហែសរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានផ្នត់គំនិតយល់ខុសបានបាក់ទៅជាទម្លាប់អាក្រក់មិនសូវចេះខ្វល់ខ្វាយពីសង្គមជាតិនយោបាយជាតិរបស់ពួកខ្លួន តាំងតែពីច្រើនសតវត្សរ៍តកូនតចៅកន្លងមកហើយនោះ ក៏ពួកគេនិយាយឡើងថាយ៉ាងមិច គ្រាន់តែផឹកស្រាសោះហ្នឹងវានិងធ្វើឲ្យរលំរលាយជាតិទៅកើតដែររឺ?«**គំនិតខ្វី គិតខ្វី ល្ងង់ខ្លាំង អំនួតច្រើន**»នេះគឺជាចរិតពូជសាសន៍ដែលធ្លាប់បាត់ដីកន្លងមកនោះឯង។

## ((ពិភពលោកនេះ))

ពិភពលោកមួយនេះ វាប្រៀបបានទៅនឹងឆាកល្ខោន គឺវាមានតែការចេញចូលៗតែប៉ុណ្ណោះ។ ពិភពលោកមួយនេះប្រៀបបានទៅនឹងមន្តអាគមន៍ ដ៏ពូកែស័ក្តិសិទ្ធ សម្រាប់សណ្តំនូវដួងវិញ្ញាណឬដួងប្រលឹងរបស់មនុស្សលោកទូទៅឲ្យលុងវង្វេងងប់ងុលទៅនិងខ្លួនរបស់វា ហើយវាក៏ប្រៀបដូចជាបុគ្គលអ្នកស្ទាត់ជំនាញខាងលេងប៉ាហីយ៉ាងពូកែ សម្រាប់សម្តែងជូនឲ្យបានដល់អ្នកមើល៍ឲ្យបានដល់អ្នកទស្សនា ដើម្បីបណ្តាលចិត្តបណ្តាលអារម្មណ៍ ឲ្យមានចិត្តជឿស្លុងទៅលើការសម្តែងនោះថា គឺជាការពិតយ៉ាងណានោះ គឺថាពិភពលោកមួយនេះក៏វាយ៉ាងដូច្នោះដែរ។

ដូច្នេះហើយការប៉ុនប្រសព្វ ក្នុងការបញ្ចូលមនោគមន៍ដើម្បីបន្លំបំភាន់ភ្នែករបស់ពិភពលោកមួយនេះ ចំពោះមនុស្សសត្វទូទៅក្នុងវដ្តៈសង្សារនេះ គឺថាវាកំពុងតែបង្អួត និងបង្ហាញរូបរាងរបស់វាយ៉ាងស្អាតស្រស់បំព្រមយ៉ាងសង្ហា នៅលើផ្ទាំងភពផែនដីដ៏ធំទូលាយមួយនេះ ហើយវាក៏កំពុងតែជ្បិនភ្នែកបន្លំភ្នែក និងកំពុងតែបង្វក់ក្នុងខួរក្បាលរាល់ដួងវិញ្ញាណ របស់មនុស្សលោកទូទៅដែលកំពុងរស់នៅក្នុងលោកទាំងមូលនេះ ឲ្យកំពុងតែមានការជឿស៊ប់ទៅលើវាយ៉ាងស្លុងទៀតផង។ ផែនដីមួយនេះវាបានកំពុងតែធ្វើឲ្យ សត្វលោកមានការភាន់ច្រឡំយ៉ាងខ្លាំង និងឲ្យមានគំនិតប្រកាន់យ៉ាងខ្ជាប់ថា ពិភពលោកមួយនេះវាពិតជាស្រស់បំព្រមនិងស្ថិតស្ថេរយ៉ាងពិតប្រាកដមែន។

ភាពវង្វេងនិងភាពភាន់ច្រឡំ នៃមនុស្សលោកជាទូទៅក៏បានចាប់ផ្តើមដុះដាលទៅជាបណ្តើរៗក្នុងភាពងងឹតអន្ធការនោះ គឺមានការយល់ច្រឡំពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយជំនាន់ទៅមួយជំនាន់ យ៉ាងសន្ធឹកសន្ធាប់ទៅយ៉ាងរលូន គឺវាមិនមានការទើសទាក់នោះឡើយ គឺវាបានធ្វើឲ្យមនុស្សលោកទាំងមូលនេះព្រមទទួលយកដោយខ្លួនឯងតែម្តង គឺបានធ្វើឲ្យអស់ចម្ងល់តែម្តង គ្មានចេះឆ្ងល់គ្មានសំនួរ សម្រាប់សួរពិភពលោកមួយនេះ ដើម្បីរកការពិតរកហេតុផលរកមូលហេតុសម្រាប់ពិភពលោកមួយនេះគឺគ្មាននោះឡើយ។

(**ព្រះពុទ្ធ**)ទ្រង់ត្រាស់សម្ដែងថា (***អវិជ្ជា***)ជាភាពងងឹត ដែលជាឫសគល់ជាហេតុខាងដើម ដែលវាជាហេតុបណ្ដាលឲ្យសត្វលោកទាំងមូលនេះ មានការវង្វេងភាន់ច្រឡំថា ពិភពលោកមួយនេះគឺជាឋានសួគ៌ ដែលមានធម្មជាតិដ៏ស្រស់ស្អាតពិតជាមានការឋិតថេរ សម្រាប់ពួកគេយ៉ាងពិតប្រាកដមែនៗ តែតាមពិតពិភពលោកមួយនេះ គឺមិនដូច្នោះឡើយ គឺវាមិនដូចអ្វីដែលយើងធ្លាប់បានគិតនោះទេ តែជាការពិតគឺវាមានការប្រែប្រួលទៅជាលំដាប់លំដោយទៅតាមច្បាប់ដំណើរធម្មជាតិរបស់វាជានិយាម ប៉ុន្តែដោយសារតែភាពអវិជ្ជារបស់ពួកសត្វទាំងនោះ មានការងងឹតភាន់ច្រឡំមើលមិនឃើញគិតមិនយល់ដឹងមិនដល់ នៅសភាពប្រែប្រួលរបស់ពិភពលោកមួយនេះឯងហើយ ក៏បានបណ្ដាលធ្វើឲ្យពួកគេកំណត់យ៉ាងដាច់អហង្ការថា ពិភពលោកមួយនេះគឺទៀងយ៉ាងពិតប្រាកដ ដោយគ្មានលក្ខណ្ឌនោះឡើយ។

ដោយមានភាពងងឹតឈឹង វង្វេងវង្វាន់ភាន់ច្រឡំគ្មានទីបញ្ចប់យ៉ាងដូច្នេះហើយ ទើបបានជាវាចេះតែកើតមានឡើង នៅបញ្ហាអសន្តិសុខទាំងឡាយមិនចេះឈប់ឈរសោះនោះឯង គឺវាបានចាប់ផ្ដើមកើតមានឡើងជាបន្តបន្ទាប់នៅក្នុងពិភពលោកមួយនេះ គឺគ្មានដែលថ្ងៃណាមួយបានរលួសម្ដងសោះនោះឡើយ គឺតែងតែកើតមានព្រឹត្តិការណ៍ផ្សេងៗគ្រប់សព្វបែបយ៉ាងមានដូចជាអ្នកធំធ្វើបាបអ្នកតូច ភាពល្មោភលោភលន់បានកាន់តែកើតមាន

ច្រើនឡើងៗគ្រប់ស្រទាប់វណ្ណៈ ការកេងប្រវ័ញ្ច លួចឆក់ប្លន់ សម្លាប់ ធ្វើទារុណកម្ម និងការចាប់រំលោភបំពារបំពានតាមផ្លូវកាយ និងផ្លូវចិត្ត ដែលបានកំពុងធ្វើទុកទោសឲ្យបានដល់រៀងគ្នានិងគ្នា មានការឈឺចាប់មានការភ័យខ្លាច នៅគ្រប់ទិសទីមាននៅគ្រប់ទីកន្លែងក្នុងសង្គមជាតិ ក៏ដូចជាសង្គមពិភពលោកទាំងមូលផងនោះ។ ដូច្នេះហើយការខំប្រឹងសព្វថ្ងៃ ក្នុងជីវិតរស់នៅជាមួយនិង**អវិជ្ជា** ភាពងងឹតងងុលវង្វេងស្លុប នៅក្នុងពិភពលោកមួយនេះដោយការប្រេកាប់ប្រចាក់គ្នាជាដើមនោះ គឺដោយសារតែពួកគេបានកំពុងតែយល់ច្រឡំនិងបានយល់ថាពិភពលោកមួយនេះ គឺវាពិតជាពិភពស្ថិតស្ថេរជាដរាបជារបស់ពួកគេពិតប្រាកដនោះឯង។ ពួកគេបានគិតថា បើពួកគេអាចយកឈ្នះមនុស្សមួយពិភពលោកនេះបាន ដោយមធ្យោបាយផ្សេងៗ ទោះបីមធ្យោបាយថោកទាបក្តី គឺពួកគេមិនខ្វីនឹងខ្វល់នោះទេ សំខាន់ឲ្យតែពួកគេបានយកឈ្នះគេនោះគឺវាបានហើយ នរណាងាប់ឯណាគឺពួកគេមិនខ្វីនឹងខ្វល់។ ឱ! ពិភពលោកដ៏ស្រស់បំព្រមសម្រាប់ភ្នែកមនុស្សល្ងង់ភ្លើទាំងឡាយអើយ! អ្នកកំពុងតែវង្វេងភាន់ច្រឡំយ៉ាងងងឹតពេកណាស់ ក្នុងសម្រស់មិនទៀងទាត់របស់ខ្លួននោះ ទាំងដែលកំពុងតែនាំមនុស្សទូទាំងពិភពលោកទាំងមូលនេះ ឲ្យកំពុងតែឈ្លក់វង្វេងតាមខ្លួនថែមទៀតផង។ ដំណើរត្រង់ត្រូវដំណើរព្រះមានរួចស្រេចទៅហើយ ព្រមទាំងមានបុគ្គលមួយចំនួនធំក៏បានធ្វើដំណើរទៅដល់ហើយផង

ដែរអ្នកក៏បានដឹង ខ្ញុំក៏បានដឹង ចុះចាំពេលណាយូរប៉ុណ្ណាទៀត ទើបបានពួកយើងនិងសម្រេចចិត្តដើរទៅតាមព្រះទៅ ឬក៏ពួកយើងនៅតែនាំគ្នាបន្តប្រកាប់ប្រចាក់គ្នាតទៅទៀត? មនុស្សរស់យ៉ាងយូរបានត្រឹមមួយរយឆ្នាំតែប៉ុណ្ណោះ។

ការសម្លឹងឲ្យឃើញ និងចាំផ្តើមនាំគ្នាចេះសិក្សាស្វែងយល់រកហេតុផលឲ្យបានយល់ច្បាស់ពីច្បាប់នៃធម្មជាតិជាមុននោះ និងនាំគ្នារៀនចេះទទួលស្គាល់បញ្ហាចំពោះមុខ ចំពោះស្ថានភាពពិតនោះ នេះឯងគឺជាចំណុចដ៏សំខាន់មួយ ក្នុងការជួយដោះស្រាយបញ្ហារួមរបស់មនុស្សលោកទាំងមូលនោះឯង។ ការសិក្សាស្វែងយល់អំពី (**អនិច្ចំ** មិនទៀង **ទុក្ខំ** ជាទុក្ខ **អនត្តា** មិនជាខ្លួន មិនជារបស់ខ្លួន ) នាំគ្នាចេះរៀនពិចារណានូវធម៌ទាំងបីនេះឲ្យបានរឿយៗនិងបានគ្រប់ៗគ្នាទៅនោះ វានិងបណ្តាលធ្វើឲ្យចិត្តរបស់ពួកអ្នក ដែលមានការព្យាយាមពិចារណាទាំងប៉ុន្មាននោះ និងនាំឲ្យចិត្តធ្លាក់ទៅដល់ចំណុចថ្នាក់ចិត្តពាល់ត្រូវមួយ គេហៅថាថ្នាក់ចិត្ត **សង្វេគ** ចំពោះសព្វសត្វ និងសង្ខារទាំងឡាយនោះបាន គឺជាចំណុចមួយដ៏ពិសេស ដ៏មានខ្លឹមសារយ៉ាងក្រៃលែងក្រៃពេក គឺដើម្បីធ្វើឲ្យចិត្តមនុស្សម្នាក់ៗដែលបានពាល់ត្រូវនោះមាន**មេត្តា**សេចក្តីស្រឡាញ់ **ករុណា**សេចក្តីអាណិតអាសូរចំពោះគ្នានិងគ្នា យ៉ាងពិតជាក់ប្រាកដផងដែរ ចំណែកឯ«**សមាធិ**»វិញគឺជាចំណុចនិងគោលការណ៍រួមធំ

មួយដ៏សំខាន់ ក្នុងការដោះស្រាយបញ្ហារួមសព្វគ្រប់បែបយ៉ាងទាំងអស់ឲ្យបាន ដល់គ្រប់ស្រទាប់វណ្ណៈគ្រប់ផ្នែក និងគ្រប់សសៃចរន្តទាំងអស់ បើមនុស្សលោកទាំងអស់គ្នានោះ និងមានគំនិតភ្ញាក់កំណើតភ្ញាក់រឭកចេះចាប់យក **សមាធិ** នេះយកមកអនុវត្តន៍ ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេនោះ គឺថារិតតែពិសេសបំផុតទៅទៀត សម្រាប់ពិភពលោកយើងទាំងមូលនេះតែម្តង។

ពិភពលោកមួយនេះគឺជាឋានសួគ៌ទាំងស្រុង សម្រាប់ភ្នែកមនុស្សល្ងង់ទាំងឡាយ តែមួយចំណែកនៃពិភពលោកមួយនេះក៏គឺជាឋាននរក សម្រាប់ភ្នែកពួកលោកអ្នកត្រាស់ដឹងនិងពួកលោកទស្សនវិទូបណ្ឌិតអ្នកប្រាជ្ញសប្បុរសទាំងឡាយនោះផងដែរ។

# ពលរដ្ឋខ្មែរស៊ាំក្នុងទុក្ខលំបាក

ការស៊ាំក្នុងភាពទុក្ខលំបាកវេទនា ពីមួយជំនាន់ទៅមួយជំនាន់ របស់ប្រជាពលរដ្ឋខ្មែរ ដែលត្រូវបានរងទុក្ខទោសពីអំពើឃោរឃៅទាំងឡាយ ដែលមានការកាប់សម្លាប់ និងការធ្វើទារុណកម្មសព្វគ្រប់បែបយ៉ាងមកលើប្រជាពលរដ្ឋក្នុងប្រទេសជាយូឆ្នាំ យ៉ាងវេទនាព្រៃផ្សៃបំផុតស្ទើស្លាប់ស្ទើរស់ សឹងតែគ្រប់ៗរបបគ្រប់ៗជំនាន់មកហើយនោះ ដែលវាគឺជាមូលហេតុដែលបានកើតឡើងមកតែពីការដឹកនាំខុសពីមេដឹកនាំប្រទេស (**ដែលមិនដែលចេះ**

ឈ្នះខ្លួនឯងជាមុនម្តងណាសោះនោះ) ពីមេដឹកនាំម្នាក់ទៅមេដឹកនាំម្នាក់ មើលមិត្តមើលសត្រូវមិនដែលចេះយល់ទាល់តែសោះ បែរជាយកសត្រូវធ្វើជាមិត្ត យកមិត្តធ្វើជាសត្រូវទៅវិញ សម្រេចលទ្ធផលចុងក្រោយមកងាប់តែពលរដ្ឋខ្មែរខ្លួនឯងគឺងាប់អស់ជាង៣លាននាក់ជាងនោះឯង អស់៣លាននាក់ប៉ុណ្ណឹងហើយ មេដឹកនាំចោលម្សៀតខ្មែរមួយចំនួននោះគឺនូវតែមានចិត្តអំនួតអួតកើតបានទៀត គឺគេប្រកាសស្រែកក្តែងៗថាគេបានយកជ័យជម្នះទៅលើសត្រូវបានហើយ តើពីណាគេជាសត្រូវនិងពួកគាត់នោះ?ប្រហែលជាពូជសាសន៍ឈាមពូជសាសន៍ជាមួយពួកគាត់នុងហើយមើលទៅ។ ហើយគេចង់និយាយយ៉ាងមិចថាយ៉ាងមិច វាគឺជារឿងរបស់ពួកគេ(មេដឹកនាំចោលម្សៀត)គឺស្រេចតែពួកគេថាទាំងនោះទៅ គឺទុកពួកចោលម្សៀតមួយកន្លែងសិនចោះ។ តែអ្វីដែលសំខាន់និងត្រូវតែដឹង និងត្រូវតែនាំគ្នាធ្វើបន្តទៅទៀតនោះ គឺត្រូវតែនាំគ្នាមកចាប់អារម្មណ៍និងការអាននិងស្រាវជ្រាវពីប្រវត្តិសាស្ត្រជាចាំបាច់ខានមិនបាន ចាំបាច់ត្រូវតែនាំគ្នាអានក្នុងនាមជាពលរដ្ឋជាម្ចាស់ប្រទេស តើខំនាំគ្នាស្វែងយល់ពីប្រវត្តិសាស្ត្រដើម្បីអ្វី?គឺដើម្បីឲ្យបានដឹងច្បាស់ថា តើមេដឹកនាំរូបណាមួយដែលជាមេដឹកនាំដែលមានមនសិការនិងឧត្តមគតិជាតិពិតប្រាកដ និងមេដឹកនាំរូបណាមួយដែលគ្មានមនសិការនិងឧត្តមគតិជាតិពិតប្រាកដនោះ និងឲ្យដឹងថាអ្នកណាមិត្តអ្នកណាសត្រូវឲ្យប្រាកដ នៅក្នុងរបប

មេដឹកនាំខ្មែរយើងពីមួយជំនាន់ទៅមួយជំនាន់ពីម្នាក់ទៅម្នាក់នោះឯង។ ការចេះនាំគ្នាមកចាប់អារម្មណ៍ការអានពីប្រវត្តិសាស្ត្រ ក្នុងប្រទេសរបស់ខ្លួនដូច្នេះហើយ ទើបអាចធ្វើឲ្យពួកយើងនិងបានដឹងច្បាស់ពីអត្តចរិតពិតៗ ក្នុងការដឹកនាំប្រទេសរបស់ពួកលោកទាំងនោះបានយ៉ាងច្បាស់ជាមិនខាន។

ក្នុងចំណុចនេះខ្ញុំចង់និយាយចំពោះតែមេដឹកនាំដែលដឹកនាំអសមត្ថភាពសម្រាប់ប្រទេសជាតិតែប៉ុណ្ណោះ ដើម្បីយកមកលាតត្រដាងឲ្យបានច្រើនជាជាងមេដឹកនាំដែលមានសមត្ថភាពក្នុងការដឹកនាំប្រទេស គឺចង់និយាយថាមេដឹកនាំទាំងនោះ (**មេដឹកនាំដែលអសមត្ថភាព**) ដំបូងដៃគឺពួកគេមិនដែលយកឈ្មោះខ្លួនឯងនេះជាមុនទាល់តែសោះតែម្តងទី**១**; សន្តានមានមនោសញ្ចេតនាតិចណាស់ចំពោះជាតិនិងពលរដ្ឋ**២**; ខ្វះទស្សនវិស័យ**៣**; គ្មានចក្ខុវិស័យ**៤**; មិនដឹងនិងថាដឹកនាំប្រទេសនិងទៅណាឲ្យពិតប្រាកដ**៥**; ក្នុងការគ្រប់គ្រងប្រទេសជាតិរបស់មេដឹកនាំទាំងនោះ គឺបានធ្វើឲ្យប្រជាពលរដ្ឋរបស់ពួកគេរងនៅការឈឺចាប់យ៉ាងក្រៃលែង រហូតដល់ធ្វើឲ្យពលរដ្ឋមានជម្ងឺបាក់ស្បាត ស្ទើតែគ្រប់ៗគ្នាទៀតផង។ ភាពបាក់ស្បាតជម្ងឺបាក់ស្បាត់មួយនេះ គឺជាមេរោគដ៏កាចសាហាវនិងចង្រៃបំផុតមួយ សម្រាប់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងតែត្រូវរងនៅការបំផ្លាញនូវសតិអារម្មណ៍ របស់ប្រជាពលរដ្ឋខ្មែរជារៀងរហូតមក ហើយក៏ជាស្រមោលអន្ធកាល ដែលកំពុងតែដើរលងបន្លាច

ពូជសាសន៍ខ្មែរមួយនេះជារៀងរហូតមកនោះ ហើយបានកំពុងធ្វើឲ្យខ្មែរកាន់តែអន់ថយខ្សោយទៅៗ ពីមួយជំនាន់ទៅមួយជំនាន់ថែមទៀតផង។ គឺវាបានកំពុងតែធ្វើឲ្យពលរដ្ឋខ្មែរ លែងចង់គិតខ្វល់អ្វីៗទាំងអស់ ក្រៅតែពិការសុំគេត្រឹមតែមួយរស់ៗនោះឯងតែប៉ុណ្ណោះ ទោះបីជារស់ក្នុងស្ថានភាពក្រលំបាកល្វេមល្វាមវេទនាយ៉ាងណាក៏ដោយចុះ ក៏ពលរដ្ឋខ្មែរទាំងនោះក៏ចេះតែស៊ូទ្រាំរស់និងគេទៅបាន ហើយជម្ងឺបាក់ស្បាតមួយនេះ ដែលចេះតែធ្វើឲ្យខ្មែរខ្លាច ឲ្យខ្មែរចេះតែរត់គិចពីបញ្ហាឲ្យខ្មែរចេះតែលែងចង់ដឹង ចង់ឮពីរឿងនយោបាយស្រុកទេស លែងចង់ដឹកពីពត៌មានក្នុងស្រុក ទាំងដែលលែងចង់គិត និងលែងចង់តាមដានក្នុងការដឹកនាំប្រទេស របស់រដ្ឋាភិបាលរបស់ខ្លួនសព្វថ្ងៃនេះថែមទៀតផង។

ទោះបីជាគេ(**រដ្ឋាភិបាល**)ដឹកនាំរីកចម្រើនក្តី មិនរីកចម្រើនក្តី បរទេសចូលមកយកទឹកដីក្តី ចូលមកគ្រប់គ្រងរដ្ឋបាលក្បាលពួកខ្លួនក្តី បរទេសគេមើលងាយមើលថោកខ្មែរក្តី ក៏ពលរដ្ឋខ្មែរខ្ជិលលែងចង់គិត លែងចង់ខ្វល់ទាំងអស់ទៅហើយ។ អារឿងបញ្ហាជម្ងឺបាក់ស្បាតពិតណាស់ វាជារឿងជម្ងឺបាក់ស្បាត គឺយើងទទួលស្គាល់ ប៉ុន្តែតើពួកយើងអាចទុកវាមួយលែកសិនបានទេ? តែខ្ញុំសូមសួរមួយសំនួរថា: តើពួកអ្នកដែលជាពលរដ្ឋខ្មែរ សាកសមជាម្ចាស់ប្រទេសដែរឬទេ តើម្ចាស់ប្រទេសដែលមានតែគំនិតបាក់ស្បាតដូចជាពួកអ្នកអញ្ចឹងតើសាកសមជាម្ចាស់ប្រទេសដែរទេ? បើពួកអ្នកនៅតែបាក់ស្បាត

យ៉ាងនេះនោះ តើពួកអ្នកប្រឹងនាំគ្នាបង្ខំបង្កើតកូនឲ្យមករងទុក្ខវេទនាធ្វើអ្វី?ឲ្យគ្នាមករស់នៅវេទនាលើទឹកដីនេះធ្វើអ្វី? ការបាក់ស្បាតខ្ញុំទទួលស្គាល់ តែពេលខ្លះក៏ជាលេះក្នុងភាពអាត្មានិយម ដោយខ្ជិលគិតដោយមិនចង់គិត ដោយមានគំនិតអាត្មានិយមចោលម្សៀត ចង់គិចវេសពីការទទួលខុសត្រូវមកលើសង្គមរបស់ខ្លួនឯងតែប៉ុណ្ណោះទៅវិញនោះទេ។ តើអ្នកមិនដឹងទេថា ភាពបាក់ស្បាត និងភាពអាត្មានិយម ដែលចេះតែជម្រុញមិនចង់ឲ្យពួកយើងតាមដាន នយោបាយ ពត៌មាន និងតាមដានក្នុងការដឹកនាំប្រទេស របស់រដ្ឋាភិបាលនោះ តើពួកអ្នកដែលជាម្ចាស់ប្រទេសនឹង មិនដឹងថាកំពុងតែបើកផ្លូវ បើកឱកាសទុកឲ្យអាចោរក្នុងស្រុក និងអាចោរនៅក្រៅស្រុកវាចូលមកក្នុងការឈ្លានពានទឹកដី និងការពង្រឹងអំណាចផ្តាច់ការក្នុងស្រុក ដើម្បីគេជាន់ក្បាលយើងតជំនាន់កូនចៅយើងទេរឺ? សម័យកាលនេះហើយ តើពិភពលោកគេដើរទៅដល់ណាអស់ហើយបងប្អូន? ពលរដ្ឋខ្មែរយើងគួតែនាំគ្នាឆាប់ភ្ញាក់រឭកមកវិញហើយ។

តែដោយភាពអាត្មានិយមភាពទម្រុន បានក្លាយទៅជាទម្លាប់ បានដុះស្អិតក្នុងសន្តានបេះដូងរបស់ប្រជាពលរដ្ឋខ្មែរទៅហើយនោះ គឺជាមូលហេតុដ៏ចង្រៃនៅខាងដើមដែលធ្វើឲ្យខ្មែរកែចរិតលែងចង់ឡើង។ ទោះបីមានកូនខ្មែរណាម្នាក់មានសមត្ថភាព មានមនសិការឧត្តមគតិជាតិគ្រប់គ្រាន់ ក្នុងការ

ពន្យល់ឲ្យពលរដ្ឋខ្មែរមានស្មារតីភ្ញាក់ឡើងវិញ ឲ្យចេះគិតចេះមើលពិភពលោកឡើងវិញយ៉ាងណាក៏ដោយនោះក្តី ក៏ពលរដ្ឋខ្មែរមួយនេះមិនព្រមនាំគ្នាចង់ក្រោកឡើងដដែល គឺចេះតែម៉្យាងប៉ុណ្ណោះគឺចង់តែមានបាន ចង់តែរស់ប៉ុណ្ណោះចង់នោះចង់ ចង់ទាំងភ្លើទាំងល្ងង់ ចង់អាណាខំពន្យល់ឯណា អាណាស្នេហាជាតិឯណា អាណាខំមកបបួលអញនាំអញ មកគិតគួរអារឿងជាតិកសាងសង្គមជាតិ ឲ្យរីកចំរើនយ៉ាងណានោះក៏ដោយក្តីគឺអញមិនខ្វីខ្វល់ កុំឲ្យតែមកហាមឃាត់កូនចៅអញមិនឲ្យទៅធ្វើកញ្ជះគេ នៅស្រុកគេទៀតទៅគឺវាបានទៅហើយ គឺអញមិនខ្វល់នោះទេ។ នេះឯងដែលជាភាពសុាំយ៉ាងចាក់ស្រេះ យ៉ាងក្រញាញ់ខួរ ក្នុងផ្នត់គំនិតនៅក្នុងខួរក្បាលរបស់ពលរដ្ឋខ្មែរ មួយចំនួនធំនោះឯង។ តើឯណាទៅភាពថ្លៃថ្នូររបស់ពលរដ្ឋខ្មែរ ដែលមានប្រទេសមួយនិងគេដែរនោះ? តើឯណាទៅតម្លៃ និងមុខមាត់ប្រទេសពូជសាសន៍ដូនតាជាអ្នកកសាងអង្គររបស់ពួកអ្នកនោះ? ពួកអ្នកមិនព្រមចង់**ដឹង ចង់ឮ ចង់គិត ចង់ខ្វល់ ពីប្រទេសជាតិ** របស់ពួកខ្លួនគឺវាមិនថ្វីទេ តែអ្វីដែលកាន់តែគ្រោះថ្នាក់ខ្លាំងបំផុតនោះ គឺពលរដ្ឋខ្មែរបានភ្លេចខ្លួនឯងភ្លេចអត្តសញ្ញាណខ្លួនឯងថែមទៀតផង ទាំងដែលនាំគ្នាចង់តែទៅធ្វើការ និងទៅធ្វើកញ្ជះគេ នៅឯស្រុកគេទាំងខុសច្បាប់ទៀតនោះ ខ្លះត្រូវគេមើលងាយ ខ្លះត្រូវគេសម្លាប់ចោលខ្មោចយ៉ាងវេទនា ដូចខ្មោចឆ្កែខ្មោចឆ្មានៅស្រុកគេថែមទៅទៀតផងនោះ។ នេះឬកូន

ថៅពូជដូនតាអ្នកកសាងអង្គរនោះតើឯណាទៅដែលជាតម្លៃរបស់ពលរដ្ឋ ដែលមានប្រទេសមួយនិងគេដែរនោះ? តើតម្លៃប្រទេសជាតិរបស់ពួកអ្នក បង្កើតពលរដ្ឋមកបានត្រឹមតែមិនចេះខ្វាយខ្វល់ពីសង្គម និងសម្រាប់តែនាំគ្នាទៅធ្វើកញ្ជះគេ នៅគ្រប់ៗតែបណ្ដាប្រទេសអញ្ចឹងរឺ? នេះឬពូជឈាមដូនតាជាអ្នកកសាងអង្គរនោះ?បើខ្ញុំដាក់សំនួរសួរ ពិតណាស់អ្នកនិងឆ្លើយតបវិញថា ស្មានតែពួកខ្ញុំចង់ទៅធ្វើការងារជាកញ្ជះគេនៅឯស្រុកគេណាស់ទៅរឺ? គឺវាមកតែពីជីវភាពនៅក្នុងស្រុកវាបង្ខំខ្ញុំទេតើ ទើបបានជាពួកខ្ញុំទៅ បើនៅក្នុងស្រុកមានសេដ្ឋកិច្ចរារីកចម្រើននោះគឺពួកខ្ញុំចេះតែនៅហើយ ពួកខ្ញុំមិនខ្វីនិងទៅធ្វើកញ្ជះនៅឯស្រុកគេនោះទេ តែមកមើលសេដ្ឋកិច្ចក្នុងស្រុកខ្មែរមើល៍ គឺវាធ្លាក់ចុះដល់កម្រិតណាទៅហើយ រកតែការងារធ្វើពិបាកចង់ងាប់ទៅហើយនឹង? អាគ្មានការងារធ្វើវាមធ្យមទេ តែអាងំមានជនបរទេសអាខាងកើត វាមកដណ្ដើមការងារពលរដ្ឋខ្មែរក្នុងស្រុកធ្វើថែមទៀតផងនោះ តើមិនឲ្យខ្ញុំបង្ខំចិត្តទៅធ្វើការនៅស្រុកគេដូម្ដេចនិងកើតទៅ?។ ពិតណាស់វាមានរឿងបែបនេះពិតមែន គឺមិនខុសនោះទេក្នុងការឆ្លើយតបរបស់ពួកអ្នកមកនោះ ប៉ុន្តែអ្នកត្រូវដឹងឲ្យបានច្បាស់ថា នេះគឺជាបញ្ហាហើយៗក៏វាមិនមែនជាបញ្ហាតូចតាចនោះផងទេ តែវាគឺជាបញ្ហាធំហើយក៏ជាបញ្ហារួមរបស់ពួកយើងទាំងអស់គ្នា ហើយក៏ជាបញ្ហាដ៏រសើបទៀតផង។ ក្នុងនាមយើងជាម្ចាស់ប្រទេសម្នាក់និងគេដែរនោះ សួរថា

ឥលូវបញ្ហាវាបានកំពុងតែកើតមានឡើង នៅក្នុងសង្គមរបស់ពួកយើងដូច្នេះហើយ សួរថាតើអ្នកណាជាអ្នកដោះស្រាយនូវបញ្ហាទាំងអស់នេះទៅ?**រដ្ឋាភិបាល អ្នកនយោបាយ ឬក៏ខ្លួនអ្នកដែលជាប្រជាពលរដ្ឋ ជាម្ចាស់ប្រទេស** ដែលជាអ្នកដោះស្រាយនូវបញ្ហាអស់ទាំងនោះ? បើទៅតាមតែទម្លាប់និងផ្នត់គំនិតមិនចង់ទទួលខុសត្រូវ ទៅលើសង្គមរបស់ពួកខ្លួនភាគច្រើននោះ ពូជសាសន៍ខ្មែរមួយនេះ ក្រោយតាំងតែពីសម័យអង្គរមកឃើញថា ដូចជាគ្មានសតិស្មារតី គ្មានព្រលឹងសូម្បីតែបន្តិចនៅក្នុងខ្លួនទាល់តែសោះស្មោះតែម្តង សឹងថាជាទូទៅទាំងអស់ពួកគេ តែងតែទំលាក់បញ្ហាទាំងអស់នេះឲ្យទៅលើមេដឹកនាំប្រទេស ដែលយើងហៅថា «***រាជរដ្ឋាភិបាល***»នោះឯងឲ្យជាអ្នកទទួលដោះស្រាយបញ្ហាទាំងអស់នោះជំនួសពួកគេទៅវិញ ឯពួកគេដែលជាម្ចាស់ប្រទេស ហើយក៏ជាអ្នករងគ្រោះខ្លាំងជាងមេដឹកនាំទៅទៀតផងនោះ បែរទៅជាពួកគេទាំងនោះមិនខ្វីគិតនាំគ្នាខ្វល់ខ្វាយ ពីការដោះស្រាយបញ្ហាប្រទេសរបស់ពួកគេនោះទេ។ ត្រង់ចំណុចនេះឯងហើយ ដែលចេះតែធ្វើឲ្យពលរដ្ឋខ្មែរយើងអត់ការងារធ្វើនោះ ហើយចេះតែនាំគ្នាទៅធ្វើការឲ្យគេល្ហាមៗនៅស្រុកគេនោះឯង អ្នកត្រូវចាំឲ្យបានច្បាស់ថា ខ្លួនអ្នកគឺជាកោសិការបស់សង្គមជាកូនសោរនៃសង្គមជាតិរបស់ពួកអ្នក រូបសំណាក់ស្តេច ឬក៏រដ្ឋាភិបាលមិនមែនជាម្ចាស់សង្គមនោះទេគ្រាន់តែជាតំណាងឲ្យសង្គមទេតើ តែពួកអ្នកគឺ

ជាម្ចាស់របស់សង្គម ជាម្ចាស់ប្រទេសជាម្ចាស់អំណាច ហើយក៏ជាម្ចាស់លើអ្នកដឹកនាំសង្គម(**ស្តេច និង៍រាជរដ្ឋាភិបាល**) នោះទៀតផង។ តាមច្បាប់ធម្មជាតិគ្មានទេ ពាក្យថា«**ស្តេច**»ឬ **អ្នកាជំឧកញ៉ា ជំទាវ ឯកាឧត្តម**។ល។នោះ ច្បាប់ធម្មជាតិគ្មានការបែងចែកអ្នកធំអ្នកតូចស្អីនោះទេ។ **អវិជ្ជា**ភាពកំឡៅរបស់មនុស្សទេតើ ដែលជាអ្នកបែងចែកថានេះ ជាមនុស្សធម្មតា គេនោះជាស្តេចគេនោះជាអ្នកធំគេនោះជាឯឧត្តមគេនោះជាលោកជំទាវ តែចំពោះច្បាប់ធម្មជាតិចំពោះ(**ជម្ទៈ**)ក្នុងក្របខណ្ឌមនុស្សគឺជាមនុស្សទូទៅស្មើគ្នា តែដោយភាពអវិជ្ជា របស់មនុស្សម្នាក់ៗដោយខ្លួនមានចំណុចណាមួយ រៀងលិចឆ្លៀជាងគេបន្តិចទៅក៏មានអំនួតអួតអាងលើកថាខ្លួនឯងជាស្តេច ជារដ្ឋមន្រ្តី ជាអ្នកធំ ជាអ្នកអស្ចារ្យជាងគេជាដើមទៅ។ល។ នៅក្នុងសង្គមមនុស្សនេះទៅវិញ។ ពិតណាស់នៅពេលដែលខ្ញុំលើកយកច្បាប់ធម្មជាតិយកមកសរសេរ យកមកសំអាងបញ្ជាក់បង្ហាញឲ្យឃើញថា ច្បាប់ធម្មជាតិ មនុស្សគឺជាមនុស្សស្មើគ្នាទូទៅទាំងអស់ ដូច្នេះហើយនិងមានមនុស្សមួយចំនួនធំបានបដិសេធ ព្រោះពួកគេទាំងនោះគេបានកំណត់មនុស្សធំតូច ទៅលើតែអ្វីដែលលើសគេដូចជាការមានចំណេះដឹងលើសគេ មានទ្រព្យសម្បត្តិច្រើនលើសគេ

**មានគំនិតលើគេ** តែប៉ុណ្ណោះ។ល។ គឺថាពួកគេមិនដែលបានមើលមនុស្សតូចធំស្ថិតក្នុងក្របខណ្ឌគុណធម៌នោះទេ។

ទោះបីខាងលើយើងសរសេរថាច្បាប់ធម្មជាតិ មិនមានការបែងចែកវណ្ណៈមនុស្សធំតូចក៏ពិតមែន តែជាការពិតជាក់ស្តែង ច្បាប់ធម្មជាតិជាអ្នកបែងចែកមនុស្សធំតូចយ៉ាងពិតប្រាកដក្រោមក្របខណ្ឌអមនិង«**គុណធម៌**» របស់មនុស្សក្រោមក្របខណ្ឌជាមនុស្សទូទៅ ។ **ឧទាហរណ៍**: ជាក់ស្តែង «**ព្រះពុទ្ធ**» គឺជាមនុស្សជាបុគ្គលដ៏ចម្បងលើសគេ លើសមនុស្ស ទេវតា មារ និងព្រមទាំងព្រហ្មទាំងឡាយ យើងចង់សួរថា: តើពាក្យថាធំសម្រាប់ព្រះអង្គផ្ទាល់គឺព្រះពុទ្ធនឹងគឺធំដោយសារអ្វី? តើព្រះអង្គមានអំនួតក្នុងតំណែងធំជាងគេ ក្នុងនាមជាមនុស្សដូចគេដែរឬទេ? តើព្រះអង្គក្នុងនាមជាអ្នកមានតំណែងធំជាងគេ យើងនិយាយថាតំណែងទៅចុះក្នុងនាមជាមនុស្សដូចគេដែរនោះ តើព្រះអង្គបានយកតំណែងនោះទៅធ្វើជាប្រយោជន៍អ្វីខ្លះ ដើម្បីឲ្យបានដល់មនុស្សទូទៅដែលបានរស់នៅខាងក្រោយៗ នៅខាងក្រោមព្រះអង្គនោះ? ហើយរហូតមកដល់បច្ចុប្បន្នសព្វថ្ងៃនេះ តើអ្វីទៅដែលនៅសល់ពីដំណើររបស់ព្រះអង្គក្នុងមួយជីវិតរបស់ព្រះអង្គនោះ? **ចម្លើយ**ទាំងនេះគឺមានតែនៅលើមនុស្សដែលចូលចិត្តស្រាវជ្រាវ និងចង់ដឹងចង់ចេះតែប៉ុណ្ណោះទេ តែបើអ្នកណា

ម្នាក់មិនខ្វីខ្វល់ចង់ដឹង មិនចង់ចេះមិនចង់ឮហើយនោះ កុំសង្ឃឹមថាបាន ចម្លើយនេះឲ្យសោះ ហើយកុំសង្ឃឹមថានិងបានមានពន្លឺប្រាជ្ញាឲ្យសោះ បើអ្នក មានចិត្តខ្ជិលច្រអូសទៅហើយនោះ។

ខ្ញុំចង់បញ្ជាក់ពីខាងដើមបន្តិចថា តំណែងជាព្រះពុទ្ធនេះក៏គឺជាធម្មជាតិ ជាអ្នកបែងចែកយ៉ាងពិតប្រាកដដែលវាស្របទៅនិងច្បាប់ធម្មជាតិ ហើយស្ថិត នៅក្នុងគុណធម៌ដែលចេញតែពីទង្វើរល្អៗពីមនុស្ស គឺបុគ្គលព្រះអង្គផ្ទាល់ នោះតែម្តង ដែលព្រះអង្គខំព្យាយាមកសាងមកអស់រាប់កប្បរាប់អសង្ខេយ្យនៃ អាយុផែនដីមកម្លេះ គឺរាប់កប្បដំណរជាតិណាស់មកហើយនោះឯង។ ផ្ទុយមក វិញតំណែងយសស័ក្តិក្នុងបច្ចុប្បន្ននេះ តើពួកគេបានមកពីណា?តើវាមិនមែន បានមកដោយអវិជ្ជារបស់មនុស្សទេរឺ? ពិតណាស់លទ្ធផលដែលបានមក ដោយអវិជ្ជា គឺជាលទ្ធផលនាំមកនៅសេចក្តីក្តៅក្រហាយឲ្យដល់ខ្លួនឯង និងអ្នក ដទៃយ៉ាងពិតប្រាកដ ទាំងដែលមិនអាចនិងនាំឲ្យពិភពលោកទាំងមូលនេះ មានសុខសន្តិភាពបានទៀតផង ប្រសិនបើពួកគេយកតំណែងទាំងនោះទៅប្រើ ប្រាស់ចាកឃ្លៀតឆ្ងាយពីគុណធម៌ជាមនុស្សនោះ បើមិនយកទៅប្រើប្រាសឲ្យ បានត្រឹមត្រូវទៅតាមគន្លងគុណធម៌ទេនោះ គឺវាជាគ្រោះថ្នាក់យ៉ាងពិតប្រាកដ ដល់សង្គមជាតិក៏ដូចសង្គមពិភពលោកទាំងមូលផងដែរ។

# ស្រុកខ្ញុំស្រុកចំឡែក

ស្រុកចំឡែកគឺជាស្រុករបស់ខ្ញុំ ដែលជាស្រុកមួយមានអ្វីៗសុទ្ធតែលើសគេ និងអស្ចារ្យជាងគេទាំងអស់មួយពិភពលោក គឺថាអ្វីៗក៏ដោយជាមនុស្សក្ដី ឬវត្ថុណានីមួយក្ដី ទោះបីអន់កម្រិតណាក៏ដោយចុះ ឲ្យតែមាននៅក្នុងស្រុកមួយនេះ គឺចង់និយាយថាសុទ្ធសឹងតែអស្ចារ្យ លើសគេទាំងអស់លើពិភពលោក។

តើស្រុកចំឡែកមួយនេះ ជាស្រុកដែលមានទឹកដីវត្ថុស័ក្ដិសិទ្ធិ គឺថាប្រាថ្នាអ្វីៗនិងបានដូចបំណង់ពិតមែនរឺ? ប្រហែលហើយមើលទៅ! ពីព្រោះគ្រាន់តែបច្ចុប្បន្ននេះ ស្រុកចំឡែកមួយនេះគេបានឲ្យឈ្មោះនិងហៅពេញៗមាត់ថាជាដែនដី«អច្ឆរិយ:»ថែមទៀតផង។ ទាំងដែលបច្ចុប្បន្នសព្វថ្ងៃម្ចាស់ស្រុកមួយនេះ ដែលកំពុងតែត្រដរស្វាសស្វែងខ្វាស់ខ្វែងដើររកការងារធ្វើ នឹងដើរសុំទីជម្រក់ទៅតាមបណ្ដាលប្រទេសផ្សេងៗជុំវិញភិភពលោក សម្រាប់ស្នាក់នៅដើម្បីរកការងារធ្វើយ៉ាងលំបាកវេទនាផងនោះ។ ភាពក្រអើតក្រទមចិត្តអំនួតអួតអាង ចេញតែពីភាពអាត្មានិយមចិត្តអាក្រក់ចិត្តអកតញ្ញូ (**មិនចេះដឹងគុណគេ**)អសមត្ថភាពក្នុងការដឹកនាំរបស់មេដឹកនាំ នៅក្នុងស្រុកចំឡែកមួយនេះគឺនៅតែមាន ទោះបីមនុស្សមួយពិភពលោក គេបានស្គាល់យ៉ាងច្បាស់នូវសង្គមមួយនេះដូចបាតដៃក៏ដោយ គេដឹងយ៉ាងច្បាស់ថាពូជសាសន៍មួយនេះ

ពលរដ្ឋនៅមានកម្រិតខាងចំណេះដឹងយ៉ាងណាក៏ដោយក្តី មានមនុស្សល្ងង់ច្រើនសណ្ឋាន មានមនុស្សអាត្មានិយមជិះជាន់ឈ្លានពានកេងប្រវ័ញ្ចយ៉ាងណាក៏ដោយនោះក្តី តែមនុស្សនៅស្រុកមួយនេះទាំងអស់ ពិសេសគឺពួកអាមនុស្សជើងកាងក្បាលដុះស្លែ ដែលនៅប្រចាំស្រុកមួយនេះទាំងអស់ គឺពួកវាខិតខំបិទបាំង ពួកវាខំនាំគ្នាហៅយ៉ាងគគ្លើនទាំងមុខក្រាស់ ដោយគ្មានចិត្តខ្មាស់អៀន សូម្បីតែបន្តិចនៅក្នុងខ្លួននោះទាល់តែសោះ គឺថាមួយមាត់ណាក៏ស្រុកគេមិនដល់ស្រុកវា មួយមាត់ណាក៏ប្រជាជនគេមិនឆ្លាតដល់ប្រជាជនរបស់ខ្លួន មួយមាត់ណាអ្នកដឹកនាំគេមិនឆ្លាតដល់អ្នកដឹកនាំរបស់ខ្លួនឯងដែរ។ និយាយមកដល់ចំណុចត្រង់នេះ សរសេរមកដល់ត្រង់នេះ ខ្ញុំមានអារម្មណ៍ថាចង់តែក្អួតយ៉ាងមិចមិនដឹងទេខ្ញុំ..! ។

និយាយឲ្យចំៗទៅគឺថាអស្ចារ្យគឺលើសគេមួយពិភពលោក គឺពួកគេបានដាក់ឈ្មោះឲ្យស្រុករបស់ពួកគេថាជាស្រុកអច្ឆរិយៈ ហើយទោះបីមេដឹកនាំអសមត្ថភាពដល់កម្រិតណាក៏ដោយចុះ គឺពួកគេនូវតែបញ្ជើចបញ្ជើរចំពោះមេដ៏មហាល្ងង់របស់ខ្លួនមួយនេះ នៅតែថាជាមេខ្លាំងឈ្លាសវៃ មហាលោតផ្លោះមហាអស្ចារ្យជារៀងរហូត! គឺថាគ្មានបុគ្គលឬមេដឹកនាំណាម្នាក់ក្នុងពិភពលោកមួយនេះ អាចមានសមត្ថភាពដឹកនាំល្អដល់មេដឹកនាំរបស់ពួកគេនោះទេ។ គឺថាឆ្កួតតាំងពីថ្នាក់លើរហូតដល់ពលរដ្ឋថ្នាក់ក្រោម និយាយឲ្យខ្លីឲ្យងាយស្រួល

ស្ដាប់ទៅ គឺថាឆ្កួតមួយនគរតែម្ដង តើហេតុអ្វីបានជាបណ្ដាលឲ្យយើងនិយាយខ្លី កំបុតយ៉ាងដូច្នេះទៅវិញនោះ? គឺវាគ្មានអ្វីក្រៅតែពីហួសចិត្តព្រោះតែវាយ៉ាប់ពេកយ៉ាប់ដល់កន្លាក់ញាប់ដល់ថ្នាក់អស់លេខដាក់នោះអី! គឺយ៉ាប់សែនមហាយ៉ាប់ គឺយ៉ាប់មើលលែងយល់កែលែងឡើងតែម្ដងនោះណា! តែពួកក្រុមវានៅតែបញ្ចើចបញ្ចើសរសើរខុសរបៀបហៅពេញៗមាត់បានទៀតផង បើនិយាយពីពាក្យថា«**សម្ដេច**»វិញសុទ្ធតែសម្ដេចសម្អុយ ដើរគៀរនិងជើងយកទៅក្រវាត់ចោលមិនចេះនិងអស់ផងទេ និងនៅមានមនុស្សសំរាមជាច្រើនប្រភេទផ្សេងៗទៀត ដូចជាទីប្រឹក្សាសំរាម ឧកញ្ញាសំរាម ឯកឧត្ដម និងលោកជំទាវសំរាមៗជាច្រើនថែមទៀត។ល។ ដែលមាននៅពាសពេញក្នុងស្រុកចំឡែកមួយនេះ គឺថាគៀរនិងជើងយកទៅក្រវាត់ចោលមិនចេះនឹងអស់នោះផងទេ នៅស្រុកចំឡែកមួយនេះ គឺសម្បូរទៅដោយពពួកមនុស្សសំរាម មនុស្សសំអុយច្រើនណាស់ ហេតុអ្វីបានជាស្រុកទាំងមូលបានក្លាយទៅជាបែបនេះទៅវិញនោះ តើពួកអ្នកកំពុងអានមានការឆ្ងល់ទេ? បើតាមតែខ្ញុំយល់គឺគ្មានអ្វីក្រៅមកតែពីពលរដ្ឋដែលកំពុងរស់នៅក្នុងស្រុកមួយនេះ តែងតែមើលមនុស្សឲ្យតម្លៃមនុស្សខុសគឺឲ្យតម្លៃមនុស្សត្រឹមតែនឹងភ្នែក និងសម្បកខាងក្រៅនោះឯង គឺពួកគេមិនដែលយកខួរក្បាល និងសន្ដានបេះដូងជាមនុស្ស របស់ពួកគេនោះមកវិនិច្ឆ័យ មកថ្លឹងថ្លែងមកឲ្យតម្លៃគុណធម៌ខាងក្នុងរបស់មនុស្សនោះឡើយ។ ដោយទិដ្ឋិយល់

ខុស និងមានភាពដ៏ល្ងង់ខ្លៅនៃពលរដ្ឋនៅក្នុងស្រុកមួយនេះ ដូច្នេះឯងហើយ ដែលជាឱកាសដ៏ល្អ របស់ក្រុមពួកអាសំរាម និងក្រុមពពួកមេសម្អុយទាំងឡាយនោះ បានរីកដុះដាលវាកាន់តែមានការកើនឡើងមនុស្សបែបៗនេះជាច្រើនពាសពេញក្នុងសង្គម រហូតមកដល់សព្វថ្ងៃនេះមិនចេះដាច់ពូជមនុស្សថោកទាបដូច្នេះនោះឯង។ ចំណែកខាង**ពួកលោកវីរបុរសជាតិ បណ្ឌិត អ្នកប្រាជ្ញ អ្នកជួយការពារជាតិ** ពួកលោកអស់ទាំងនោះ ដែលពួកលោកសំបូរទៅដោយគុណធម៌ និងទឹកចិត្តដ៏ស្មោះត្រង់ដ៏បរិសុទ្ធចំពោះជាតិមាតុភូមិ និងប្រជាពលរដ្ឋរហូតដល់ថ្នាក់ហ៊ានបូជាលះបង់ជីវិត ដើម្បីតែការពារប្រយោជន៍ពួកខ្លួនដែលជាពលរដ្ឋ និងពូជសាសន៍រួមឈាម និងប្រទេសជាតិទាំងមូលផងនោះ បែរជាពួកពលរដ្ឋទាំងនោះពួកគេមើល៍មិនដែលចេះឃើញ និងឲ្យតម្លៃមិនកើតទៅវិញ។ តែផ្ទុយមកវិញពលរដ្ឋទាំងនោះពួកគេសុខចិត្តនាំគ្នាទៅជួយគាំទ្រជួយផ្តល់កម្លាំងចិត្ត និងនាំគ្នាទៅឲ្យតម្លៃជាខ្លាំងដល់ពពួកក្រុមមនុស្សសំរាមមានតែចិត្តអាត្មានិយមសន្ដានថោកទាប ដែលមានតែបំណង់អាក្រក់ចង់ឲ្យពួកខ្លួន(**ប្រជាពលរដ្ឋ**) ស្លាប់ជាបន្តបន្ទាប់នោះទៅវិញ។ រហូតដល់ថ្នាក់ជួយជ្រុមជ្រែងឲ្យក្រុមពួកអាសំរាមមេសំអុយទាំងនោះ ឲ្យពួកវាមានឱកាសបានមកគ្រប់គ្រងនិងសម្លាប់ពួកលោកជាអ្នកប្រាជ្ញ បណ្ឌិត

សប្បុរសអ្នកការពារជាតិជាវីរបុរសជាតិ របស់ខ្លួនឯងបន្ថែមទៀតផងនោះទៅវិញ។

ដោយភាពកំឡៅល្ងង់ខ្លៅចាក់ស្រេះ ពេញតែខួរក្បាលកែរលែងចង់កើតរបស់ពលរដ្ឋនៅក្នុងសង្គមមួយនេះដូច្នេះហើយ ទើបបានជាឱកាសល្អច្រើនសម្រាប់ក្រុមពពួកអាមនុស្សខូចៗទាំងនោះ ពួកវាបានមានឱកាសបានឡើងគ្រប់គ្រងឋានៈបុណ្យស័ក្តិបានតំឡើងគ្នាជាស្តេចសឹងតែគ្រប់គ្នានោះ ហើយពពួកមនុស្សសំរាមទាំងនោះ វាបានកំពុងតែបែរមកជាន់ក្បាលពួកខ្លួន (**ពលរដ្ឋ**) វិញយ៉ាងស្របច្បាប់អស់មួយជីវិតជីវ៉ា រាប់ជំនាន់តកូនតចៅទៀតផងនោះ គេជាន់ក្បាលប៉ុណ្ណឹងហើយនូវតែមិនព្រមដឹងខ្លួនទៀត តែផ្ទុយមកវិញគឺពួកគេនូវតែសប្បាយចិត្តកើតថែមទៀតផង។ ហើយពួកអាមនុស្សកំឡៅទាំងនោះ វាព្យាយាមលើកអាសំរាមគ្នាវាឲ្យឡើងធ្វើជាស្តេច ហើយពួកវាខំបង្វែរកំហុសពួកវាដែលពួកវាបានធ្វើបាបប្រជាពលរដ្ឋនិងបំផ្លាញជាតិកន្លងមកទាំងប៉ុន្មាននោះ វាបានបង្វែរកំហុសទាំងនោះទម្លាក់មកឲ្យពួកលោកជាវីរបុរសជាតិជាអ្នកការពារជាតិ មានបណ្ឌិតអ្នកប្រាជ្ញ ដែលបានកំពុងមានជីវិតរស់នៅមកដល់សព្វថ្ងៃនេះផង និងទម្លាក់កំហុសទាំងប៉ុន្មានទៅឲ្យពួកលោកដែលបានបាត់បង់ជីវិតទៅហើយនោះផង បែរជាឲ្យពួកលោកអ្នកទាំងនោះជាអ្នកទទួលកំហុស និងជាប់ឈ្មោះក្លាយទៅជាចោរបំផ្លាញជាតិជាប់ឈ្មោះជាបុគ្គលក្បត់

ជាតិពួកគេនាំគ្នាយកទៅចារចុះក្នុងប្រវត្តិសាស្ត្រទាំងអយុត្តិធម៌ផ្តល់ឲ្យពួកលោកជាអ្នកទទួលកំហុសទាំងអស់នេះទៅវិញ។

នេះពិតជាស្រុកដ៏ចំឡែកពិតប្រាកដមែន គឺចំឡែកបែបឆ្កួតៗតែងឲ្យតម្លៃជីវិត«**អ្នកឈ្នះជាស្តេច អ្នកចាញ់ជាចោរ**»ទៅវិញនោះឯង។ ទោះបីជាជីវិតពួកគេរស់នៅដោយភាពស្មោកគ្រោកចង្រៃគេចង្រៃឯងយ៉ាងណាក៏ដោយក្តី ក៏ពួកវាអាចឲ្យតម្លៃជាស្តេចបានដែរ នេះពិតជាគួរឲ្យអើមខ្ពើមចង់តែក្អួតឲ្យបែកប្រម៉ាត់ស្លាប់នោះទេខ្ញុំ នេះពិតជាស្រុកដ៏ឆ្កួតលីលាពិតមែន។ នៅក្នុងលោកជាមួយនឹងគេដែរ មិនច្រលំគេទាល់តែសោះ ស្រុកឆ្កួតមួយ។

## ភ្លេចអត្តសញ្ញាណខ្លួនឯង

មនុស្សដែលនៅឆ្ងាយពីតម្លៃក្នុងភាពជាមនុស្ស ប្រៀបបានទៅនិងមនុស្ស ដែលបានបាត់បង់សតិរួចស្រេចបាត់ទៅហើយ ។ យ៉ាងណាមិញពលរដ្ឋនៅក្នុងប្រទេសមួយ ដែលនាំគ្នាបំភ្លេចនូវអត្តសញ្ញាណជាតិរបស់ខ្លួនឯង ឬថាមិនស្គាល់នូវអត្តសញ្ញាណជាតិខ្លួនឯងហើយនោះ ក៏មិនអាចនិងមានមោទនៈភាពចំពោះជាតិខ្លួនឯងនោះកើតបានដែរ ទាំងនេះក៏ជារឿងមួយដ៏គ្រោះថ្នាក់ដ៏ធំបំផុតសម្រាប់សង្គមជាតិទៅអនាគតផងដែរ។

សារជាតិជាមនុស្សពិតប្រាកដ គឺស្ថិតនៅលើគុណធម៌ គុណធម៌គឺមានអំណាចធ្វើឲ្យមនុស្សទូទៅបានពេញលក្ខណៈជាមនុស្ស ភាពពេញលក្ខណៈជាមនុស្សនោះហើយ អាចនឹងធ្វើឲ្យមនុស្សទាំងនោះឯង បានយល់អំពីតម្លៃនៃជីវិតពិតរបស់ពួកគេក្នុងការរស់នៅប្រចាំថ្ងៃ ការរស់នៅឱបក្ដាប់ជាមួយនិងតម្លៃជីវិតក្នុងភាពជាមនុស្សនេះ នោះគឺវាពិតជាទ្រព្យដ៏មហាសាលមួយដែលមិនអាចកាត់ថ្លៃបាននោះសោះឡើយ ដែលវាបាននៅប្រចាំជានិច្ចក្នុងដំណើរជីវិតរស់នៅរបស់ពួកគេទាំងនោះ ក៏ជាទ្រព្យមួយដែលនៅជាប់និងខ្លួនជាអមតៈជានិរន្តរ៍នោះផង ដែលគ្មានអ្នកណាម្នាក់ ឬក្រុមចោរណាអាចមកលួច ឬប្លន់យកទៅបាននោះឡើយ។

ការស្គាល់អំពីតម្លៃនៃជីវិតក្នុងការរស់នៅក្នុងនាមជាមនុស្សជាតិ គឺវាធ្វើឲ្យមនុស្សទាំងនោះ បានក្លាយទៅជាមនុស្សម្នាក់ប្រាកដនិយម ស្គាល់ពីតួនាទីស្គាល់ពីកតព្វកិច្ចភារកិច្ចក្នុងនាមជាមនុស្ស និងធ្វើឲ្យខ្លួនពួកគេផ្ទាល់មានមោទនភាព ក្នុងទង្វើគឺការងារដ៏មានតម្លៃរបស់ពួកគេ ក្នុងការបម្រើមនុស្សជាតិជាពិសេសគឺសង្គមជាតិរបស់ពួកគេផ្ទាល់ ដែលពួកគេកំពុងតែរស់នៅនោះឯងតែម្ដង។ ប៉ុន្តែផ្ទុយមកវិញ ប្រសិនបើមនុស្សទាំងឡាយនោះ បែរជានាំគ្នានៅឆ្ងាយពីតម្លៃនៃគុណធម៌ទៅវិញហើយនោះ គឺបានន័យថាពួកគេកំពុងតែបានបាត់បង់នៅមោទនភាព គឺបាត់បង់នូវភាពជាម្ចាស់ខ្លួនឯងនោះតែម្ដង វាគឺជា

រឿងដ៏គ្រោះថ្នាក់បំផុតក្នុងនាមពួកគេ ដែលជាពលរដ្ឋនៅក្នុងសង្គមជាតិមួយ ឬក្នុងនាមពួកគេជាមនុស្សជាតិ គឺវាមិនខុសអីមិនខុសអីពី ប៉ោងប៉ោង មិនខុសអីពីមនុស្សឡប់សតិ ឬមនុស្សអានាថាមនុស្សឆ្កួតប្រសៃប្រសាទនោះទេ គឺវាឋិតនៅក្នុងមនុស្សដែលមានជីវិតរស់មិនបានការ មនុស្សអត់ប្រយោជន៍គឺមានតែដង្ហើមដកចេញនិងចូលគ្រាន់តែរស់ពីមួយថ្ងៃទៅមួយថ្ងៃតែប៉ុណ្ណោះ នេះគឺជារឿងដ៏គ្រោះថ្នាក់បំផុតសម្រាប់មនុស្សជាទូទៅ ដែលមិនស្គាល់អំពីតម្លៃជីវិតរស់នៅជាមនុស្សនោះឯង។ និយាយមកដល់ត្រង់ចំណុចនេះ យើងចង់ដាក់សំនួរសួរថាៈ តើយើងចាំបាច់អីត្រូវការតម្លៃយកមកដាក់ក្នុងខ្លួនរបស់ពួកយើងនោះ? ហើយតើចាំបាច់អ្វីត្រូវស្គាល់តម្លៃខ្លួនឯងផ្ទាល់ជាមនុស្សនោះ? តើចាំបាច់ដើម្បីស្គាល់អត្តសញ្ញាណជាតិរបស់ខ្លួនឯងនោះធ្វើអ្វី? ហើយបើកើតជាមនុស្សហើយគ្មានតម្លៃតើរស់មិនកើតទេឬអ្វី? **ចម្លើយ**:.......................;គឺទុកឲ្យអ្នកកំពុងកាន់សៀវភៅនេះអាន ជាអ្នកឆ្លើយនូវសំនួរនេះជំនួសទៅចុះ។ តែចំពោះខ្ញុំជាអ្នកនិពន្ធចង់និយាយថាៈ **តម្លៃគឺតម្លៃ គុណជម៌គឺគុណជម៌ មនុស្សគឺមនុស្ស។**

- មនុស្សចំពោះ( **ព្រះពុទ្ធ** )លោកចែកមនុស្សជា**៥**ពួកគឺៈ

១.រូបជាមនុស្សចិត្តជាទេវតា

២.រូបជាមនុស្សចិត្តជាមនុស្ស

៣.រូបជាមនុស្សចិត្តជាតិរច្ឆាន

៤.រូបជាមនុស្សចិត្តជាប្រេត

៥.រូបជាមនុស្សចិត្តជានរក។

ក្នុងចំណោមចិត្តទាំងប្រាំរបស់មនុស្ស ដែលយើងបាននិយាយរៀបរាប់មកពីខាងលើជាហូរហែរមកហើយនោះ យើងអាចនិងបានយល់និងសិក្សាបែងចែកបានតែពីរផ្នែកតែប៉ុណ្ណោះគឺ:

១.ផ្នែកខាង**ចិត្តល្អ** គឺជាចិត្តដែលមានគុណធម៌ ដែលហៅថាតម្លៃនៃជីវិត គឺរស់មានតម្លៃ ដែលស្គាល់ពីបុព្វហេតុជីវិត ក្នុងការរស់ ។

២.គឺផ្នែកខាង**ចិត្តអាក្រក់** គឺចិត្តថោកទាបដែលជាចិត្តគ្មានគុណធម៌ ជាចិត្តដែលមិនអាចធ្វើឲ្យជីវិតមានតម្លៃបាន ការរស់មិនស្គាល់ពីបុព្វហេតុនៃជីវិត ជាជីវិតរស់គ្រាន់តែនាំភាពចង្រៃមកឲ្យពិភពលោកតែប៉ុណ្ណោះ។

ដូច្នេះហើយមនុស្សទូទៅ អាចជ្រើសរើសទៅតាមចំណង់ចំណូលចិត្តរបស់ខ្លួនម្នាក់ៗបានបើពួកគេយល់ថាផ្នែកនៃចិត្តណាមួយខាងលើនេះ ដែលនាំ

ឲ្យជីវិតរបស់ពួកគេទទួលបាន នៅក្តីសុខស្ងប់សេចក្តីល្អសេចក្តីចំរើន និងបានលទ្ធផលល្អសម្រាប់ជីវិតពួកគេទៅអនាគតនោះ ចូលជ្រើសរើសយកមកដាក់ក្នុងខ្លួន ឬសូមច្នៃវាទៅតាមតែបំណងរៀងៗខ្លួន ដែលខ្លួនចង់បាននោះទៅចុះ លទ្ធផលនិងចេញមកជាខាងក្រោយ នោះទើបបានយើងម្នាក់ៗអាចនិងបានដឹងនិងបានទទួលលទ្ធផលនោះហើយ ដល់ដំណាក់កាលនោះហើយយើងចង់មិនចង់គឺវាត្រូវបានចេញជាលទ្ធផល មកឲ្យពួកយើងជាអ្នកជ្រើសរើសជាអ្នកប្រព្រឹត្តក្នុងពេលនោះយ៉ាងពិតប្រាកដ ចង់មិនចង់ក៏ត្រូវតែនៅទ្រាំដេកឱបយកលទ្ធផល ដែលបានមកដោយសារពីទង្វើរបស់ខ្លួនម្នាក់ៗនឹងទៅចុះ ( **បើអ្នកជាមនុស្សឆ្លាតដេកពាក់មកុដ តែបើអ្នកជាមនុស្សល្ងង់វិញនោះ គឺដេកឱបខ្មោចឆ្អឹងអស់មួយជីវិតរៀងៗខ្លួនដូចគ្នា** )។ពីព្រោះខ្លួនយើងម្នាក់ៗជាអ្នកសម្រេចចិត្តជ្រើសរើសកសាងយកដោយខ្លួនឯងផ្ទាល់ទេ គឺមិនមានបុគ្គលណាម្នាក់ដែលមានអំណាចមានបុណ្យស័ក្តិមានឫទ្ធិបារមីណាគេមកបង្ខិតបង្ខំឲ្យយើងជាអ្នកជ្រើសរើសយកនោះទេ គឺខ្លួនយើងផ្ទាល់ទេដែលជាអ្នកសម្រេចចិត្តជ្រើសរើសយកដោយខ្លួនឯងនោះ។

# សីល៥ប្រៀបដូចអាវក្រោះ

សីល**៥**នេះប្រៀបដូចជាអាវគ្រោះដ៏រឹងមាំ ហើយក៏ជាទ្រព្យមរតកដ៏មានតម្លៃពិសេសសម្រាប់មនុស្សជាតិទូទៅ ក្នុងពិភពលោកទាំងមូលនេះផង និងរកវត្ថុអ្វីនៅក្នុងសកលលោកនេះឲ្យមានតម្លៃលើសពីសីល៥នេះ និងយកមកប្រៀបផ្ទឹមយកមកកាត់ថ្លៃឲ្យស្មើនិងសីលប្រាំនេះគឺគ្មាននោះទេ។ សីល៥នេះគឺត្រូវបាននៅជាប់ជាមួយនិងកំណើតដំបូងរបស់មនុស្សតែម្តង គឺថាកំណើតរបស់មនុស្ស ឬមានសណ្ឋានជាលក្ខណៈជាមនុស្សនៅពេលណា គឺថាសីល៥នេះកើតមានក្នុងពេលនោះតែម្តង នេះគឺជាច្បាប់ធម្មជាតិមិនមែនមកពីព្រះពុទ្ធ បុគ្គលអាទិទេព ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះជាម្ចាស់ ឬព្រះអង្គណានិមួយជាអ្នកមានរិទ្ធិបារមីពូកែប្រទានមកឲ្យនោះក៏ទេដែរ តែវាគឺជាធម៌ចាស់មានតាំងពីយូរយារណាស់មកហើយ សីលប្រាំគឺជាទ្រព្យជាប់តាមខ្លួនរបស់មនុស្សនេះជាស្រេចស្រាប់ទៅហើយ ដោយពិតប្រាកដដល់មនុស្សជាទូទៅតែម្តង។ ប៉ុន្តែជាធម្មតានោះទេដោយសារតែមនុស្សលោកជាទូទៅ មានតែភ្នែកមានតែក្បាលនិងសន្តានពោរពេញទៅដោយភាពអវិជ្ជាច្រើនពេកនោះ ក៏មិនអាចនិងធ្វើឲ្យពួកគេអាចយល់ជាក់ច្បាស់ទៅបាន និងមិនអាចឲ្យមើល៍ឃើញនូវតំលៃទ្រព្យដ៏ពិសេសវិសាលកាត់ថ្លៃមិនបានមួយនេះទាល់តែសោះ ទាំងដែលមិនដឹងថាជាទ្រព្យជាប់និងពួកខ្លួនគេដែលជាមនុស្សផងនោះទេ ព្រមទាំងមិនដឹងថាជាធម៌មានតម្លៃ ដែលនិងជាសីលធម៌អាចជួយបំពេញឲ្យពួកខ្លួននោះ ឲ្យបានកាន់តែ

ពេញលក្ខណៈជាមនុស្សបានថែមទៀតនោះក៏ពួកគេមិនទាំងនឹងដឹងផង។ ហើយដោយភាពវង្វេងដោយអវិជ្ជាងងឹតឈឹងដោយមិនដឹងថាអ្វី ដែលបានជួយឧបត្ថម្ភឲ្យពួកខ្លួនបានពេញលក្ខណៈជាមនុស្ស បានដោយវិធីណានោះ តាមរូបមន្តណាមួយនិងដើរតាមគន្លងណាមួយនោះ គឺមនុស្សសឹងមួយពិភពលោកទៅហើយគឺថាមិនមានសំនួរមិនមានចម្លើយនោះទេ ពួកគេព្រៀបបានទៅនឹងគោជាច់កន្លះ គឺពួកគេធ្វើទៅតាមអ្វីៗដែលពួកគេនឹកឃើញតែប៉ុណ្ណោះ ហើយបង្កើតអ្វីៗដែលពួកគេចង់បង្កើតតែប៉ុណ្ណោះ និងធ្វើអ្វីៗទាំងអស់ជាប្រេីន។ល។ នោះគឺថាទៅតាមតែចំណង់ទៅតាមតណ្ហានិងភាពវង្វេងវង្វេងងងឹតឈឹងក្នុងភាពអវិជ្ជាដឹកមុខពួកគេតែប៉ុណ្ណោះ ទោះបីអំពើទាំងនោះមានប្រយោជន៍ក្តី មិនមានប្រយោជន៍ក្តី ប៉ះពាល់និងមិនប៉ះពាល់ដល់អ្នកដទៃក្តី គឺថាពួកគេធ្វើទាំងអស់ធ្វើទាំងងងឹត ទាំងដែលពួកគេមានភ្នែកភ្លឺមានខួរសម្រាប់ឲ្យគិតតែបែរជាពួកគេមិនព្រមគិត គឺពួកគេមិនខ្វីខ្វល់យកក្បាលមកគិតយកភ្នែកមកមើល៍នោះទាល់តែសោះ ហើយអ្វីៗដែលបានមកពីលទ្ធផលទង្វើដោយគ្មានក្រមសីលធម៌របស់ពួកគេទាំងនោះមានដូចជា មនុស្សល្អជាបែរជាធ្វើឆ្កួតភ្លើដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន មនុស្សឆ្កួតធ្វើជាព្រះ សាសនាគ្មានហេតុផលរាប់មិនអស់ បង្កើតជំនឿធ្វើឲ្យមនុស្សវង្វេងជនផ្អើលរាប់ជំនាន់មិនចេះចប់ បង្កើតបច្ចេកវិទ្យា

ក្នុងក្រមសីលធម៌និងគុណធម៌។ល។ និងធ្វើអ្វីៗដែលគ្មានហេតុផលជាច្រើនផ្សេងៗទៀត ដែលជារឿងនឹកស្មានមិនដល់នោះ វាចេះតែកើតជាបន្តបន្ទាប់ ដែលជាហេតុនិងជាដំណើរផ្លូវមួយដែលនិងកំពុងបណ្តាលនាំឲ្យមនុស្សនិងពិភពលោកទាំងមូលនេះ និងដល់នៅក្តីក្តៅក្រហាយនិងអន្តរាយទៅបន្តិចម្តងៗពីមួយថ្ងៃទៅមួយថ្ងៃនោះឯង ទាំងនេះឯងហើយគឺសបញ្ជាក់ឲ្យឃើញថាវាសុទ្ធសឹងតែកើតមកពីទង្វើរបស់មនុស្សអវិជ្ជាទាំងអស់។ ដោយពួកគេមិនទាំងនឹងដឹងថាខ្លួនរបស់ពួកគេហ្នឹង កំពុងមានមរតកដ៏ពិសេសមួយនៅជាប់តាមខ្លួនរបស់ពួកគេនោះទេ ដែលកំពុងតែកប់នៅក្នុងជម្រៅបាតចិត្តខាងក្រោមផងនោះ ដោយចិត្តពួកគេទាំងនោះមានក្តីប្រមាថ (ប្រហែសធ្វេស) ខ្ជិលនិងគិតខ្វល់ស្វែងយល់ទៀតផងនោះ ទើបចេះតែធ្វើឲ្យសីល៥នេះបានធ្លាក់កប់កាន់តែជ្រៅទៅៗ នៅក្នុងជម្រៅបាតចិត្តរបស់ពួកគេនោះឯងហើយភាពអកុសលក៏ផុសឡើង ពេលនោះឯងហើយសភាពចិត្តងងឹតដោយអវិជ្ជាក៏មានឱកាសផុសមកខាងលើងបានបាំងនូវពន្លឺធម៌ពន្លឺសីលនេះតែម្តង ហើយក៏បានបណ្តាលធ្វើឲ្យមនុស្សទាំងនោះ ក៏កាន់តែមានភាពងងឹតសូន្យឈឹង និងមិនអាចមានសមត្ថភាពយល់បាន និងអាចឲ្យន័យនិងកំណត់ដើម្បីបដិបត្តិនូវខ្លឹមសារសីល៥នេះក្នុងដំណើរត្រឹមត្រូវបាននោះឡើយ។ នៅពេលជីវិតពួកគេនៅឆ្ងាយពីសីលប្រាំហើយនោះ គឺថារាល់សកម្មភាពការងាររបស់មនុស្ស

ទាំងឡាយនោះប្រៀបបានទៅនឹងពួកគេ កំពុងតែដើរឆ្លងនៅលើបន្ទះដែកដ៏តូចហើយស្តួឆ្លងកាត់នៅលើរណ្តៅរងើកភ្លើងដ៏ធំមួយអញ្ចឹង។ សូមបញ្ជាក់ថា: សីល៥នេះគឺមិនសម្រាប់សាសនា បុគ្គល ឬសម្រាប់ប្រទេសណាមួយនោះទេ ហើយក៏មិនមែនសម្រាប់តែជនណាម្នាក់ ដែលជាអ្នកគ្រាន់តែចេះចាំសូត្រចាំមាត់តែបដិបត្តិមិនត្រូវនោះថាជាអ្នកចេះសីល៥នោះក៏ទេដែរ។ សីលប្រាំនេះជាសីលសកលជាធម៌សកលរបស់មនុស្សជាតិទូទៅ ដូចដែលខ្ញុំបាននិយាយរៀបរាប់មកពីខាងលើជាហូរហែរកន្លងមកហើយនោះឯង តែដែលអាចសម្គាល់បានថាបុគ្គលណាម្នាក់ជាអ្នកចេះសីល៥ពិតប្រាកដបាននោះ គឺវាអាស្រ័យទៅលើតែទង្វើគឺការប្រព្រឹត្តដ៏ត្រឹមត្រូវទៅតាមច្បាប់ឬតាមគន្លងសីល៥ ដែលជាគុណធម៌របស់មនុស្សតែប៉ុណ្ណោះ ទោះបីមនុស្សនោះរស់នៅក្នុងសាសនាណាឬជាជាតិសាសន៍ណាក៏ដោយ នេះគឺជាអត្ថន័យខ្លឹមសារពិតចំពោះអ្នកដែលប្រព្រឹត្តត្រឹមត្រូវតាមសីល៥នោះឯង។ ពលរដ្ឋនៅក្នុងសង្គមនីមួយៗឬពលរដ្ឋនៅក្នុងសង្គមពិភពលោកទាំងមូលក្តី បើពួកគេប្រព្រឹត្តសីល៥បានខ្ជាប់ខ្ជួនបានល្អហើយនោះ ពិតណាស់សង្គមរបស់ពួកគេទាំងនោះ និងពិភពលោករបស់ពួកគេនិងនាំមកនូវសន្តិភាពយ៉ាងពិតប្រាកដជានិរន្តរ៍។ ដោយការមិនចង់យល់នូវអ្វីដែលមាននូវក្នុងខ្លួនជាមុន ហើយចេះតែចង់ដឹងពីរបស់ខាងក្រៅយ៉ាងនោះឯងហើយ ទើបបានជាយើងចេះតែឃើញមាននូវបញ្ហាផ្សេងៗវាចេះ

តែកើតមានឡើង ជាច្រើនមកនៅលើភពផែនដីរបស់ពួកយើងនេះ ជាបន្តរបន្ទាប់មិនដែលចេះចប់នោះឯង។ ទើបបានមកដល់ជំនាន់ព្រះសម្មាសម្ពុទ្ធសមណគោតមនៃយើងសព្វថ្ងៃនេះ ដែលព្រះអង្គបានត្រាស់ដឹងឡើងមកក្នុងលោក ទើបព្រះអង្គបានគាស់រំលើង នឹងបានបើកបង្ហាញអំពីអត្ថប្រយោជន៍នៃសីល៥របស់មនុស្សមួយនេះ ឲ្យមនុស្សលោកទូទៅបានដឹងបានយល់ពីអត្ថន័យពិតខ្លឹមសារពិត ដើម្បីឲ្យសត្វលោក និងបានយកទៅប្រើប្រាស់ឲ្យបានជាប្រយោជន៍ទូទៅ សម្រាប់សង្គមមនុស្សចាប់តាំងពីខ្លួនឯងរហូតដល់សង្គមគ្រួសារប្រទេសជាតិ និងសកលលោកទាំងមូលឲ្យបានដល់នៅក្ដីសុខសន្តិភាពឯកភាពគ្នាជាសកលផងដែរ។(**ព្រះសម្ពុទ្ធ**)ព្រះទ្រង់ត្រាស់សម្ដែងថាៈធម៌នេះគឺមានតាំងតែពីបរមបុរាណកាលមកម្លេះ ហើយក៏ជាធម៌របស់មនុស្សយ៉ាងពិតប្រាកដថែមទៀតផង បើបុគ្គលណាហើយចង់បានសេចក្ដីសុខសុភមង្គលឲ្យបានដល់ខ្លួន ដល់សង្គមគ្រួសារ និងប្រទេសជាតិរបស់ខ្លួននោះ ពួកគេគួរតែប្រកាន់យកសីល**៥**នេះមកដាក់ក្នុងខ្លួននាំគ្នាសិក្សា នាំគ្នាយកមកបដិបត្តិជារៀងរាល់ថ្ងៃ សម្រាប់ដំណើរជីវិតប្រចាំថ្ងៃរបស់ខ្លួនទៅនោះ ពិតណាស់ពលរដ្ឋទាំងនោះ សង្គមគ្រួសារនោះ ប្រទេសជាតិទាំងនោះ និងបានសេចក្ដីសុខចម្រើនយ៉ាងពិតប្រាកដ ហើយពិភពលោកទាំងមូលនេះ ក៏គង់និងដល់នៅសេចក្ដីសុខសន្តិភាពយ៉ាងជាក់ប្រាកដផងដែរ។ ដោយវាបានទទួលឥទ្ធិពលពីផល

នៃអំពើទង្វើរបស់មនុស្សដែលជាអ្នកយល់ច្បាស់ និងបដិបត្តិបានល្អត្រូវនៅក្នុងគន្លងសីល៥បានមកគ្រប់ៗគ្នានោះឯង។ ហើយសីល៥នេះសោធ គឺជាឫសគល់នៃគុណធម៌ សីលធម៌ និងកុសលធម៌សេចក្ដីល្អទាំងពួងផងដែរ។

**សីល**:[សិ+ល ឬសីល+អ]=ប្រែថា: ចម្រើន,ត្រជាក់,ប្រក្រី។ បញ្ចសីល ឬសីល៥មានអង្គ៥គឺ:

១.**បាណាតិបាតា វេរមណី**:វៀរចាកការសម្លាប់ជីវិតទូទៅ។

២.**អទិន្នាទានា វេរមណី**:វៀរចាកការលួច។

៣.**កាមេសុមិច្ឆាចារា វេរមណី**:វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ(កូនប្រពន្ធអ្នកដទៃ)។

៤.**មុសាវាទា វេរមណី**:វៀរចាកការពោលពាក្យកុហក។

៥.**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី**:វៀរចាកក្ដីប្រមាថ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ។

# ដើម្បីកម្ពុជាមានសន្តិភាព

ដើម្បីធ្វើឲ្យកម្ពុជាមានសន្តិភាពជាក់លាក់ជានិរន្តរ៍ទៅបាននោះ ពិតណាស់កម្ពុជាខ្លួនឯងត្រូវតែស្គាល់ខ្លួនឯងផ្ទាល់ឲ្យបានច្បាស់ជាមុន ជាជាងអ្នកណាៗទាំងអស់។ មានន័យថាមិច មានន័យថាពលរដ្ឋកម្ពុជាគឺខ្មែរគ្រប់រូបរួមទាំងរដ្ឋាភិបាលនោះផង ទាំងអស់គ្នាហ្នឹងចាំបាច់គឺត្រូវតែមានឧត្តមគតិមនសិការជាតិ គឺត្រូវស្គាល់អត្តសញ្ញាណជាតិ និងត្រូវចេះនាំគ្នាមោទនភាពចំពោះជាតិខ្លួនឯងនោះឲ្យបានប្រាកដជាក់ជាមុនសិន មុននិងឲ្យអ្នកដទៃឬប្រទេសដទៃណាគេស្គាល់យើងនោះ។ ពិតណាស់ពលរដ្ឋកម្ពុជា ក៏ដូចជារដ្ឋាភិបាលកម្ពុជាទាំងមូលគឺត្រូវរួមកម្លាំងគ្នា ប្រកាន់នូវជំហរតែមួយក្នុងដំណើរការឯកភាពជាតិតែមួយ និងសាមគ្គីភាពគ្នាឲ្យបានជាធ្លុងមួយ ក្នុងបំណងតែមួយជាមួយគ្នានោះ និងនាំគ្នារកឯករាជ្យភាពជាតិរបស់ខ្លួនឯងជាកម្ពុជាខ្លួនឯងឲ្យបានជាកម្លាំងរឹងមាំជាមុនសិន ជាពិសេសគឺមេដឹកនាំទាំងអស់តែម្តង គឺចាប់តាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់លើមានដូចជា ឪពុកម្តាយ គ្រូបង្រៀន មេក្រុមមេភូមិ មេឃុំ មេស្រុក ចៅហ្វាយខេត្ត មេបក្ស នាយករដ្ឋមន្ត្រី(**រដ្ឋាភិបាល**) មេសាសនា(**ព្រះសង្ឃ**) ប្រធានស្ថាប័ន និងស្តេច។ល។ គឺដាច់ខាតត្រូវមានឧត្តមគតិនិងមនសិការជាតិយ៉ាងពិតប្រាកដជាគំរូល្អជាមុន សម្រាប់ទុកឲ្យពលរដ្ឋ និងអ្នកដែលនៅពីខាងក្រោមខាងក្រោយ ដើម្បីឲ្យពួកគេបានឃើញយកទៅធ្វើជាគំរូល្អតាម។ ដូច្នេះហើយរាល់មេដឹកនាំទាំងអស់ គឺគ្រប់ស្ថាប័ន

និងត្រូវចេះនាំគ្នារៀនពន្យល់ដល់ពលរដ្ឋ និងបុគ្គលិកសមាជិករបស់ខ្លួននៅក្នុងស្ថាប័ននីមួយៗ និងអ្នកដែលនៅខាងក្រោមបង្គាប់របស់ខ្លួនទាំងអម្បាលមាណនោះ អោយពួកគេចេះប្រកាន់យកនូវគោលការណ៍ និងគោលនយោបាយតែមួយ ដែលជាប្រយោជន៍ជាតិរួមរបស់ពួកយើងទាំងអស់គ្នា ឲ្យពួកគេបានស្គាល់និងអនុវត្តឲ្យបានច្បាស់លាស់ ក្នុងដំណើរគោលដៅរួមមួយ និងក្នុងដំណើរឯកភាពជាតិតែមួយឲ្យបានទៅជាផ្លុងមួយជាដាច់ខាត។

ព្រឹទ្ធសភារដ្ឋសភារាជរដ្ឋាភិបាលនិងស្ថាប័ន ដែលពាក់ព័ន្ធដទៃៗទៀត បន្ទាប់ពីបានដឹងថាប្រយោជន៍រួមប្រយោជន៍ជាតិ ជាប្រយោជន៍ធំរួមហើយនោះ ដំបូងដៃអ្វីដែលពួកយើងត្រូវធ្វើបន្តទៀតនោះ គឺការបង្កើតច្បាប់ដ៏សុក្រិតមួយសម្រាប់ប្រទេស។ ដូច្នេះរាល់នៃការបង្កើតច្បាប់ទាំងអស់ គឺចាំបាច់ណាស់ត្រូវតែនាំគ្នាបង្កើតច្បាប់ណា ដែលវាពិតជាផ្តល់ផលប្រយោជន៍ឲ្យបានដល់ជាតិ និងពលរដ្ឋពិតមែន ដែលមិនមែនបង្កើតច្បាប់មកសម្រាប់គ្រាន់តែបម្រើការពារតែបុគ្គលពួកក្រុមបក្ស ឬ អ្នកមានអំណាចណានិមួយនោះទេ។ បើអាចបង្កើតច្បាប់ដែលមានគុណធម៌ច្បាប់បែបនេះបានសម្រាប់ប្រទេសមែននោះ ពិតណាស់ពលរដ្ឋខ្មែរជាទូទៅនៅក្នុងប្រទេសកម្ពុជាទាំងមូល ពួកគេអាចនិងយល់បានយ៉ាងជាក់ច្បាស់ និងជឿជាក់យ៉ាងច្បាស់ទៅលើអ្នកបង្កើតច្បាប់ ពិសេសគឺមេដឹកនាំប្រទេស ដែលជាអ្នកអនុវត្តច្បាប់នោះតែម្តង។ ដោយពួកគេនិងយល់

ទុកចិត្តជឿជាក់បានថា នេះវាពិតជារាជរដ្ឋាភិបាលជាមេដឹកនាំរបស់ពួកគេយ៉ាងពិតប្រាកដ រដ្ឋាភិបាលរបស់ពួកគេមួយនេះឯងហើយ ដែលនិងកំពុងតែបានយកចិត្តទុកដាក់ជាខ្លាំងចំពោះប្រយោជន៍របស់ពួកគេនោះ(ប្រជាពលរដ្ឋខ្មែរ)និងសង្គមខ្មែរទាំងមូលនោះឯង។

ហើយមេដឹកនាំប្រទេសមួយនេះ ត្រូវមានតួនាទីដ៏សំខាន់មួយទៀតខាន់មិនបាននោះ គឺការជួយពង្រឹងខាងផ្នែកស្ថាប័នផ្សេងៗ ដែលជាស្ថាប័នពាក់ព័ន្ធទៅក្នុងការជួយជ្រុំជ្រែងពង្រឹងដល់គោលនយោបាយជាតិនោះឯង គឺត្រូវយកចិត្តទុកដាក់ប្តូរផ្តាច់ខំពង្រឹងឲ្យបានគ្រប់ៗស្ថាប័នទាំងអស់ គឺត្រូវឲ្យស្ថាប័នទាំងនោះរាល់ក្នុងការអនុវត្តគឺត្រូវឲ្យប្រកបព្រមទៅជាមួយនិងទឹកចិត្តមនោសញ្ចេតនាឧត្តមគតិមនសិការជាតិ របស់ខ្លួនដោយពិតប្រាកដនោះឯងផង។ ពិសេសជាងគេនោះគឺស្ថាប័នអប់រំ គឺត្រូវពង្រឹងឲ្យមានគុណភាពខ្ពស់បានគ្រប់ៗតំបន់ទូទាំងប្រទេសកម្ពុជារបស់ពួកយើង កាលណាបើមេដឹកនាំប្រទេសបានយកចិត្តទុកដាក់ ដោយឧត្តមគតិនិងមនសិការជាតិក្នុងការយកចិត្តទុកដាក់ជួយពង្រឹង ដើម្បីឲ្យធនធានមនុស្សខ្មែរទាំងនោះ ឲ្យកាន់តែមានការរីកចម្រើនយ៉ាងឆាប់រហ័សថែមទៀតនោះ ពិតណាស់ក្នុងសង្គមកម្ពុជាទាំងមូលនេះនិងសម្បូរទៅដោយមនុស្សមានគុណភាពគុណធម៌ សីលធម៌ សុជីវធម៌ និងគុណតម្លៃ គឺមានន័យថាពលរដ្ឋខ្មែរទាំងមូលហ្នឹង គឺកាន់តែសម្បូរជាបណ្តើរៗ

ទៅដោយមនុស្សដែលមានសន្តានល្អ កាលណាពលរដ្ឋខ្មែរសម្បូរមនុស្ស ដែលមានសន្តានចិត្តល្អនិងចំណេះដឹងគ្រប់គ្រាន់ច្រើនហើយនោះ ជាការពិតណាស់ពួកគេទាំងនោះនិងអាចផ្តើមកើតមានមនោសញ្ចេតនាពូជសាសន៍ចេះស្រឡាញ់គ្នារាប់អានគ្នាជាបងជាប្អូន ជាពូជសាសន៍តែមួយយ៉ាងស្មោះត្រង់ចំពោះគ្នានិងគ្នាយ៉ាងប្តូរផ្តាច់ គឺពួកគេគ្មានឱកាសទំនេរណាដើម្បីបានដើរបង្ករបញ្ហាអាក្រក់ឯណានីមួយ ឲ្យដល់គ្នានិងគ្នានិងសង្គមជាតិទាំងមូលនេះឲ្យទទួលផលលំបាកដោយសារពួកគេនោះឡើយ។ ទាំងនេះឯងហើយដែលជាផ្លូវនាំឲ្យកម្ពុជារបស់យើងទាំងមូលនេះនិងមានសុខសន្តិភាពដ៏រឹងមាំជានិរន្តរ៍ទៅបាននោះ។ ហេតុដែលបណ្តាលឲ្យមនុស្សត្រូវការសន្តិភាពនោះ ពីព្រោះសន្តិភាពគឺជា «**ឋានសួគ៌ឋានសុខ**»សម្រាប់សភាវៈទូទៅមិនថាត្រឹមតែឋានមនុស្សនោះទេ ទោះបីតែឋាននរកឋានទេវតា។ល។ក៏ត្រូវការសន្តិភាពនេះផងដែរ ពីព្រោះពាក្យថាសន្តិភាពនេះគឺជា(**ក្តីសុខគ្រប់បែបយ៉ាងដោះអី?**)។ តែយើងមិនចាំបាច់និយាយអ្វីច្រើននោះទេ ចំពោះឋានដែលយើងមើល៍មិនឃើញទៅមិនដល់នោះ យើងនិយាយត្រឹមតែឋានមនុស្សដែលពួកយើងកំពុងតែរស់នៅក្នុងពេលបច្ចុប្បន្នសព្វថ្ងៃនេះ ដែលកំពុងតែឃើញជាក់ស្តែងនិងភ្នែកនេះទៅបានហើយ។

ពិតណាស់សន្តិភាពមនុស្សពិតជាត្រូវការ វាជាចាំបាច់ខាន់មិនបាន ពីព្រោះរាល់មនុស្សសត្វទូទៅទាំងអស់កុំឡើយត្រឹមតែថាមនុស្ស សម្បីតែសត្វក៏ពួកវាចង់បានពួកវាត្រូវការសន្តិភាពផងដែរ សូម្បីតែរុក្ខជាតិទាំងឡាយដែលនៅលើភពផែនដីក្នុងឋានមនុស្សសព្វថ្ងៃនេះ ក៏ពពួករុក្ខជាតិទាំងឡាយនោះក៏ពួកវាចង់បានសេចក្ដីសុខសន្តិភាពដូចតែមនុស្សយើងហ្នឹងផងដែរ។ សន្តិភាពសំខាន់ដ៏ម្លឹងផងហ្ន៎!ដល់ថ្នាក់ពិភពលោកទាំងមូលត្រូវការវាអត់វាមិនបានយ៉ាងនេះដូច្នេះនោះ? ពីព្រោះសន្តិភាពគឺជាឋានសុខគឺផ្ទុយពីឋានទុក្ខ គឺ **«សង្គ្រាម»** សង្គ្រាមគឺជាឋានទុក្ខ កាលណាសង្គ្រាមកើតឡើងហើយក្នុងតំបន់ណាមួយ ឬប្រទេសណាមួយជាចំណែកពិភពលោកមួយនេះ គឺពិតណាស់តំបន់នោះឬប្រទេសនោះ វាព្រៀបបានទៅនឹងភ្នក់ភ្លើងយ៉ាងធំឬរណ្ដៅទឹកសំណរយ៉ាងក្ដៅកំពុតែឆេះឆាប និងកំពុងតែពុះក្ដៅមានកម្រិតកើនឡើងៗទៀមនិងដុតសម្លាប់ ឬកំពុងតែដុតសម្លាប់រាល់មនុស្សសត្វរុក្ខជាតិទាំងអស់នោះ ឲ្យដល់នៅក្ដីវិនាសអន្តរាយរលៀបសូន្យបង់ជីវិតទៅនឹងឯងគឺជាឋានទុក្ខ គឺ**«សង្គ្រាម»**នោះណា!គឺគ្មានមនុស្សសត្វណាមួយប្រាថ្នាចង់បានវានោះទេ គឺពួកគេត្រូវការតែសន្តិភាពតែមួយគត់ គឺវាគ្រប់គ្រាន់ណាស់ពេកទៅហើយសម្រាប់ជីវិតរស់នៅរបស់ពួកគេនោះ។ ដូច្នេះហើយបានជាគេឲ្យនាមសន្តិភាព

ថាគឺជា «មានសុខឬមានសួគ៌» ឲ្យតែមានសន្តិភាពពិតប្រាកដគឺមានអ្វីៗទាំងអស់។

## ((ទស្សនពិចារណា))

- ធម្មទានរមែងឈ្នះអស់ទានទាំងពួង។(ព្រះពុទ្ធ)
- មូលហេតុនៃសេចក្តីទុក្ខទាំងឡាយគឺការចងចិត្តឬជំពាក់ចិត្ត។(ព្រះពុទ្ធ)
- ប្រទេសជាតិរបស់ខ្ញុំគឺជាអាយុជីវិតរបស់ខ្ញុំ។(ភប)

- រាស្ត្រខ្មែរបើចេះឈ្វេងយល់ពីសិទ្ធិ និងអំណាចរបស់ខ្លួនជាម្ចាស់ប្រទេសបានច្បាស់លាស់នោះ គឺថាគ្មានទេមេដឹកនាំដែលមានអំណាចប្រមូលផ្តុំនោះ។(កប)
- ស្គាល់មនុស្សពិតគឺស្គាល់ដល់សន្តាន។(ខឹមវាសនា)
- ភាពមិនចេះស្មោះត្រង់ចំពោះគ្នានិងគ្នាគឺជាដំណើរយឺតយូរ អាចនិងមិនដល់គោលដៅរួមមួយបានឡើយ។
- យកឈ្នះចិត្តគេប្រសើរជាងទៅកាប់សម្លាប់គេ។(ស៊ុនអ៊ូ)
- ឈ្នះខ្លួនឯង គឺឈ្នះអ្វីៗទាំងអស់។(ព្រះពុទ្ធ)
- មិត្តដ៏ស្មោះត្រង់គឺជាទ្រព្យដ៏មានតម្លៃដំបូងក្នុងជីវិតរបស់មនុស្ស។(ខឹមវាសនាស)
- គុណធម៌ងាប់ក្រឡានាំឲ្យអន្តរាយដល់ប្រទេសជាតិ។(ក.ប)
- អោយតែស្រលាញ់ប្រកបទៅដោយការយល់ដឹង ចង់ស្រលាញ់ឲ្យអស់ពីពោះក៏វាមិនអីដែរ។
- ប្រទេសណាមួយដែលប្រជាពលរដ្ឋមានជំនឿច្រើន ប្រទេសហ្នឹងមិនដែលរីកចម្រើនទេជំនឿតិចល្ងង់តិច ជំនឿច្រើន ល្ងង់ច្រើន។ (ខឹមវាសនា)

- សហាយតាគុណមិនមានក្នុងបុគ្គលពាលទេ។(ព្រះពុទ្ធ)
- ការសន្សំបាបនាំមកនូវសេចក្តីទុក្ខ។(ព្រះពុទ្ធ)
- អំពើអាក្រក់មនុស្សអាក្រក់ធ្វើបានដោយងាយ។(ព្រះពុទ្ធ)
- អំពើល្អមនុស្សល្អធ្វើបានដោយងាយ។(ព្រះពុទ្ធ)
- អំពើអាក្រក់មនុស្សល្អធ្វើបានដោយលំបាក។(ព្រះពុទ្ធ)
- អំពើល្អមនុស្សអាក្រក់ធ្វើបានដោយលំបាក។(ព្រះពុទ្ធ)
- ការមិនធ្វើអំពើបាបទាំងឡាយនាំមកនូវសេចក្តីសុខ។(ព្រះពុទ្ធ)
- បេះដូងអ្នកប្រាជ្ញលះបង់ ដើម្បីមនុស្សជាតិ មិនមែនដូចមនុស្សខូចគិតតែប្រយោជន៍ផ្ទាល់ខ្លួននោះទេ។(Gol damair)
- ពេលណាពលរដ្ឋកម្ពុជាបាត់លង្វង់ ពេលនោះទ្វីបអាស៊ីនិងមាននាគដ៏ខ្លាំងមួយទៀត គឺកម្ពុជានាគអាស៊ី។(Lee kuan yew)
- គេមិនឆ្លាតប៉ុន្មានទេ តែមកពីយើងភ្លើពេក។

- ការមើលមិនឃើញពីតម្លៃនៃការលះបង់របស់វីរបុរស គឺជាទោសមនសិការដ៏ធំបំផុតសម្រាប់ខ្លួនយើងជាមនុស្ស។(ប ព)
- សីលប្រាំគឺជាបាតគ្រឹះនៃកុសលធម៌ទាំងឡាយទាំងពួង)។(ប ព)
- វិស័យផ្សេងមនុស្សអាចស្ពាបានឆាប់ ប៉ុន្តែវិស័យគំនិត **ពុទ្ធិ** ជាបញ្ហាមួយមនុស្សពិបាកស្ពាណាស់។
- បើគិតហើយរៀនហើយមិនយកទៅផ្សាភ្ជាប់ និងការប្រតិបត្តិនេះកាន់តែឥតប្រយោជន៍ទៅទៀត។

# ((សេចក្តីបញ្ចប់))

ជាដំបូងខ្ញុំសូមអភ័យទោសចំពោះបងប្អូនប្រជាជាតិខ្មែរគ្រប់ៗរូប។ អត្ថន័យនិងខ្លឹមសារនៅក្នុងសៀវភៅនេះទាំងប៉ុន្មានគឺមានបំណងធំតែ

មួយគត់គឺចង់ឲ្យកូនខ្មែរគ្រប់ៗរូបចេះរៀនចែករំលែកនូវចំណេះដឹងឲ្យបានដល់គ្នានិងគ្នាតែប៉ុណ្ណោះ។ គឺគ្មានបំណងអ្វីដទៃណាមួយក្នុងការដែលធ្វើឲ្យខុសពីគន្លងដំណើរការឯកភាពជាតិសាមគ្គីភាព និងសន្តិភាពសង្គមនោះទេ។

ដូច្នេះហើយបើរាល់សំណេរខ្លឹមសារដែលខ្ញុំបានសរសេរទៅហើយទាំងប៉ុន្មាន នៅក្នុងសៀវភៅមួយនេះមានការប៉ះពាល់ដល់ពុកម៉ែបងប្អូនអស់លោក លោកស្រីនោះ ក៏សូមមេត្តាអភ័យទោសដល់រូបខ្ញុំដែលជាអ្នកនិពន្ធផងចុះ។ ហើយបងប្អូនពុកម៉ែស្រីប្រុស និងលោកលោកស្រីគ្រប់រូប សូមជួយចូលរួមកែរតម្រូវរាល់កំហុសទាំងប៉ុន្មាននៅក្នុងសៀវភៅនេះចុះ ដែលអស់លោកពុកម៉ែបងប្អូនមើលឃើញទៅថានៅមានកំហុសដែលគួរឲ្យកែរនោះ ខ្ញុំនិងស្វាគមន៍រាល់ការឆ្លើយតបក្នុងន័យស្ថាបនាពីបងប្អូនពុកម៉ែ ដោយក្តីរីករាយ៕សូមអរគុណ!

# ឯកសារពិគ្រោះ

-វចនានុក្រមខ្មែរភាគ១;២សម្ដេចព្រះសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ)

-បទានុក្រមជម្មបទភាគ (១;២;៣)

-បណ្ដាញសង្គម (Facebook)

(នាមអ្នកមានសទ្ធាចូលរួមជួយបោះពុម្ភសៀវភៅ)

១.លោកគ្រូ ភន សុផាត(វត្តអរុណវតី)....................៤០០០០០៛

២.ភិក្ខុបាន ពិត..........................................៣០០០០០៛

៣.ភិក្ខុនៅ សម្បត្តិ.......................................៣០០០០០៛

៤.ភិក្ខុម៉ា សុផាន់នី.......................................១០០០០០៛

៥.ភិក្ខុគឹម សុជារ៉ា.......................................១០០០០០៛

៦.ភិក្ខុសុខ សឿន.......................................១០០០០០៛

៧.ភិក្ខុស៊ឹម មករា..............................................20$

៨.សាមណេរ វ៉ា រុណ....................................២០០០០៛

៩.សាមណេរ ទែន មិនា................................២០០០០៛

១០.សាមណេរ សូត្រគុណ ធីម...........................១០០០០៛

១១.សាមណេរ លុច សុជាតិ.............................១០០០០៛

១២.សាមណេរ ស្រេង ហ៉ង................................១០០០០៛

១៣.សាមណេរ សែម រតនា……………………………..១០០០០៛

១៤.សាមណេរ ណុប សុផាន់ណាង……………………..១០០០០៛

១៥.សាមណេរ ម៉ែន សុខៃ…………………………….១០០០០៛

១៦.សាមណេរ សូ នាល……………………………....៥០០០៛

១៧.សាមណេរ ភ៉ា រី……………………………………...៥០០០៛

១៨.សាមណេរ នាង បូរី……………………………….៥០០០៛

១៩.សាមណេរ ម៉ែន សុឃី………………………..……….៥០០០៛

២០.សាមណេរ ឡុង ឆៅវៃន……………………………..៥០០០៛

២១.សមណសិស្ស សុង វុទ្ធី……………………………៥០០០០៛

២២.សមណសិស្ស តន់ឃោ ស៊ីណែត……..……………....៥០០០០៛

២៣.សមណសិស្ស ងួន ថៃនិត…..……………………..២៥០០០៛

២៤.សមណសិស្ស គូ សារិន…………..……………….១០០០០៛

២៥.សមណសិស្ស ព្រំ ផាន់នុត…………..…………….២០០០០៛

២៦.សមណសិស្ស ផា ភ័ស................................២០០០០៛

២៧.សមណសិស្ស រិន រី....................................២០០០០៛

២៨.សមណសិស្ស សយ ជីវ័ន្ត................................១០០០០៛

២៩.សមណសិស្ស ឈឿន ប្រុសតូច.........................៣០០០០៛

៣០.សមណសិស្ស បឿន បឿត...............................១០០០០៛

៣១.សមណសិស្ស ញ៉ែម ផល្លីដា............................១០០០០៛

៣២.សមណសិស្ស យឹម ប៊ុននឿន...........................៤០០០០៛

៣៣.សមណសិស្ស មាន សីហា...............................១០០០០៛

៣៤.សមណសិស្ស ម៉ុន ចិន....................................៥០០០០៛

៣៥.សមណសិស្ស វ៉ង ឆេន....................................១០០០០៛

៣៦.សមណសិស្ស ហេន ម៉ាន.................................២៥០០០៛

៣៧.សមណសិស្ស ហ៊ុំង ហេង................................១០០០០៛

៣៨.សមណសិស្ស ហើ ផាន់ណេត...........................២០០០០៛

៣៩.អ៊ិន ចាងវ៉ៃ..........................................១០០០០៛

៤០.សមណសិស្ស អុល វិសាល................................៥០០០៛

៤១.សមណសិស្ស ភឿន ណាត................................៥០០០៛

៤២.សមណសិស្ស ស្រស់ ឧស្សា...............................៥០០០៛

៤៣.សមណសិស្ស ផាត សភា.................................១០០០០៛

៤៤.សមណសិស្ស រនេ បូរី....................................១០០០០៛

៤៥.សមណសិស្ស ធី សុឋាត...................................៥០០០៛

៤៦.សមណសិស្ស ដា វណ្ណា....................................៥០០០៛

៤៧.សមណសិស្ស អេន សំអុង...............................៥០០០៛

៤៨.សមណសិស្ស ផន លី.....................................១០០០០៛

៤៩.សមណសិស្ស អេន រដ្ឋា...................................៣០០០០៛

៥០.ឧបាសក អេង សារោ.....................................៣០០០០៛

៥១.ឧបាសក ភឿ សុភ័ក្ត្រ...................................១០០០០០៛

៥២.ហ៊ល សុជាតិ...........................................៥០០០០៛

៥៣.ញ្រោមស្រី ស៊ុនហៃ....................................៤០០០០៛

៥៤.បងស្រីផាន...........................................៤០០០០៛

៥៥.បងស្រីរឿន...........................................១០០០០០៛

៥៦.បងស្រីខួច...........................................១០០០០០៛

៥៧.ស្រីង៉ាត់...........................................២០០០០៛

៥៨.ស្រីស...........................................២០០០០៛

៥៩.ស្រីពៅ...........................................១០០០០៛

៦០.អំញ្រិល...........................................១០០០០៛

៦១.លីលី...........................................២០០០០៛

៦២.លោកផ្លួយ&អ្នកស្រីស៊ីណាត...........................៥០០០០៛

៦៣.តាយង&យាយវៃ...........................................២០០០៛

៦៤.សួនម៉ាលី...........................................៥០០០៛

៦៥.ជឹកសាម៉ន.............................................៥០០០៛

៦៦.តានឿន&យាយអឹម....................................៥០០០៛

៦៧.អ៊ុនសារ៉េត...............................................៥០០០៛

៦៨.យាយយឿន..............................................២០០០៛

៦៩រស់សេងលី................................................៥០០០៛

៧០.អឹម ណុប....................................................៥០០០៛

៧១.យង់នាង..................................................១០០០០៛

៧២.ដាសិន.......................................................៥០០០៛

៧៣.ដារ៉ា............................................................៥០០០៛

៧៤.បងតូរ.........................................................៥០០០៛

៧៥.សន ស៊ីម...................................................៤០០០៛

៧៦.ឧបាសិកាលាង...........................................៥០០០៛

៧៧.ហ៊ាន ហឿន..............................................៥០០០៛

៧៨.លាងហ៊ីម..........................................................៥០០០៛

៧៩.ក្រុមបងស្រីផាត...............................................៨៥០០០៛

៨០.អ៊ុំអាចារ្យពេញសុជា..............................................៥០០០៛

៨១.លោកឈឺនបូរដ្ឋ&ភរិយា.......................................១០០០០៛

៨២.គង់រដ្ឋា&ភរិយា.....................................................១$

៨៣.ឈិនប៉ូរ៉ា&ស្វាមី....................................................៥០០០៛

៨៤.ឧបាសិកាតាំងចាន់តំកល់..................................១០០០០០៛

៨៥.ប្អូនស្រីគន្ធា.......................................................៦០០០០៛

៨៦.ប្អូនស្រីមករា.....................................................២០០០០៛

៨៧.លោកឡាយបូណា&ភរិយា....................................១០០០០៛

៨៨.អ្នកស្រីឈិនសាវន់..............................................១០០០០៛

៨៩.អ្នកស្រីរស់ស៊ីណា&ស្វាមី.....................................២០០០០៛

៩០.អាចារ្យឡាញ់&យាយទូច........................................៥០០០៛

៩១.ថៃ ស៊ីណាត.............................................២០០០០៛

៩២.តាមរស់សាម៉ុន&ភរិយា.................................១០០០០៛

៩៣.លោករស់សាម៉េត&ភរិយា..................................៥០០០៛

៩៤.លោករស់សាមិត្ត&ភរិយា....................................៥០០០៛

៩៥.អ្នកស្រីរស់សំណាង&ស្វាមី...................................៥០០០៛

៩៦.លោកថៃឈាន&ភរិយា.....................................១០០០០៛

៩៧.អ្នកស្រីថៃសូនី&ភរិយា........................................៥០០០៛

៩៨.អ្នកស្រីថៃសុម៉ាលី&ស្វាមី...................................១០០០០៛

៩៩.អ្នកស្រីថៃស៊ីនឿន&ស្វាមី.....................................៥០០០៛

១០០អ្នកស្រីរស់ស៊ីណោត&ស្វាមី................................២០០០០៛

១០១.នងសុគា..................................................១០០០០៛

១០២.បងសារ៉េត..............................................១០០០០៛

១០៣.ខឿន ចន្នី...............................................២០០០០៛

១០៤.នង ចន្ទ្រា………...……………………………..១០០០០៛

១០៥.សុន វណ្ណា…………...………………………….១០០០០៛

១០៦.គា ស៊ីនិត…………...…………………………..១០០០០៛

១០៧.សឿន អាត………...…………………………...១០០០០៛

១០៨.ឈឺន សិអុន……………………………………..១០០០០៛

១០៩.រិនវ័ត្ន………...……………………………………១០០០០៛

ព្រះភិក្ខុ បញ្ញាបទីបោ ភឿន ទបុល

គ្មានអ្វីធំជាងប្រយោជន៍ជាតិ